សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បទល្មើសឲ្រ្តួតគ្នា

## (ករណីនៅសាលាដំបូង)

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ថាប់ ចាន់ថន**

**លោក នូ ផាណ្ណី**

ណែនាំដោយ

**លោក ច័ន្ទ តារាស្មី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទនិស្សិតឈ្មោះ **ថាប់ ចាន់ថន** និងឈ្មោះ **នូ ផាណ្ណី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២៤ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅបំផុតជូនចំពោះ ៖**

លោកតា **ឃឹម ប៉ុណ្ណ** ដែលលោកតែងតែផ្តល់ដំបូន្មាននិងធ្វើជាគំរូដ៏ល្អសម្រាប់ចៅៗក្នុងវិស័យយុត្តិការ ព្រមទាំងដើរតួនាទីជាអ្នកផ្តល់កម្លាំងចិត្តដ៏សំខាន់ក្នុងការសិក្សាជំនាញនីតិសាស្ត្រ រហូតដល់ឆ្នាំចុងក្រោយដើម្បីសរសេរសារណាបញ្ចប់ការសិក្សានេះ។

លោកឪពុក **ថាប់ សារី - នូ នៀត** និងអ្នកម្តាយ **ធន់ ណារី - សាង គឹមអេង** ដែលលោកមានគុណទាំងបួន បានផ្តល់កំណើត និងធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានកូនឲ្យប្រព្រឹត្តខ្លួនដើរតាមគន្លងធម៌ព្រមទាំងទំនុកបម្រុងគ្រប់យ៉ាងទាំងផ្នែកសម្ភារៈ និងស្មារតី។ ជាពិសេសលោកតែងតែនៅចាំលើកទឹកចិត្តដល់កូនក្នុងការសិក្សា និងកិច្ចការផ្សេងៗទៀត តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យ ហើយទទួលបានជោគជ័យប្រកបដោយមោទនភាព។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រាចារ្យទាំងឡាយ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលលោកបានខិតខំបង្ហាត់បង្រៀនដល់ខ្ញុំបាទទាំង២រូប ក៏ដូចជានិស្សិតគ្រប់គ្នា អស់ពីកម្លាំងកាយចិត្តដោយការយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជាចាប់តាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ និងព្រមទាំងណែនាំអំពីមេរៀនជីវិត និងបទពិសោធន៍ក្នុងវិជ្ជាជីវៈ ដើម្បីទុកជាពុទ្ធិដ៏មានតម្លៃ និងមានប្រសិទ្ធភាពសម្រាប់ភាពជោគជ័យ និងកែលម្អជីវិតទៅថ្ងៃអនាគត។

ជាពិសេសទៅទៀតនេះ ខ្ញុំបាទសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅក្រៃលែងជូនចំពោះ **លោក ច័ន្ទ តារាស្មី** ដែលបានចំណាយពេលវេលាមកវាយតម្លៃ និងកម្លាំងកាយចិត្តដើម្បីធ្វើការណែនាំបង្ហាត់បង្ហាញផ្តល់យោបល់ និងផ្តល់នូវវិធីសាស្ត្រល្អៗក្នុងការសរសេរសារណា ព្រមទាំងជួយកែលម្អនូវរាល់ចំណុចខ្វះខាតទាំងឡាយណា ដែលជាប្រយោជន៍ដល់ការសរសេរសារណាឲ្យបានល្អប្រសើររហូតចងក្រងបានជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

សូមអរគុណចំពោះ **លោកសាស្ត្រាចារ្យ ញឹក វុឌ្ឍី** ប្រធានការិយាល័យស្រាវជ្រាវនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានជួយណែនាំដល់នូវមតិយោបល់ និងលើកទឹកចិត្តខ្ញុំបាទទាំង ២រូបរហូតដល់ការសរសេរបញ្ចប់កិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់ខ្ញុំបាទ សូមប្រសិទ្ធពរជ័យជូនចំពោះ **លោកឪពុក អ្នកម្តាយ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់** សូមឲ្យលោកជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន សុខភាពរឹងមាំជាពិសេសសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងសូមឲ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចពិតជាបានផ្តល់ឲ្យខ្ញុំបាទនូវចំណេះដឹងតាមរយៈការសិក្សាចម្រុះច្រើនបែបពីសាស្ត្រាចារ្យ ដែលមានទាំងបទពិសោធន៍ពោលគឺលោកនៅក្នុងវិជ្ជាជីវៈច្បាប់ស្រាប់ និងមានទាំងទ្រឹស្តីដែលធ្វើឲ្យនិស្សិតងាយយល់និងចាប់បានស្ទើតែគ្រប់ៗមេរៀន។ ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្ត ព្រមទាំងការខិតខំចំណាយពេលវេលាដ៏មានតម្លៃរបស់សាស្ត្រាចារ្យគ្រប់ៗរូបក្នុងការស្វែងរកឯកសារបង្រៀន បានធ្វើឲ្យខ្ញុំបាទក្លាយធនធានមនុស្ស និងជាធនធានមួយដែលអាចចូលរួមកសាងប្រទេសជាតិដើម្បីជម្រុញឲ្យឈានទៅរកវឌ្ឍនភាព និងភាពរុងរឿងដូចប្រទេសអភិវឌ្ឍន៍នានានៅលើសាកលលោកក៏ដូចជាការចូលរួមប្រកួតប្រជែងក្នុងកម្រិតអន្តរជាតិដែរ។

ដើម្បីជានាថានិស្សិតម្នាក់ៗ ទទួលបាននូវសមត្ថភាពមានចំណេះដឹងក៏ដូចជាឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងពីសាស្ត្រាចារ្យនោះ ខ្ញុំបាទបានធ្វើការស្រាវជ្រាវសារណាបញ្ចប់ការសិក្សានៅឆ្នាំទី៤ ជាឆ្នាំចុងក្រោយនេះដែលជាតម្រូវការរបស់សាកលវិទ្យាល័យដើម្បីធានាថានិស្សិតម្នាក់ៗ មានចំណេះដឹងអាចបង្កើតបាននូវស្នាដៃតម្កល់នៅក្នុងបណ្ណាល័យទុកឲ្យនិស្សិតជំនាន់ក្រោយៗទៀត ដើម្បីសិក្សាឈ្វេងយល់បន្ថែមពីប្រធានដែលទាក់ទងនឹងបទល្មើសត្រួតគ្នា។ ការសិក្សាចងក្រងនូវសារណានេះ ពិតជាមានការលំបាកត្រង់ការវាយអត្ថបទជាភាសាខ្មែរដោយត្រូវស្វែងរកឯកសារដែលពាក់ព័ន្ធដើម្បីពិគ្រោះ និងសរសេរបញ្ចូល ពីព្រោះប្រធានបទទាក់ទងទៅនឹងព្រហ្មទណ្ឌដែលផ្តោតទៅលើបទល្មើសត្រួតគ្នា នេះពុំសូវមានអ្នកសិក្សាស្រាវជ្រាវនោះទេ។

សារណាបញ្ចប់ការសិក្សាស្តីពី << **បទល្មើសត្រួតគ្នា** >> ដែលក្រុមខ្ញុំបាទបានស្រាជ្រាវឡើងនេះ គឺជាសារណាមួយដែលត្រូវបានគេសិក្សាតិចបំផុត។ ការសិក្សាពីនិយមន័យ ការកំណត់ពីស្ថានភាពបទល្មើសត្រួតគ្នាពេលខ្លះមានភាពភ័ន្តច្រលំនឹងបទល្មើសមិនរាងចាល។ រីឯនីតិវិធីនៃការដាក់ទោស និងការចោទប្រកាន់នៃបទល្មើសពេលខ្លះត្រូវបានយល់ឃើញខុសគ្នាៗដោយតុលាការគ្រប់ជាន់ថ្នាក់។ ការចោទប្រកាន់ដាច់ពីគ្នា ឬជាមួយគ្នាត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញាដោយគ្មានមាត្រាណាមួយមកកំណត់ការចោទប្រកាន់នេះឡើយ ពោលគឺអាស្រ័យលើស្ថាន-ភាពបទល្មើស ឬការយល់ឃើញរបស់ព្រះរាជអាជ្ញានៅក្នុងដំណាក់កាលនៃការចោទប្រកាន់ ឬដំណាក់កាលព្រះ-រាជអាជ្ញា។

ស្នាដៃដំបូងនេះអាចនឹងមានចំណុចខ្វះខាតដែលទាក់ទងនឹងអក្ខរាវិរុទ្ធ និងខ្លឹមសារពុំទាន់មានភាពស៊ីជម្រៅនៅឡើយដែលអាចធ្វើឲ្យអ្នកអានកើតឡើងនូវចម្ងល់ខ្លះអំពីប្រធានបទនេះ។ ហេតុដូច្នេះហើយ ខ្ញុំបាទសូមអភ័យទោសនៅរាល់កំហុសឆ្គងដែលអាចកើតឡើងដោយអចេតនានៅក្នុងសារណារបស់យើងខ្ញុំនេះ។ ខ្ញុំបាទទាំង២រូប សូមស្វាគមន៍ និងរង់ចាំនូវរាល់ការរិះគន់ដើម្បីស្ថាបនានូវរាល់កំហុសឆ្គងដោយក្តីរីករាយបំផុត។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៤

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

**ជំពូកទី១**

**ការកំណត់ស្ថានភាពត្រួតស៊ីគ្នានៃបទល្មើស**

**ផ្នែកទី១. ការបែងចែកពហុភាពបទល្មើស** ........ ៦

កថាខណ្ឌទី១. ការមិនរាងចាល និងស្ថានទម្ងន់ទោស ........ ៦

កថាខណ្ឌទី២. កំណត់និយមន័យបទល្មើសត្រួតគ្នា ........ ៧

**ផ្នែកទី២. អត្ថិភាពនៃបទល្មើសត្រួតគ្នា** ........ ៧

កថាខណ្ឌទី១. បទល្មើសតែមួយបង្កើតតម្លៃព្យសនកម្មពីរ ........ ៧

កថាខណ្ឌទី២. យុត្តិសាស្ត្ររបស់ អ.វ.ត.ក. ក្នុងបទល្មើសត្រួតគ្នា ........ ៧

**ជំពូកទី ២**

**ការចោទប្រកាន់ និងវិធានអនុវត្តទោស**

**ផ្នែកទី១. ការចោទប្រកាន់ជនល្មើស** ........ ១១

កថាខណ្ឌទី១. វិធានចោទប្រកាន់តែមួយ ........ ១១

១.១. និយមន័យ ..................... ១១

១.២. ស្ថានភាពក្នុងការចោទប្រកាន់តែមួយ ..................... ១២

**កថាខណ្ឌទី២. វិធានចោទប្រកាន់ដាច់ពីគ្នា** ..................... ១៤

២.១. និយមន័យ ..................... ១៤

២.២. ការចោទប្រកាន់បទល្មើស ..................... ១៤

**ផ្នែកទី២. ការអនុវត្តវិធានប្រកាសទោស** ..................... ១៦

**កថាខណ្ឌទី១. វិធានស្រូបទោស** ..................... ១៦

១.១. វិធានស្រូបទោសតាមបញ្ញត្តិមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ ..................... ១៧

១.២. វិធានស្រូបទោសតាមបញ្ញត្តិមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ ..................... ១៨

**កថាខណ្ឌទី២. វិធានត្រួតទោស** ..................... ២១

១.១. ការត្រួតទោសដែលមានប្រភេទខុសគ្នា (បញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ) ..................... ២២

១.២. ការត្រួតទោសដែលមានប្រភេទដូចគ្នា (បញ្ញត្តិមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ) ..................... ២៣

**ផ្នែកទី៣. វិធានបូកទោស** ..................... ២៦

**កថាខណ្ឌទី១. វិធានបូកទោសពិន័យចំពោះបទលហុ** ..................... ២៦

**កថាខណ្ឌទី២. វិធានបូកទោសចំពោះករណីរត់ចេញពីពន្ធនាគារ** ..................... ២៨

## ជំពូកទី៣

## ការអនុវត្តទោស

**ផ្នែកទី១. ការព្យួរទោស** ..................... ៣០

**កថាខណ្ឌទី១. ការព្យួរទោសធម្មតា** ..................... ៣០

១.១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា ..................... ៣១

១.២. អានុភាពនៃការព្យួរទោសធម្មតា ..................... ៣២

**កថាខណ្ឌទី២. ការព្យួរទោសសាកល្បង** ..................... ៣៤

២.១. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ...... ៣៤

២.២. អានុភាពការព្យួរទោសសាកល្បង ...... ៣៦

**ផ្នែកទី២. ការកម្រិតសិទ្ធិសេរីភាព...... ៣៨**

**កថាខណ្ឌទី១. របបពាក់កណ្ដាលសេរីភាព ...... ៣៨**

១.១. លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព...... ៣៩

១.២. អានុភាពនៃការប្រកាសរបបពាក់កណ្ដាលសេរីភាព...... ៣៩

**កថាខណ្ឌទី២. របបនៃការបែកចែកទោសជាប្រភាគ...... ៤០**

២.១. លក្ខខណ្ឌរបបបែងចែកទោសជាប្រភាគ...... ៤១

២.២. ការអនុវត្តរបបនៃការបែងចែកទោសជាប្រភាគ ...... ៤១

**សេចក្ដីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

# អក្សរកាត់ប្រើនៅក្នុងសារណានេះ

- ក្រ.នី.ព្រ.ទ មានន័យថា ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ក្រ.ព្រ.ទ មានន័យថា ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩
- អ.វ.ត.ក មានន័យថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បទល្មើស គឺជាអំពើទាំងឡាយណាដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់ ឬច្រើននាក់ ហើយអំពើនោះទៀតសោតបានបង្កឱ្យមានភាពចលាចល ខូចសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយក្នុងសង្គម និងអសន្តិសុខជាតិជាដើម។ ច្បាប់ព្រហ្មទណ្ឌបានកំណត់អំពីសកម្មភាពហាមឃាត់ និងកាតព្វកិច្ចមួយចំនួនក្នុងការធ្វើសកម្មភាពរួមគ្នា ដើម្បីការពារទំនាក់ទំនងរបស់មនុស្សនៅក្នុងសង្គមទាក់ទងលើការប្រព្រឹត្តនូវទង្វើដែលជាបទល្មើសដោយចេតនា ឬអចេតនាក្តីជាមួយនឹងទោសពិន័យ ឬការដាក់ទារុណកម្មជាប់ពន្ធនាគារ។ គោលបំណងចម្បងក្នុងមុខងារនៃច្បាប់ព្រហ្មទណ្ឌ គឺជួយរក្សាសណ្តាប់ធ្នាប់ និងស្ថេរភាពសង្គម ដោយគិតពីមុខងារ និងគោលបំណងខាងលើ ច្បាប់ព្រហ្មទណ្ឌបានផ្តល់នូវវិធានគន្លឹះអាចពិពណ៌នាអំពីរបៀបដែលបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនត្រូវបានចោទប្រកាន់លើបទល្មើសដែលបានប្រព្រឹត្ត។ ការកំណត់ការទទួលខុសត្រូវ និងទោសទណ្ឌអំពីបទល្មើសមួយ ឬច្រើន មានតួនាទីយ៉ាងសំខាន់ដើម្បីធានាឲ្យមាននូវភាពយុត្តិធម៌ក្នុងការដាក់ទណ្ឌកម្មចំពោះអ្នកដែលបំពានលើបទប្បញ្ញត្តិ ដើម្បីឲ្យសមាមាត្រនឹងសកម្មភាពល្មើសរបស់ពួកគេដូចបានកំណត់ក្នុងនីត្យានុកូលភាពនៃក្រមព្រហ្មទណ្ឌ។ ការផ្តន្ទាទោសឲ្យមានភាពសមាមាត្រ និងបទល្មើសរបស់ចារី គឺមានសារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅនៃច្បាប់ព្រហ្មទណ្ឌ ដូច្នេះ និស្សិត ឬអ្នកសិក្សាច្បាប់ មេធាវី និងអ្នកអនុវត្តច្បាប់គួរតែយល់ពីភាពខុសគ្នាជាមូលដ្ឋានរវាងបទល្មើសមួយ ឬច្រើន។ លើសពីនេះ អ្នកអនុវត្តច្បាប់ទាំងឡាយគួរយល់ពីវិធីសាស្ត្រ ឬនីតិវិធីក្នុងការចោទប្រកាន់ និងការគណនាទោសចំពោះបទល្មើសតែមួយ និងបទល្មើសច្រើនដែលជនល្មើសបានប្រព្រឹត្ត។

ជាទូទៅ ចារី ឬសហចារីតែងតែប្រព្រឹត្តនូវបទល្មើសតែមួយ ហើយពេលខ្លះទៀតពួកគេអាចប្រព្រឹត្តនូវបទល្មើសច្រើនជាងនេះក្នុងពេលដំណាលគ្នាមុន ឬក្រោយពេលសាលក្រមផ្តន្ទាទោសជាស្ថាពរ។ ការប្រព្រឹត្តបទល្មើសច្រើនទៀតសោត ពេលខ្លះក៏ត្រូវបានចោទប្រកាន់ក្នុងសំណុំរឿងតែមួយជាមួយនឹងការអនុវត្តទោសតាមវិធានចោទប្រកាន់តែមួយ ឬត្រូវបានចោទប្រកាន់ក្នុងសំណុំរឿងផ្សេងពីគ្នា ជាមួយនឹងការអនុវត្តទោសតាមវិធានចោទប្រកាន់ដាច់ពីគ្នាជាដើម។ ការប្រព្រឹត្តបទល្មើសច្រើនដោយចារី ឬសហចារីដែលអាចកើតមានឡើងក្នុងករណីច្រើនបែបយ៉ាង។ ករណីខ្លះតុលាការបានផ្តន្ទាទោសចារីនូវបទល្មើសមួយរួចហើយ ក្រោយមកចារីបានបន្តប្រព្រឹត្តបទល្មើសជាថ្មីទៀតដែលគេអាចហៅថាការមិនរាងចាល។ ជួនកាលទៀត ចារី ឬសហចារីបានប្រព្រឹត្តបទល្មើសច្រើនក្នុងពេលតែមួយ ឬក្នុងពេលខុសគ្នាដោយចារីបានប្រព្រឹត្តបទល្មើសមួយហើយមួយទៀតនៅមុនពេលដែលតុលាការបានផ្តន្ទាទោសជាស្ថាពរ។ ក្នុងករណីនេះ គេកំណត់ថាមាន ការត្រួតគ្នានៃបទល្មើស ឬមានបទល្មើសត្រួតគ្នា ដែលចាំបាច់ត្រូវតែយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្ត។ ក៏ប៉ុន្តែក្នុងករណីខ្លះទៀត ច្បាប់ព្រហ្មទណ្ឌបានកំណត់រួចជាស្រេចអំពីទោសជាក់លាក់ណាមួយដែលគេហៅថា ការបូកទោសតាមច្បាប់កំណត់ដោយមិនយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្តឡើយ។

ក្រមព្រហ្មទណ្ឌជាកម្រងច្បាប់សាធារណៈ ដែលចង្អុលបង្ហាញអំពីបទល្មើសបុគ្គលត្រូវទទួលខុសត្រូវចំពោះបទល្មើស ប្រភេទ និងបែបបទនៃការអនុវត្តទោស។ ក្រមព្រហ្មទណ្ឌកម្ពុជាដែលមានសរុប ៦៧២មាត្រាត្រូវបានចងក្រងជា ៦គន្ថី។ នៅក្នុងនោះ គន្ថីទី១ ត្រួសត្រាយឱ្យដឹងអំពីបទប្បញ្ញត្តិទូទៅនៃក្រមដែលនិយាយអំពីគោលការណ៍សំខាន់នានាដែលមានជាអាទិ៍ គោលការណ៍ដែនដី ឬសញ្ជាតិ នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍ប្រតិសកម្ម និងមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គោលការណ៍អាជ្ញាអស់ជំនុំ ក៏ដូចជាគោលការណ៍សច្ចធារណ៍នៃទោស។ ចំពោះគន្ថីទី២ នៃក្រមព្រហ្មទណ្ឌវិញ គឺសំដៅជារួមរាល់បទល្មើសប្រឆាំងនឹងបុគ្គល ខណៈគន្ថីទី៣ជាប្រភេទនៃបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងគន្ថីទី៤ គ្របដណ្តប់រាល់បទល្មើសប្រឆាំងនឹងជាតិ។ ដោយពិនិត្យយ៉ាងជាក់លាក់លើខ្លឹមសារនៃមាត្រាទាំងឡាយនៃ ៣គន្ថីនោះ ច្បាប់ព្រហ្មទណ្ឌបានដើរតួនាទីក្នុងការបង្ក្រាប បង្ការបទល្មើស និងកែប្រែអប់រំធនធានរបស់សង្គមយ៉ាងស្វិតស្វាញ ខណៈដែលបទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបង្ហាញត្រង់មាត្រា១៣៧ និងមាត្រា១៣៨ ដែលបានកំណត់ពីចារីដែលបានប្រព្រឹត្តបទល្មើសច្រើនបង្កើតជាបទល្មើសត្រួតគ្នា ដោយត្រូវស្ថិតក្នុងការចោទប្រកាន់តែមួយ ឬដាច់ពីគ្នាដែលមានលក្ខខណ្ឌផ្សេងៗគ្នា។ នៅក្នុងការកំណត់ទោសទៅលើចារី តុលាការត្រូវធ្វើការពិចារណាដោយបែងចែកសម្មតិកម្មពីរយ៉ាង យោងទៅតាមវិធានទូទៅអនុវត្តទៅលើបទល្មើសត្រួតគ្នាគឺ ករណីនៃការចោទប្រកាន់តែមួយ និងករណីនៃការចោទប្រកាន់ដាច់ពីគ្នា ក៏ប៉ុន្តែក្នុងករណីពិសេស ក្រមព្រហ្មទណ្ឌតម្រូវឲ្យមានការបូកបញ្ចូល គ្នាដោយមិនបាច់ពិចារណាថា ជាការចោទប្រកាន់តែមួយ ឬជាការចោទប្រកាន់ដាច់ដោយឡែកពីគ្នានោះទេ។ ការកំណត់ចំណាំអំពីបទល្មើសត្រួតគ្នា និងបទល្មើសមិនរៀងចាលសព្វថ្ងៃនៅមានភាពច្រលំគ្នា និងការអនុវត្តនីតិវិធីចោទប្រកាន់នៅតែមានភាពស្មុគស្មាញនៅឡើយ។ ហើយបទល្មើសត្រួតគ្នានេះក៏មិនទាន់មានការសិក្សាណាមួយបញ្ជាក់ច្បាស់លាស់អំពីសញ្ញាណនៃបទល្មើសរហូតដល់នីតិវិធីនៃការចោទប្រកាន់ និងលក្ខខណ្ឌនៃការ ប្រកាសទោសនៅឡើយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បទល្មើសត្រួតគ្នាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា១៣៧ និង១៣៨ និងបទល្មើសស្រដៀងដទៃទៀតដូចមានចែងក្នុងមាត្រា៨៤ ស្តីពីបទល្មើសមិនរាងចាល និងមាត្រា១៤០ ស្តីពីការបូកទោសបញ្ចូលគ្នា និងមាត្រា១៤១ ស្តីពីការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ហើយមិនទាន់មានការពន្យល់លំអិតសម្រាប់អ្នកសិក្សានីតិសាស្ត្រមួយចំនួន។ មាត្រាទាំងនេះទៀតសោត ក៏មានភាពខុសគ្នានៃការស្រូបទោសត្រង់មាត្រា១៣៧ គឺមិនតម្រូវឲ្យទណ្ឌិតស្នើសុំអនុវត្តវិធានស្រូបទោសនោះទេ ពោលនៅពេលដែលទណ្ឌិតបានប្រព្រឹត្តបទល្មើសច្រើនករណីដែលអាចឲ្យព្រះរាជអាជ្ញាចោទប្រកាន់ក្នុងលិខិតតែមួយបាន ចៅក្រមត្រូវសម្រេចដាក់ទណ្ឌកម្ម ដោយកំណត់យកទោសមួយ

ជាទោសធ្ងន់បំផុតប៉ុន្តែត្រឹមកម្រិតអតិបរិមានៃបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងនោះ។ ចំណែកឯមាត្រា១៣៨ នៃក្រ.ព្រ.ទ គឺតម្រូវឲ្យចារីស្នើសុំស្រូបទោសទៅលើបទល្មើសត្រួតគ្នាដែលខ្លួនបានប្រព្រឹត្ត ដោយហេតុថាអង្គហេតុត្រូវបានកំណត់ក្នុងការចោទប្រកាន់ដាច់ពីគ្នារបស់ព្រះរាជអាជ្ញា។

ប៉ុន្តែការកំណត់បញ្ហាលំបាកមិនមែនស្ថិតតែនៅត្រង់អត្ថន័យ និងខ្លឹមសារនៃវិធាននីមួយៗនោះទេ គឺបញ្ហាលំបាកត្រង់ការកំណត់កាលៈទេសៈនៃបទល្មើសមួយថាជាបទល្មើសត្រួតគ្នា ព្រោះជាប្រការមួយសំខាន់ដែលយើងត្រូវតែស្គាល់ឲ្យបានច្បាស់លាស់ជាមុនសិន។ ការទាមទារឲ្យស្គាល់នូវស្ថានភាពនៃបទល្មើសត្រួតគ្នាឲ្យបានច្បាស់ លាស់នេះក៏ដោយសារថាមាត្រា១៣៦ នៃក្រ.ព្រ.ទ. គ្រាន់តែឲ្យបាននិយមន័យទូលាយនៃបទល្មើសត្រួតគ្នាដោយបរិយាយថា “ **មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត** ”។

ការស្គាល់អំពីស្ថានភាពគតិយុត្តនៃបទល្មើសត្រួតគ្នាក្នុងច្បាប់កម្ពុជា គឺដាច់ខាតត្រូវតែផ្អែកលើយុត្តិ-សាស្ត្រនានារបស់ **អ.វ.ត.ក.** ដែលជាប្រភពមួយនៃនីតិកម្ពុជា និងជាអ្នកត្រួតត្រាយផ្លូវឲ្យបទប្បញ្ញត្តិព្រហ្មទណ្ឌមានលក្ខណៈគ្រប់គ្រាន់ និងច្បាស់លាស់ ព្រមទាំងធ្វើឲ្យនីតិកម្ពុជាអាចរីកវឌ្ឍន៍ទៅរកភាពល្អប្រសើរមួយក្នុងបំណងចៀសវាងការបកស្រាយមិនឯកភាពគ្នារបស់ចៅក្រម ដែលអាចបំពានលើគោលការណ៍បកស្រាយតឹងរ៉ឹងចំពោះច្បាប់ព្រហ្មទណ្ឌដោយប្រការណាមួយ។ រីឯនីតិព្រហ្មទណ្ឌបារាំងក៏ត្រូវដើរតួនាទីដ៏សំខាន់ផងដែរសម្រាប់នីតិព្រហ្ម-ទណ្ឌកម្ពុជា ពីព្រោះថានីតិព្រហ្មទណ្ឌកម្ពុជាបានទទួលរងនូវឥទ្ធិពលប្រពៃណីពីប្រព័ន្ធច្បាប់ស៊ីវិល នឹងជាពិសេសឥទ្ធិពលរបស់នីតិបារាំងផ្ទាល់តែម្តង។

ម៉្យាងវិញទៀត ការអនុវត្តន៍នីតិវិធីចោទប្រកាន់ និងការជំនុំជម្រះលើបទល្មើសត្រួតគ្នានៅមានភាពមិនច្បាស់លាស់ពីព្រោះការសម្រេចរបស់ចៅក្រមនៅក្នុងសវនាការ ដោយមានការយល់ឃើញខុសៗគ្នាស្ទើតែគ្រប់សាលាជម្រះក្តី។ នៅក្នុងសំណុំរឿងនីមួយៗ ទណ្ឌិតភាគច្រើនស្នើសុំអនុវត្តការស្រូបទោសទៅកាន់ចៅក្រម ហើយការសម្រេចនោះទៀតសោត ចៅក្រមយល់ឃើញខុសៗគ្នាក្នុងការសម្រេចនោះ។

ដោយយោងតាមបញ្ហានៃបទល្មើសត្រួតគ្នាដែលបានរៀបរាប់ខាងលើនេះ ការសិក្សាស៊ីជម្រៅនៃបទល្មើសនៅមិនទាន់មានអ្នកសិក្សានៅឡើយនោះទេ។ ដូច្នេះក្រុមរបស់ខ្ញុំបាទនឹងសិក្សាអំពីសញ្ញាណនៃបទល្មើសត្រួតគ្នា នីតិវិធី ឬលក្ខខណ្ឌនៃការវិធានស្រូបទោស ការបូកទោស និងការប្រកាសទោស ។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ស្របតាមបញ្ហាដែលបានរៀបរាប់ខាងលើ គោលបំណងសំខាន់នៃការសិក្សានេះគឺដើម្បីបញ្ជាក់ឱ្យច្បាស់ពីធម្មជាតិនៃបទល្មើសត្រួតគ្នា នីតិវិធីនៃការចោទប្រកាន់ ការប្រកាសទោស លក្ខខណ្ឌដែលអាចស្រូបទោស និងបូកទោសព្រមទាំងបូកនូវការផាកពិន័យជាទឹកប្រាក់ ដែលមានចែងក្នុងមាត្រានីមួយៗនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយហេតុថាការសិក្សាទៅលើប្រធានបទ “ **បទល្មើសត្រួតគ្នា** ” ពុំសូវមានការសិក្សាលម្អិតពីមជ្ឈដ្ឋានអ្នកសិក្សាច្បាប់ និងភាគច្រើនការបកស្រាយមានតែក្នុងការអនុវត្តផ្ទាល់ពីស្ថាប័នតុលាការកម្ពុជា។ ម៉្យាងវិញទៀតស្ថាប័នតុលាការកម្ពុជាមានច្រើនជាន់ថ្នាក់, រីឯការសម្រេចសេចក្តី និងការពន្យល់បង្ហាញក្នុងសាលក្រម និងសាលដីកាក៏មានកម្រិតទៅតាមតុលាការនីមួយៗផងដែរ។ អាស្រ័យហេតុនេះ ដើម្បីធានា និងរក្សាឲ្យបាននូវប្រសិទ្ធភាពអំពីការសិក្សាប្រធានបទខាងលើ ខ្ញុំបាទទាំង ២រូបនឹងសិក្សាលម្អិតត្រឹមកម្រិតសាលក្រមរបស់សាលាដំបូងរាជធានីខេត្ត ដែលបានសម្រេចប្រកាសជាសាធារណៈនាពេលកន្លងមក នឹងយកមកធ្វើជាទឡ្ហីករណ៍ក្នុងការស្រាវជ្រាវដើម្បីសរសេរសារណានេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ក្រុមខ្ញុំបាទបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដើម្បីទទួលបានចំណេះដឹងផ្នែកទ្រឹស្តី និងចំណេះដឹងទាក់ទងនឹងការអនុវត្ត ព្រមទាំងទទួលបានបទពិសោធន៍ អំពីសញ្ញាណនៃបទល្មើសត្រួតគ្នា នីតិវិធីនៃការចោទប្រកាន់ និងការប្រកាសទោសជាមួយលក្ខខណ្ឌផ្សេងៗដែលកំពុងអនុវត្តនៅក្នុងសង្គមកម្ពុជាឲ្យមានភាពច្បាស់លាស់និងស៊ីជម្រៅជាងមុនបន្ថែមទៀត។ ការស្រាវជ្រាវលើប្រធានបទនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមខ្ញុំបាទ ដើម្បីឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តប្រកបដោយភាពជោគជ័យ និងដើម្បីចូលរួមចំណែកអភិវឌ្ឍន៍វិស័យយុត្តិធម៌នៅកម្ពុជា ឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងថែមទៀត។ ជាពិសេសខ្ញុំបាទសង្ឃឹមថាសមិទ្ធផលនៃការស្រាវជ្រាវប្រធានបទនេះ អាចទុកជាឯកសារមួយសម្រាប់ប្អូនៗដែលជានិស្សិតជំនាន់ក្រោយៗ សម្រាប់ការឈ្វេងយល់អំពីអ្វីទៅជាបទល្មើសត្រួតគ្នា ព្រមទាំងលក្ខខណ្ឌនីតិវិធីនៃការចោទប្រកាន់ និងការប្រកាសទោសដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ន ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់លាស់ និងមានភាពត្រឹមត្រូវបន្ថែមទៀត។

## ៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទបានខិតខំប្រើប្រាស់វិធីសាស្រ្តជាច្រើន ដើម្បីយកមកសរសេរសារណានេះឡើងតួយ៉ាងដូចជា ការប្រមូលទិន្នន័យតាមបែបគុណវិស័យដែលជាទិន្នន័យបានមកពីការប្រមូលឯកសារទ្រឹស្តី ព័ត៌មាន ការស្នើសុំឯកសារ និងរបាយការណ៍ សាលក្រម ឬសាលដីការ ដើម្បីឲ្យដំណើរការនៃការស្រាវជាវនេះទទួលបានភាពជោគជ័យ។ ចំពោះប្រភព និងប្រភេទនៃវិធីប្រមូលទិន្នន័យ ឯកសារ និងព័ត៌មានដែលបានសរសេរតាមគុណវិស័យរួមមាន ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

- លិខិតបទដ្ឋានគតិយុត្ត យុត្តិសាស្ត្រ សាលក្រម សាលដីកា និងបទប្បញ្ញត្តិនានា
- របាយការណ៍ និងសៀវភៅមេរៀនរបស់សាស្ត្រាចារ្យផ្សេងៗ
- ការទទួលនូវធាតុចូលពីសាស្ត្រាចារ្យដឹកនាំកិច្ចការសារណា
- និងការប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រុមខ្ញុំបាទបានកំណត់រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវប្រធានបទ “**បទល្មើសត្រួតគ្នា**” ដោយត្រូវបាន បែងចែកការសិក្សាស្រាវជ្រាវជា ៣ជំពូកដូចខាងក្រោមៈ

**ជំពូកទី១.** ការកំណត់ស្ថានភាពត្រួតស៊ីគ្នានៃបទល្មើស

**ជំពូកទី២.** នីតិវិធីនៃការចោទប្រកាន់

**ជំពូកទី៣.** ការអនុវត្តទោស

# ជំពូកទី១

# ជំពូកទី១

# ការកំណត់ស្ថានភាពត្រួតស៊ីគ្នានៃបទល្មើស

## ផ្នែកទី១. ការបែងចែងពហុភាពបទល្មើស

ការកំណត់ជាមូលដ្ឋាននៃបទល្មើសច្រើន ឬពហុភាពបទល្មើស មានស្ថានភាពកើតឡើងដូចគ្នាទៅនឹងបទល្មើសទូទៅធម្មតាផងដែរ គឺត្រូវការធាតុផ្សំបទល្មើស ដំណាក់កាលប្រព្រឹត្តបទល្មើស ចារីដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាដើម។ ប៉ុន្តែចំណុចដែលខុសគ្នានោះត្រង់ពហុភាពបទល្មើសជាប្រភេទបទល្មើសដែលមានបទល្មើសធម្មតាលើសពីមួយករណី ដែលបុគ្គលដដែលជាអ្នកប្រព្រឹត្តទាំងនោះ។ ពាក្យ “ **បុគ្គល** ” គឺសំដៅទៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល និងនីតិបុគ្គល។ មានស្ថានភាពជាច្រើនដែលបានបង្ហាញអំពីពហុភាពនៃបទល្មើសដែលអាចកើតឡើងនៅគ្រប់ពេលវេលារួមមាន ការមិនរាងចាល ស្ថានទម្ងន់ទោស និងបទល្មើសត្រួតគ្នា។ ការកំណត់ទណ្ឌកម្មក្នុងករណីមានពហុភាពបទល្មើស[1] នឹងមានបញ្ហាចោទដ៏ធំមួយ ប្រសិនបើយើងមិនអាចបែងចែកឲ្យបានដាច់ស្រឡះ អំពីស្ថានភាពដែលប្រហាក់ប្រហែលគ្នារវាងអំពើល្មើសជាក់ស្តែង និងទ្រឹស្តីច្បាប់ពហុភាពបទល្មើសនីមួយៗ។

## កថាខណ្ឌទី១. ការមិនរាងចាល និងស្ថានទម្ងន់ទោស

ការមិនរាងចាលវិញ គឺជាស្ថានភាពគតិយុត្តដែលចារីម្នាក់ត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពររួចហើយលើបទល្មើសមុន ហើយបានប្រព្រឹត្តបទល្មើសថ្មីមួយទៀត ក្នុងរយៈពេលកំណត់ជាក់លាក់។[2] ចំពោះស្ថានទម្ងន់ទោសវិញគឺមិនមែនជាធាតុផ្សំនៃបទល្មើសនោះទេ ហើយវាមិនបានទៅធ្វើឲ្យមានការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធជាមូលដ្ឋាននៃបទល្មើសនោះដែរ ពោលវាគឺគ្រាន់តែជាកាលៈទេសៈពិសេសនៃបទល្មើស។[3] ស្ថានភាពទាំងនោះអាចជាក្រុមមានការចាត់តាំង ការគិតទុកជាមុន ការកាប់គាស់ទម្លុះទម្លាយ ការឆ្លោះរបងចូល អាវុធ ឬវត្ថុដែលត្រូវចាត់ទុកថាជាអាវុធ និងការពួនស្ទាក់ជាដើម (ស្ថានទម្ងន់ទោសទូទៅ)។[4] ទាំងអស់នេះគឺជាស្ថានទម្ងន់ទោសទូទៅ ដោយឡែកបទល្មើសនីមួយៗក៏មានស្ថានទម្ងន់ពិសេសផងដែរ។ **ឧទាហរណ៍៖** នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៤៨៦ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១២ ជនជាប់ចោទត្រូវបានសាលាដំបូងខេត្តបាត់ដំបងប្រកាសពិរុទ្ធភាពពីបទរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះជាអនីតិជនអាយុ១៤ឆ្នាំ តាមមាត្រា ២៤១ នៃក្រ.ព្រ.ទ.។[5] ក្នុងករណីនេះ ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈមិនមានការប្រែប្រួលនោះទេ ដោយ

[1] អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក., សាលដីការបស់ឌុច ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១២, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧។

[2] ក្រមព្រហ្មទណ្ឌ, នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៨៤។

[3] ច្បាប់ព្រហ្មទណ្ឌបារាំង, (France 2005, Hachette, 3ème édition), ទំព័រទី១៣៣។

[4] ក្រមព្រហ្មទណ្ឌ, នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៧៧, ៧៨, ៧៩, ៨០, ៨១, និង មាត្រា៨២។

[5] សាលក្រមលេខ១០(យ) ចុះថ្ងៃទី០៥ ខែ កុម្ភៈ ឆ្នាំ២០១៤ របស់ខេត្តបាត់ដំបង។

គ្រាន់តែថាមានកាលៈទេសៈពិសេសបន្ថែមទៅលើធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ ដែលមានជនរងគ្រោះជាអនីតិជន។

## កថាខណ្ឌទី២. កំណត់និយមន័យបទល្មើសត្រួតគ្នា

បទល្មើសត្រួតគ្នាគឺបានកំណត់នៅក្នុងមាត្រា១៣៦ នៃក្រ.ព្រ.ទ. បានចែងកំណត់ថា “ *មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត ។*

ផ្ទុយពីស្ថានទម្ងន់ទោស និងការមិនរាងចាល នៅក្នុងករណីបទល្មើសត្រួតគ្នាវិញ ជនល្មើសមិនទាន់បានទទួលនូវការផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមុនណាមួយនោះទេ។ សំណួរចោទឡើងមុនគេត្រង់ថា តើពេលណាដែលការសម្រេចផ្តន្ទាទោសចូលជាស្ថារ។ សេចក្តីសម្រេចរបស់តុលាការមួយចូលជាស្ថាពរវាប្រែប្រួលទៅតាមប្រភេទនៃសេចក្តីសម្រេចនេះ។ កាលណាអំឡុងពេលប្តឹងទាស់នឹងសាលក្រមកំបាំងមុខ ប្តឹងឧទ្ធរណ៍ ប្តឹងទាស់ នឹងសាលដីកាកំបាំងមុខ ឬប្តឹងសាទុក្ខបានផុតកំណត់ ឬនិយាយម្យ៉ាងទៀតថា អស់ផ្លូវបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការនោះ សេចក្តីសម្រេចនោះនឹងក្លាយជាស្ថាពរ។[6]

ក្រឡេកមកមើលសំណុំរឿងនៅក្នុងសាលដីការឿងក្តី០០១ ដែលមានជនជាប់ចោទ **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** បានឲ្យនិយមន័យបទល្មើសត្រួតគ្នាថា “ **ច្បាប់ដែលពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នា ឬការវិនិច្ឆ័យពីបទល្មើសត្រួតគ្នាលើជនជាប់ចោទតែម្នាក់ពាក់ព័ន្ធនឹងអង្គហេតុមួយដែលមានកាលៈទេសៈនៃបទល្មើសច្រើន** ” ។ ការកំណត់និយមន័យនៃពាក្យ “ **បទល្មើសត្រួតគ្នា** ” នេះ គឺគ្រាន់តែបានគ្របដណ្តប់ទៅលើការត្រួតគ្នាផ្នែកគំនិតនៃបទល្មើស ពោលគឺបទល្មើសត្រួតគ្នាដែលកើតចេញពីអំពើល្មើសតែមួយរបស់ **ឌុច** នៅក្នុងមន្ទីរ **ស ២១**។ តែទោះយ៉ាងណាក៏ដោយនិយមន័យនៃបទល្មើសត្រួតគ្នាដែលបរិយាយដោយអង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** ពិតជាបានបំពេញនូវចន្លោះខ្វះខាតរបស់ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា ពីព្រោះថាការកំណត់អំពីពិរុទ្ធភាពច្រើនដែលកើតចេញមកពីអំពើល្មើសតែមួយ គឺជារឿងលំបាកស្មុគស្មាញដែល ច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនបានផ្តល់ជាដំណោះស្រាយសោះ។

# ផ្នែកទី២. អត្ថិភាពនៃបទល្មើសត្រួតគ្នា

## កថាខណ្ឌទី១. បទល្មើសតែមួយបង្កើតតម្លៃព្យសនកម្មពីរ

ពហុភាពនៃបទល្មើសដែលកើតចេញពីបទល្មើសច្រើន វាមិនចោទជាបញ្ហាក្នុងការកំណត់អំពីស្ថានភាពត្រួតគ្នានៃបទល្មើសនោះទេ ប៉ុន្តែចំណុចសំខាន់គឺការកំណត់អំពីកាលបរិច្ឆេទនៃការចូលជាស្ថាពរនៃការផ្តន្ទាទោសចំពោះបទល្មើសមុន។ ការលំបាកក្នុងការកំណត់អំពីបទល្មើសត្រួតគ្នា ឬពិរុទ្ធភាពត្រួតគ្នានឹងចោទជាបញ្ហាសំខាន់

[6] ក្រមព្រហ្មទណ្ឌ, នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៣៦៨, ៣៨១, ៣៨៣, ៨១២, និងមាត្រា៨២០។

ដែលបទល្មើសតែមួយបំពានទៅលើតម្លៃសង្គមពីរ ឬច្រើន ពោលមានការត្រួតគ្នាលក្ខណៈគតិយុត្តនៃអង្គហេតុ ឬពហុលទ្ធភាពក្នុងការធ្វើគុណវុឌ្ឍន៍លើអំពើល្មើស។ ការត្រួតគ្នាពិតប្រាកដនៃបទល្មើស ឬបទល្មើសត្រួតគ្នាដែលយើងកំពុងសិក្សាវែកញែកនេះ មិនត្រូវភ័ន្តច្រឡំជាមួយនឹងការត្រួតគ្នាផ្នែកគំនិតនៃបទល្មើស (ឬហៅថាការត្រួតគ្នាលក្ខណៈគតិយុត្តនៃអង្គហេតុ) ដែលបង្ហាញឡើងតាមអត្ថិភាពនៃពហុភាពនៃការធ្វើគុណវុឌ្ឍន៍ទៅលើអំពើតែមួយ។ នីតិនិពន្ធកម្ពុជាមិនបានកំណត់ស្ថានភាពនៃជម្លោះផ្នែកគំនិតនេះនោះទេ។ ផ្អែកលើទ្រឹស្តីនៅពេលដែលអង្គហេតុសត្យានុម័តតែមួយគត់អាចក្លាយទៅជាពហុគុណវុឌ្ឍន៍ផ្នែកព្រហ្មទណ្ឌ ហើយជាគោលការណ៍ចៅក្រមត្រូវតែជ្រើសរើសយកគុណវុឌ្ឍន៍មួយដែលមានទោសធ្ងន់ធ្ងរជាងគេក្នុងចំណោមគុណវុឌ្ឍន៍ទាំងអស់ ឬគុណវុឌ្ឍន៍ដែលពិសេសជាងគេ ពោលគឺគុណវុឌ្ឍន៍ដែលនៅជិតបំផុតនៃអង្គហេតុដែលបានប្រព្រឹត្ត។ ក៏ប៉ុន្តែនៅពេលដែលអង្គហេតុសត្យានុម័តតែមួយបានបំពានទៅលើតម្លៃសង្គមពីរ ឬច្រើនដែលត្រូវបានការពារ ការប្រកាសអំពីពិរុទ្ធភាពនានាអាចនឹងត្រូវបានធ្វើឡើងហើយទោសនីមួយៗនឹងត្រូវបានប្រកាស។

**ឧទាហរណ៍៖** ការបោកគ្រាប់បែកចូលផ្ទះការគឺជាការបំពានទៅលើតម្លៃសង្គមចំនួនពីរគឺជីវិតមនុស្ស និងទ្រព្យសម្បត្តិ។ បទល្មើសចំនួនពីរបានកើតឡើងគឺ បទឃាតកម្ម និងបទការធ្វើឲ្យខូចខាតដោយចេតនា។

## កថាខណ្ឌទី២. យុត្តិសាស្ត្ររបស់ អ.វ.ត.ក. ក្នុងបទល្មើសត្រួតគ្នា

ចូរកុំភ្លេចថាប្រភពនៃនីតិរាប់បញ្ចូលផងដែរនូវយុត្តិសាស្ត្ររបស់តុលាការ។ ទ្រឹស្តីខាងលើនេះវាស្របទៅនឹងអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** បានលើកឡើងនៅក្នុងសាលដីការបស់ខ្លួន ក្នុងសំណុំរឿង ០០១ ដែលមានជនជាប់ចោទឈ្មោះ **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច**។[7] **ឌុច** ដែលជាប់ចោទ និងត្រូវបានតុលាការកំពូលរបស់ **អ.វ.ត.ក.** រកឃើញអំពីពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ បទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឲ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀតត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[8] សេចក្តីសម្រេចនេះបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, ក្នុងសំណុំរឿងនេះ **ឌុច** អង្គជំនុំជម្រះសាលាដំបូងបានសម្រេចស្រូបបញ្ចូលបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋ ដែលអង្គជំនុំជម្រះសាលាដំបូង ដោយសារមូលហេតុនយោបាយ និងឧក្រិដ្ឋកម្មនេះមានភាពជាក់លាក់ជាងគេ។[9] ប៉ុន្តែអង្គជំនុំជម្រះតុលាការបដិសេធ ដូច្នេះ ដោយផ្អែកលើវិធានក្នុងការកំណត់បទល្មើសត្រួតគ្នា និងលើកឡើងនូវទឡ្ហីករណ៍ដូច៖[10]

[7] អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** សាលដីកា (**កាំង ហ្គេចអ៊ាវ** ហៅ **ឌុច**) ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១២, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧។

[8] អង្គជំនុំជម្រះសាលាដំបូងនៃ **អ.វ.ត.ក.** សាលក្រម (**កាំង ហ្គេចអ៊ាវ** ហៅ **ឌុច**) ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧, ទំព័រទី៥៦២។

[9] សាលក្រម ដដែល, កថាខណ្ឌទី៥៦៨ ទំព័រទី៣៣១។

[10] ដដែល, ទំព័រទី២៣៥ ដល់ ២៥០, កថាខណ្ឌទី២៨៦ ដល់ ២៩៥។

បទល្មើសត្រួតគ្នា គឺជាច្បាប់ដែលពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នា ឬការវិនិច្ឆ័យពីបទល្មើសត្រួតគ្នាលើជនជាប់ចោទតែម្នាក់ពាក់ព័ន្ធនឹងអង្គហេតុមួយដែលមានកាលៈទេសៈនៃបទល្មើសច្រើន។ ការសម្រេចដាក់ពិរុទ្ធ-ភាពពីបទល្មើសត្រួតគ្នា ដែលបានកំណត់ដោយបទប្បញ្ញត្តិផ្សេងគ្នា ប៉ុន្តែបានផ្អែកលើអំពើតែមួយនោះគឺអាចធ្វើទៅបានតែក្នុងករណីដែលបទប្បញ្ញត្តិពាក់ព័ន្ធនីមួយៗ ក្នុងនោះមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តដែលពុំមាននៅក្នុងបទល្មើសផ្សេងទៀតទេ។ ធាតុផ្សំមួយមានភាពដាច់ដោយឡែកជាសត្យានុម័តពីធាតុផ្សំមួយផ្សេងទៀត គឺថាប្រសិនបើនៅពេលមានតម្រូវការ ឲ្យបង្ហាញភស្តុតាងអំពីអង្គហេតុមួយចំពោះធាតុផ្សំនេះនោះមិនទាមទារឲ្យធ្វើដូច្នេះឡើយចំពោះធាតុផ្សំផ្សេងមួយទៀត។ នៅពេលដែលមិនអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះបានអង្គជំនុំជម្រះត្រូវសម្រេច ថាតើបទល្មើសណាមួយដែលខ្លួនត្រូវសម្រេចដាក់ពិរុទ្ធភាព។ កិច្ចការនេះអាចសម្រេចបានដោយផ្អែកលើគោលការណ៍ថាការសម្រេចដាក់ពិរុទ្ធភាពត្រូវ អនុវត្តតាមបទប្បញ្ញត្តិដែលមានភាពជាក់លាក់ជាងគេ។ ដូច្នេះ ប្រសិនបើអង្គហេតុកើតឡើងមួយស្ថិតក្រោមបទប្បញ្ញត្តិពីរ ដោយបទប្បញ្ញត្តិមួយមានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តបន្ថែមលើសគេ នោះការសម្រេចដាក់ពិរុទ្ធភាពត្រូវអនុលោមតាមបទប្បញ្ញត្តិដែលមាន ភាពជាសត្យានុម័តលើសគេនោះ។ ដោយឈរលើគោលការណ៍ទូទៅនៃច្បាប់ដែលមានការយល់ដឹងជាទូទៅនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាអំពីការអនុវត្តជាក់ស្តែង ជារួមពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នាចំពោះអំពើប្រព្រឹត្តដូចគ្នា ប្រសិនបើបទល្មើសទាំង នោះមានប្រភេទដាច់ដោយឡែកពីគ្នាគ្រប់គ្រាន់តាមច្បាប់កម្ពុជានោះនឹងទ្រឹស្តីខ្វែងគ្នា និងតែងតែមិនអាចរកចំណុចរួមនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលនេះ គឺជាផលវិបាកនៃការត្រួតគ្នានេះ។ នេះជាការពិតទាក់ទងនឹងផ្នែកទាំងពីរ គឺទាំងផ្នែកនៃការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា និងការប្រកាសទោសដោយសារតែជាផ្នែកមួយនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។

ប្រទេសប្រកាន់ច្បាប់ស៊ីវិលទំនងជាធ្វើដូច្នេះ ដោយសំអាងលើទ្រឹស្តីការត្រួតស៊ីគ្នាតែមួយ។ ក្រមព្រហ្ម-ទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មាត្រា១២៤ បានកំណត់ថា “ **មិនត្រូវចាត់ទុកជាបទល្មើសច្រើនបទទេ កាលណាបើអំពើទាំងឡាយដដែលៗនោះមានប្រភេទព្រហ្មទណ្ឌដូចគ្នា និងមិនត្រូវផ្តន្ទាទោសច្រើនបទនោះទេ** ”។ រីឯមាត្រា៥៤នៃក្រមព្រហ្មទណ្ឌជប៉ុនមានកំណត់ថា “ **កាលណាអំពើតែមួយបង្កើតបានជាបទឧក្រិដ្ឋពីរ ឬច្រើន ដាច់ដោយឡែកពីគ្នា ឬកាលណាអំពើមួយគឺជាមធ្យោបាយ ឬលទ្ធផលនៃបទឧក្រិដ្ឋមួយដែលបង្កើតបានជា បទឧក្រិដ្ឋមួយទៀតត្រូវផ្តន្ទាទោសធ្ងន់ជាងគេបំផុតដែលមានចែងពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងនេះ** ” ។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** បានសម្រេចប្រកាសតម្កល់ការដាក់ពិរុទ្ធភាពលើ **ឌុច** ពីបទធ្វើទុកបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសម្រេចបន្ថែមពិរុទ្ធភាពបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឲ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។ ផ្អែកទៅលើការសម្រេចដាក់ពិរុទ្ធភាព អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** បានសម្រេចផ្តន្ទាទោសលើ **ឌុច** ដាក់ពន្ធនាគារអស់មួយជីវិត។[11]

[11] អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក.** សាលដីកា (**កាំង ហ្កេចអ៊ាវ** ហៅ **ឌុច**) ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១២, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧, ទំព័រទី៥៦២ និង ៥៦៣ (ផ្នែកសម្រេចសេចក្តី)។

ដោយឡែកក្នុងរឿងក្តី០០២ ទាក់ទងទៅនឹងជនជាប់ចោទឈ្មោះ **នួន ជា** និង **ខៀវ សំផន** អង្គជំនុំជម្រះសាលាដំបូងនៃ **អ.វ.ត.ក.** បានលើកឡើងនូវទឡ្ហីករណ៍នៅក្នុងសាលដីកាក្នុងសំណុំរឿង០០១ របស់ **ឌុច** មកធ្វើជាទឡ្ហីករណ៍នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងនៃ **អ.វ.ត.ក.** យល់ឃើញថាក្នុងករណីដែលអំពើរបស់ជនជាប់ចោទបានបំពេញធាតុផ្សំបានជាបទល្មើសច្រើនផ្សេងគ្នា អង្គជំនុំជម្រះត្រូវវាយតម្លៃអំពីផលប៉ះពាល់នៃពិរុទ្ធពីបទល្មើសច្រើន។ ពិរុទ្ធពីបទល្មើសច្រើនមានតួនាទីបង្ហាញអំពីពិរុទ្ធភាពទាំងអស់របស់ជនជាប់ចោទណាមួយ ឬនៅក្នុងការផ្តល់នូវរូបភាពពេញលេញមួយដែលបង្ហាញពីបទល្មើសរបស់ជនជាប់ចោទរូបនេះ។ នៅពេលដែលអង្គជំនុំជម្រះបានរកឃើញពិរុទ្ធភាពពីបទល្មើសច្រើន ដែលមាននៅក្នុងបទល្មើសមូលដ្ឋានដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលកើតចេញពីអំពើសកម្ម ឬអសកម្ម ដូចគ្នារបស់ជនជាប់ចោទនោះ ការផ្តន្ទាទោសចំពោះបទល្មើសនីមួយៗ អាចធ្វើបានតែក្នុងករណីដែលបទល្មើសទាំងនោះមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ហើយដែលមិនមាននៅក្នុងបទល្មើសផ្សេងទៀត។ ប្រសិនបើបទល្មើសពីរត្រូវបានចោទប្រកាន់ដោយផ្អែកលើអំពើតែមួយ ដែលមិនមានធាតុផ្សំដាច់ដោយឡែកពីគ្នាទាំងស្រុងយ៉ាងតិចមួយទេនោះ អង្គជំនុំជម្រះអាចធ្វើការផ្តន្ទាទោសជនជាប់ចោទបាន តែចំពោះបទល្មើសណាដែលមានធាតុផ្សំជាក់លាក់ជាងមួយ ឬច្រើនតែប៉ុណ្ណោះ។ ក្នុងពេលអនុវត្តលក្ខណៈវិនិច្ឆ័យចំពោះការផ្តន្ទាទោសត្រួតគ្នា អង្គជំនុំជម្រះត្រូវតែប្រៀបធៀបទៅលើលក្ខខណ្ឌតម្រូវទូទៅទាំងអស់នៃបទល្មើសដែលមានចែងក្នុងច្បាប់ ព្រមទាំងធាតុផ្សំនៃបទល្មើសជាមូលដ្ឋាន ដែលត្រូវបានចោទប្រកាន់ដើម្បីសម្រេចថាតើតាមផ្លូវច្បាប់បទល្មើសនីមួយៗ តម្រូវឲ្យមានការបង្ហាញធាតុផ្សំមួយដែលបទល្មើសដទៃទៀតមិនមានដែរឬយ៉ាងណា។

អានុភាពនៃការរកឃើញពិរុទ្ធពីបទល្មើសច្រើននៅពេលផ្តន្ទាទោស បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង **អ.វ.ត.ក.** ច្បាប់ស្តីពីការបង្កើត **អ.វ.ត.ក.** និងវិធានផ្ទៃក្នុងមិនបានបង្ហាញថា តើអង្គជំនុំជម្រះអាចធ្វើការផ្តន្ទាទោសសរុបរួមតែមួយក្រោយពីបានរកឃើញពិរុទ្ធចំពោះបទល្មើសច្រើននៅពេលដែលពិរុទ្ធនីមួយៗ ផ្អែកទៅលើអំពើឧក្រិដ្ឋដាច់ដោយឡែកពីគ្នារបស់ជនជាប់ចោទនោះ។ ប៉ុន្តែទោះជាយ៉ាងណា អង្គជំនុំជម្រះធ្លាប់បានសម្រេចកន្លងមកថា អង្គជំនុំជម្រះអាចប្រកាសទោសសរុបតែមួយដែលឆ្លុះបញ្ចាំងពីអំពើឧក្រិដ្ឋរួមរបស់ ជនជាប់ចោទក្នុងករណីដែលជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន។

ដូច្នេះ យើងឃើញថាដំណោះស្រាយអំពីពិរុទ្ធភាពត្រួតគ្នា និងទោសដែលត្រូវប្រកាសក្នុងករណីនេះ ត្រូវបានត្រួសត្រាយផ្លូវដោយ **អ.វ.ត.ក.** នៅក្នុងសាលក្រម និងសាលដីកានៃសំណុំរឿង០០១ របស់ខ្លួន ហើយត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកមកធ្វើជាយុត្តិសាស្ត្រនៅក្នុងសំណុំរឿង០០២។ យុត្តិសាស្ត្រគួរណាស់តែដើរតួជាប្រភពមួយនៃនីតិព្រហ្មទណ្ឌកម្ពុជា ដោយសារថាក្រមព្រហ្មទណ្ឌកម្ពុជាមិនបានផ្តល់ជាដំណោះស្រាយណាមួយអំពីការកំណត់បទល្មើសត្រួតគ្នាដែលកើតចេញមកពីអំពើល្មើសតែមួយនោះទេ។

ក្រឡេកមកមើលយុត្តិសាស្ត្ររបស់តុលាការជាតិវិញ បើទោះបីជាមិនមានការបកស្រាយឲ្យបានក្បោះក្បាយក៏ដោយ នៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ៤៩(យ) ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ សាលាដំបូងខេត្ត

បាត់ដំបងបានធ្វើការសម្រេចប្រកាសអំពីពិរុទ្ធភាព ដែលកើតចេញអំពីល្មើសតែមួយ។ នៅក្នុងសាលក្រមរបស់ខ្លួនសាលាដំបូងខេត្តបាត់ដំបងបានលើកឡើងអំពីអង្គហេតុដូចតទៅៈ មានករណីគំរាមកំហែង និងប្រើប្រាស់អាវុធដោយខុសច្បាប់មួយបានកើតឡើងបង្កដោយឈ្មោះ **ក** បានធ្វើសកម្មភាពគម្រាមដោយយកគ្រាប់បែករកសម្លាប់ទៅលើឈ្មោះ **ខ** ដើម្បីទាមទារយកប្រាក់។ តុលាការបានលើកឡើងនូវទឡ្ហីករណ៍ច្បាស់លាស់អំពីធាតុផ្សំនៃបទគម្រាមកំហែង និងបទប្រើប្រាស់អាវុធដោយខុសច្បាប់ដែលធាតុផ្សំមានភាពដាច់ដោយឡែកពីគ្នា។

# ជំពូកទី២

# ជំពូកទី ២

# ការចោទប្រកាន់ និងវិធានអនុវត្តទោស

## ផ្នែកទី១. ការចោទប្រកាន់ជនល្មើស

បុគ្គលដែលបានជាប់សង្ស័យចំពោះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងត្រូវបានចាប់ឃាត់ខ្លួនមកឃុំឃាំងភ្លាមៗ ប្រសិនបើនគរបាលយុត្តិធម៌មានភស្តុតាង ឬសក្ខីកម្មផ្សេងៗគ្រប់គ្រាន់ ដែលអាចបញ្ជាក់អំពីទម្ងន់នៃការសង្ស័យនោះ។[12] ការឃាត់ខ្លួនត្រូវធ្វើឡើងក្នុងគោលបំណងផ្តល់តួនាទីឲ្យព្រះរាជអាជ្ញាសម្រេចចិត្តក្នុងការចោទប្រកាន់ ដើម្បីបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ បើកការស៊ើបសួរបន្ថែមស្វែងរកនូវហេតុការណ៍ពិត និងបញ្ជូនទៅតុលាការជំនុំជម្រះក្នុងសវនាការ។[13] ក្នុងករណីបទល្មើសត្រួតគ្នា ក្រមព្រហ្មទណ្ឌបានបែងចែកការចោទប្រកាន់ជា ២ប្រភេទធំៗ គឺ (កថាខណ្ឌទី១) ការចោទប្រកាន់តែមួយ និង(កថាខណ្ឌទី២) ការចោទប្រកាន់ដាច់ពីគ្នាដែលយើងនឹងសិក្សាលម្អិតអំពីនិយមន័យ និងលក្ខខណ្ឌសម្រាប់អនុវត្តក្នុងការចោទប្រកាន់នីមួយៗដូចខាងក្រោម។

### កថាខណ្ឌទី១. វិធានចោទប្រកាន់តែមួយ

#### ១.១. និយមន័យ

ការចោទប្រកាន់តែមួយ គឺសំដៅទៅដល់ការចោទប្រកាន់បទល្មើសច្រើនដែលប្រព្រឹត្តដោយបុគ្គលដដែលក្នុងលិខិតចោទប្រកាន់តែមួយ ដូចជាការចោទប្រកាន់បទល្មើសត្រួតគ្នានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែមួយ នៅក្នុងកំណត់ហេតុបង្ហាញខ្លួនភ្លាមតែមួយ ឬនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់តែមួយ។[14] ជារួមគេអាចឲ្យនិយមន័យបែបសាមញ្ញមួយទៀតបានថា ការចោទប្រកាន់ដាច់តែមួយ គឺជាការចោទប្រកាន់ចំពោះបទល្មើសច្រើនដែលប្រព្រឹត្តដោយបុគ្គលដដែល និងត្រូវព្រះរាជអាជ្ញាចោទប្រកាន់ក្នុងសំណុំរឿងតែមួយប៉ុណ្ណោះ។ បន្ថែមពីលើលក្ខណៈនិយមន័យខាងលើនេះ ការចោទប្រកាន់តែមួយក៏ត្រូវបានរាប់បញ្ចូលផងដែល ក្នុងករណីដូចខាងក្រោម៖[15]

**ករណីទី១៖** នៅក្នុងដំណាក់កាលស៊ើបសួរ ៖ (១) ចៅក្រមស៊ើបសួរបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីអយ្យការ សម្រាប់អង្គហេតុនៃបទល្មើសថ្មីផ្សេងទៀតដែលចៅក្រមស៊ើបសួរបានរកឃើញថា មានការពាក់ព័ន្ធនឹងជនត្រូវចោទហើយចៅក្រមស៊ើបសួរបានសម្រេចបិទការស៊ើបសួរតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ ។

---

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៩៧។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៧, ១២៧ និងមាត្រា២៤៧។

[14] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៧៤។

[15] ឯកសារជំនួយស្មារតីសម្រាប់ការស្វែងយល់ក្រមព្រហ្មទណ្ឌ រៀបចំដោយ ឯកឧត្តម **ហ៊ី សោភា** និងឯកឧត្តម **កើត រិទ្ធ**។

ដូចគ្នាផងដែរ (២) នៅក្នុងករណីដែលសភាស៊ើបសួរពន្លាតការស៊ើបសួររបស់ខ្លួនទៅដល់បទល្មើសពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិមាត្រា២៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបានបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន តាមសាលដីកាបញ្ជូនទៅជំនុំជម្រះសម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។

**ករណីទី២៖** នៅក្នុងពេលដែលតុលាការបានសម្រេច បញ្ចូលសំណុំរឿងព្រហ្មទណ្ឌច្រើនជាមួយគ្នា តាមមាត្រា២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយនៅក្នុងសំណុំរឿងទាំងនោះមានអង្គហេតុដែលអាចបង្កើតបានជាស្ថានភាពនៃបទល្មើសត្រួតគ្នា ។

## ១.២. ស្ថានភាពក្នុងការចោទប្រកាន់តែមួយ

យោងតាមបញ្ញត្តិមាត្រា៤៣ នៃក្រ.នី.ព្រ.ទ ព្រះរាជអាជ្ញាមានជម្រើសចំនួន ៣ សម្រាប់ធ្វើការចោទប្រកាន់ចំពោះបុគ្គលទាំងឡាយណា ដែលសង្ស័យថាមានពិរុទ្ធភាពក្នុងបទល្មើសរឿងព្រហ្មទណ្ឌ។ តាមរយៈនិយមន័យដែលបានរៀបរាប់ខាងលើ ស្ថានភាពការចោទប្រកាន់មួយអាចត្រូវបានកើតឡើងក្រោមទម្រង់ក្នុងនីតិវិធីដូចខាងក្រោម។

### ១.២.១. ការបញ្ជូនទៅចៅក្រមស៊ើបសួរ

#### ១.២.១.១. ការចោទប្រកាន់បទល្មើសបន្ថែម

យោងតាមមាត្រា៤៤ នៃក្រ.នី.ព្រ.ទ ព្រះរាជអាជ្ញាត្រូវតែបើកកិច្ចស៊ើបសួរប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ចំពោះបទឧក្រិដ្ឋដោយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរតាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ បន្ថែមពីនេះ មាត្រា៤៥ នៃក្រ.នី.ព្រ.ទ ព្រះរាជអាជ្ញាក៏អាចបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរបានដែរ នៅពេលមានបទមជ្ឈឹមដែលមានលក្ខណៈស៊ាំញ៉ាំ និងត្រូវការប្រមូលភស្តុតាងបន្ថែម ទើបអាចបញ្ជូនទៅជំនុំជម្រះក្តីបាន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចនឹងស្វែងរកឃើញអង្គហេតុព្រហ្មទណ្ឌពីមុនរបស់ជនល្មើស និងត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាឲ្យបានលឿនអំពីការរកឃើញ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់បទល្មើសដែលបានរកឃើញថ្មី។[16] ប្រសិនបើព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បន្ថែមពីសំណុំរឿងចាស់នោះបទល្មើសត្រួតគ្នានឹងកើតឡើងតាមរយៈ (ករណីទី១ និងចំណុច១.១.) ខាងលើ។

#### ១.២.១.២. ការចោទប្រកាន់បទល្មើសត្រួតគ្នាតែម្តង

ក្រៅពីករណីដែលបានរៀបរាប់ខាងលើ សំណុំរឿងខ្លះព្រះរាជអាជ្ញាធ្វើឆន្ទានុសិទ្ធិ

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២៥។

ចោទប្រកាន់បទល្មើសត្រួតគ្នាប្រឆាំងនឹងបុគ្គលល្មើសច្បាប់តែម្តង បន្ទាប់ពីបានពិនិត្យនិងវាយតម្លៃយ៉ាងជាក់ច្បាស់នូវចម្លើយសារភាពចំពោះភស្តុតាងដែលប្រមូលបានក្នុងកំណត់ហេតុប្រតិបត្តិការបង្ក្រាបរបស់មន្ត្រីនគរបាលយុត្តិធម៌។ ស្ថានភាពនេះ ការចោទប្រកាន់បទល្មើសត្រួតគ្នាប្រឆាំងនឹងបុគ្គលខាងលើ នឹងត្រូវបានចាត់ទុកជាការចោទប្រកាន់តែមួយតែម្តង។

### ១.២.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជានីតិវិធីមួយក្នុងការចោទប្រកាន់បទល្មើសរបស់ព្រះរាជអាជ្ញា ដោយបង្គាប់ឲ្យនាំខ្លួនជនសង្ស័យចូលមកបង្ហាញខ្លួននៅតុលាការជាន់ដំបូងដែលសម្រេចរឿងក្តីព្រហ្មទណ្ឌនៅក្នុងរយៈពេលដែលបានកំណត់ជាកំហិត ដោយគិតចាប់ពីថ្ងៃទទួលបានដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។[17] ការជំនុំជម្រះផ្ទាល់នេះ អាចយកទៅអនុវត្តបានតែក្នុងបទមជ្ឈឹមដែលមានលក្ខណៈអាចជំនុំជម្រះបាន និងបទលហុតែប៉ុណ្ណោះ។[18] នៅក្នុងនីតិវិធីនេះ ស្ថានភាពការចោទប្រកាន់តែមួយ អាចត្រូវបានកើតឡើងក្នុងករណី៖

#### ១.២.២.១. ការរកឃើញបទល្មើសថ្មី ក្នុងពេលជនុំជម្រះផ្ទាល់

នៅដំណាក់កាលជំនុំជម្រះ ដែលជនជាប់ចោទត្រូវតែចូលទៅសវនាការតាមមាត្រា៣០២ នៃក្រ.នី.ព្រ.ទ និងបានចូលរួមដដែកដេញដោលក្នុងសវនាការជម្រះក្តី តុលាការបានរកឃើញថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសម្តងរួចហើយ ប៉ុន្តែពុំទាន់បានផ្តន្ទាទោសនោះទេ។ ប្រសិនបើជនជាប់ចោទបានរកឃើញថាពិតជាជនល្មើសក្នុងអង្គហេតុរកឃើញថ្មី ហើយអង្គហេតុទាំង២ ដែលប្រព្រឹត្តមានការជាប់ពាក់ព័ន្ធគ្នា តុលាការអាចប្រកាសបញ្ចូលជាសំណុំរឿងចោទប្រកាន់តែមួយបានតាមដូចមានបញ្ជាក់ក្នុង (ករណីទី២ និងចំណុច ១.១.) ខាងលើ។

#### ១.២.២.២ ការចោទប្រកាន់បទល្មើសត្រួតគ្នាតែម្តង

ព្រះរាជអាជ្ញាសម្រេចចោទប្រកាន់បទល្មើសត្រួតគ្នា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង បន្ទាប់ពីបានពិនិត្យមើលចម្លើយសារភាព ភស្តុតាង និងកំណត់ហេតុបង្ក្រាបបទល្មើសរបស់មន្ត្រីនគរបាលថ្មី ឬកំណត់ហេតុពីមុនរបស់ជនជាប់ចោទដែលពុំបានទទួលការផ្តន្ទាទោស។ ប៉ុន្តែការចោទប្រកាន់នេះ អាចអនុវត្តទៅបានលុះត្រាតែបទល្មើសទី១ មិនស្ថិតក្នុងការផុតអាជ្ញាយុកាលនៃបទល្មើស ឬហេតុផ្សេងៗដែលនាំឲ្យរលត់បណ្តឹងអាជ្ញាជាដើម។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤ , ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៣,៤៥៧ និងមាត្រា៤៥៧។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤ , ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៥, ៤៦ និងមាត្រា៤៩។

#### ១.២.៣. នីតិវិធីបង្ហាញខ្លួនភ្លាម

វិធីចោទប្រកាន់បទល្មើសត្រួតគ្នាក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម ពុំមានលក្ខណៈខុសពីការបញ្ជូនទៅជំនុំជម្រះផ្ទាល់នោះទេ។ យោងតាមមាត្រា៤៧ នៃក្រ.នី.ព្រ.ទ ការបង្ហាញខ្លួនភ្លាមអាចយកទៅអនុវត្តបានចំពោះតែបទឧក្រិដ្ឋជាក់ស្តែង ឬបទមជ្ឈឹមជាក់ស្តែង (**ទោសអាចដាក់ពន្ធនាគារយ៉ាងតិចត្រឹម ១ឆ្នាំ និងច្រើនបំផុតត្រឹម៥ឆ្នាំ**) ដែលប្រព្រឹត្តដោយបុគ្គលជានីតិភាព និងសំណុំរឿងមានលក្ខណៈអាចជំនុំជម្រះបានតែប៉ុណ្ណោះ។ បន្ថែមពីនេះ ការចោទប្រកាន់តែមួយអាចត្រូវបានចាត់ទុកផងដែរ ករណីសំណុំរឿងដែលបានបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមនោះមានភាពស្មុំញាំពុំទាន់អាចជំនុំជម្រះភ្លាមៗបាន តុលាការត្រូវលើកសំណុំរឿងបញ្ជូលទៅសវនាការនៅពេលក្រោយ។[19] ក្នុងកំឡុងពេលនោះ ព្រះរាជអាជ្ញាអាចតួនាទីប្រើប្រាស់អំណាចខ្លួនបើកការស៊ើបអង្កេតដោយប្រតិបត្តិតាមមាត្រា៤៤ នៃក្រ.នី.ព្រ.ទ ដើម្បីបំពេញចំណុចភស្តុតាងដែលខ្វះខាត។ នៅក្នុងកិច្ចបើកការស៊ើបសួរ ព្រះរាជអាជ្ញាអាចស្វែងរកឃើញពិរុទ្ធភាពបន្ថែមដែលបង្កើតទៅជាស្ថានភាពបទល្មើសត្រួតគ្នាក្នុងការចោទប្រកាន់តែមួយដូចបានរៀបរាប់ក្នុង (ករណីទី១)។

## កថាខណ្ឌទី២. វិធានចោទប្រកាន់ដាច់ពីគ្នា

### ២.១. និយមន័យ

មានលក្ខណៈខុសពីការចោទប្រកាន់តែមួយបន្តិច ការចោទប្រកាន់ដាច់ពីគ្នា គឺសំដៅទៅដល់ការចោទប្រកាន់លើបុគ្គលដែលបានប្រព្រឹត្តបទល្មើសជាច្រើនក្នុងលិខិតចោទប្រកាន់ពីរ ឬច្រើនដាច់ពីគ្នា ឬការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ពីរ ឬច្រើនដាច់ពីគ្នា ឬកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមពីរ ឬច្រើនដាច់ពីគ្នា។[20] ការចោទប្រកាន់ដាច់ពីគ្នាត្រូវបានរាប់បញ្ចូលផងដែរ កាលណាមាន ការបំបែកសំណុំរឿងមួយទៅជាសំណុំរឿងពីរ ឬច្រើនដាច់ពីគ្នាដោយយុត្តាធិការជំនុំជម្រះ។ និយាយជារួមគេអាចឲ្យនិយមន័យបានម៉្យាងទៀតថា ការចោទប្រកាន់ដាច់ពីគ្នា គឺជាការចោទប្រកាន់បទល្មើសត្រួតគ្នាចំពោះបុគ្គលដដែល នៅក្នុងសំណុំរឿងពីរ ឬច្រើនដាច់ដោយឡែកពីគ្នា ឬជាសំណុំរឿងអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះដាច់ដោយឡែកពីគ្នា។

### ២.២. ការចោទប្រកាន់បទល្មើស

#### ២.២.១. ការចោទប្រកាន់ទូទៅ

ការចោទប្រកាន់ដាច់ដោយឡែក ធ្វើឡើងដោយមានជម្រើសចោទប្រកាន់ដូចគ្នាទៅនឹងការចោទប្រកាន់តែមួយ គឺព្រះរាជអាជ្ញាអាចចោទប្រកាន់តាមនីតិវិធីចំនួន ៣ប្រភេទ ដែលមានការបើកការស៊ើបសួរ ការបញ្ជូន

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៨ កថាខណ្ឌទី៨។

[20] សៀវភៅស្តីពីបទល្មើសត្រួតគ្នា រៀបរៀងដោយលោក **ចក សម្បត្តិ** ទំព័រទី៧០ កថាខណ្ឌទី៧៦។

ទៅជំនុំជម្រះផ្ទាល់ និងនីតិវិធីបង្ហាញខ្លួនភ្លាម។[21] ប៉ុន្តែរបៀបនៃការចោទប្រកាន់វិញ គឺមានលក្ខណៈផ្ទុយគ្នា ការចោទប្រកាន់ដាច់ពីគ្នា គឺសំដៅលើនីតិវិធីចោទប្រកាន់បុគ្គលដដែលក្នុងសំណុំរឿងពីរ ឬច្រើនផ្សេងគ្នា មានន័យថា សំណុំរឿងបានបំបែកចេញច្រើនជាងមួយ ដែលផ្ទុយក្នុងការចោទប្រកាន់តែមួយសំណុំរឿងត្រូវបញ្ចូលគ្នាតែវិញ។ នៅគ្រប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នា ព្រះរាជអាជ្ញាបានសម្រេចចិត្តចោទប្រកាន់សំណុំរឿងនោះដាច់ដោយឡែកពីគ្នា ដោយមូលហេតុពិសេសណាមួយ។ ករណីខ្លះការចោទប្រកាន់ដាច់ពីគ្នា អាចត្រូវបានធ្វើឡើងដោយតម្រូវទៅលើនីតិវិធីចោទប្រកាន់ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ជាធរមាន មានន័យថាទោះបីជាសំណុំរឿងអាចបើកការចោទប្រកាន់តែមួយបានក៏ដោយ ប្រសិនបើនីតិវិធីច្បាប់តម្រូវជាចាំបាច់ ការចោទប្រកាន់ត្រូវតែធ្វើដាច់ដោយឡែកពីគ្នា។

**ឧទាហរណ៍ទី១៖** ចៅក្រមស៊ើបសួរបានស្វែងរកឃើញអង្គហេតុបទមជ្ឈិមថ្មីបន្ថែមពីលើបទមជ្ឈិមចាស់ដែលព្រះរាជអាជ្ញាបានចោទប្រកាន់រួចហើយ។ ក្នុងនោះចៅក្រមស៊ើបបានជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការរកឃើញអង្គហេតុបន្ថែមនោះ។ ដោយសិក្សាអំពីអង្គហេតុទាំង២រួច ព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ក្នុងសំណុំរឿងថ្មីវិញ ដោយមិនជ្រើសយកការចោទប្រកាន់បន្ថែមឡើយ។ ហេតុនេះ សំណុំរឿងក្នុងឧទាហរណ៍នេះត្រូវបានកំណត់ថាជាការចោទប្រកាន់ដាច់ពីគ្នា។

**ឧទាហរណ៍ទី២៖** ចៅក្រមស៊ើបសួរបានទទួលបន្ទុកស៊ើបសួរបទឧក្រិដ្ឋតាមការប្តឹងសុំរបស់ព្រះរាជអាជ្ញា ក្នុងគ្រានោះ ចៅក្រមស៊ើបសួរបានរកឃើញអង្គហេតុថ្មីជាបទលហុចំនួន ១ករណីដែលជនល្មើសបានប្រព្រឹត្តមុនពេលប្រព្រឹត្តបទល្មើសឧក្រិដ្ឋចំនួន ១ខែប៉ុណ្ណោះ។

ក្នុងសំណុំរឿងនេះ ព្រះរាជអាជ្ញាត្រូវបានតម្រូវឲ្យចោទប្រកាន់ដាច់ពីគ្នាតែម្តង ដោយមូលហេតុថាក្នុងនីតិវិធីចោទប្រកាន់ដោយបើកការស៊ើបសួរ គេអាចអនុវត្តបានតែក្នុងបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមតែប៉ុណ្ណោះ។[22] ករណីបទលហុមិនអាចអនុវត្តការចោទប្រកាន់ដោយបើកការស៊ើបសួរបានទេ ការចោទប្រកាន់អាចធ្វើទៅបានតែតាមនីតិវិធីបញ្ជូលទៅជំនុំជម្រះផ្ទាល់តែមួយប៉ុណ្ណោះ។[23] ហេតុនេះ ព្រះរាជអាជ្ញាត្រូវចោទប្រកាន់សំណុំរឿងដាច់ពីគ្នា ដោយចោទប្រកាន់សំណុំរឿងបទឧក្រិដ្ឋមួយករណី និងចោទប្រកាន់បទលហុមួយករណី ដែលបញ្ញត្តិកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.២.២. ការឆ្លងដែនសមត្ថកិច្ចតុលាការ

ការចោទប្រកាន់ដាច់ពីគ្នាក៏ត្រូវបានរាប់បញ្ចូលផងដែរ ក្នុងករណីបុគ្គលដែលព្រះរាជអាជ្ញាចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្នុងតំបន់សមត្ថកិច្ចតុលាការខេត្ត-ក្រុងណាមួយ ហើយត្រូវបានស្វែករកឃើញថា

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៣។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៤។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៩។

បុគ្គលដដែលនោះ ធ្លាប់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌក្នុងតំបន់សមត្ថកិច្ចរបស់តុលាការខេត្ត-ក្រុងមួយផ្សេងទៀត មុនត្រូវបានសមត្ថកិច្ចចាប់ខ្លួនបទល្មើសក្រោយ។ ជាលក្ខណៈសម្រាប់យុត្តិសាស្ត្រក្នុងការដោះស្រាយវិវាទសមត្ថកិច្ចរបស់តុលាការ ពិរុទ្ធជននឹងត្រូវបញ្ជូនទៅតុលាការដែលមានសមត្ថកិច្ចចំពោះអង្គហេតុរកឃើញថ្មី ដើម្បីធ្វើការចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ។ រួមមកត្រូវបញ្ជូនទៅជំនុំជម្រះនៅតុលាការដែលមានសមត្ថកិច្ចចំពោះអង្គហេតុ នៃបទល្មើសក្រោយបានប្រកាសផ្តន្ទាទោសបទល្មើសមុនបានចូលជាស្ថាពររួចហើយ។ ក្នុងន័យនេះ គេអាចបកស្រាយសាមញ្ញបានថា បុគ្គលដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពីរ ឬច្រើនដងក្នុងទីតាំងនៃសមត្ថកិច្ចរបស់តុលាការរាជធានីខេត្តផ្សេងគ្នា ត្រូវនឹងបានចាត់ទុកជា **ការចោទប្រកាន់ដាច់ពីគ្នាដោយស្វ័យប្រវត្តិតែម្តង** ឬហៅម៉្យាងទៀតបានថា **ការអនុវត្តនីតិវិធីផ្តន្ទាទោសបុគ្គលតែម្នាក់ក្នុងសំណុំរឿងផ្សេងគ្នា**។

**ឧទាហរណ៍**៖ នៅឆ្នាំ២០២៣ លោក **ក** បានប្រព្រឹត្តបទល្មើសលួចមានស្ថានទម្ងន់ទោសតាមមាត្រា ៣៥៧ នៃក្រ.ព្រ.ទ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ រយៈពេល ១ឆ្នាំក្រោយមក គាត់បានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈតាមមាត្រា២៣៩ នៃក្រ.ព្រ.ទ នៅខេត្តសៀមរាបបន្ថែមមួយករណីទៀត។ ហេតុនេះនាំឲ្យបទល្មើសទាំង២ ដែលគាត់បានប្រព្រឹត្តស្ថិតក្នុងនីតិវិធីការចោទប្រកាន់ដាច់ពីគ្នានៃបទល្មើសត្រួតគ្នា។

## ផ្នែកទី២. ការអនុវត្តវិធានប្រកាសទោស

ការប្រកាសទោសនៅពេលមានបទល្មើសត្រួតគ្នា ត្រូវធ្វើឡើងមានលក្ខណៈខុសគ្នាពីការប្រកាសទោសទូទៅនិងការប្រកាសទោសចំពោះបទល្មើសមិនរាងចាល។ ប្រសិនបើបុគ្គលណាមួយត្រូវបានរកឃើញថា មានពិរុទ្ធភាពពីបទល្មើសត្រួតគ្នា ទោះបីជាការចោទប្រកាន់តែមួយ ឬដាច់ពីគ្នា តុលាការត្រូវផ្តន្ទាទោសបុគ្គលនោះតាមវិធានបទល្មើសត្រួតគ្នាជាស្វ័យប្រវត្តិ ដោយមិនអាចប្រកាសដូចទោសទូទៅបានឡើយ។ នៅក្នុងវិធានបទល្មើសត្រួតគ្នានីតិនិពន្ធបានបែកចែកវិធានត្រូវអនុវត្តទោសចំនួន ៣ រួមមានការស្រូបទោស (កថាខណ្ឌទី១) វិធានត្រួតទោស (កថាខណ្ឌទី២) និងវិធានបូកទោសពិន័យលហុ និងទោសរត់គេចពីពន្ធនាគារ (កថាខណ្ឌទី៣)។

### កថាខណ្ឌទី១. វិធានស្រូបទោស

តុលាការធ្វើឆន្ទានុសិទ្ធិក្នុងការជ្រើសរើសវិធានអនុវត្តទោសណាមួយក្នុងចំណោមវិធានទាំង៣ មកប្រកាសទោសលើបទល្មើសត្រួតគ្នា។ ក្នុងចំណោមនោះក៏មានវិធានស្រូបទោសផងដែរ ប្រសិនបើបទល្មើសបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមផ្លូវច្បាប់ដែលកំណត់អំពីវិធាននេះ។ វិធានស្រូបទោសអាចយកទៅអនុវត្តបានទាំងក្នុងសំណុំរឿងការចោទប្រកាន់តែមួយ និងសំណុំរឿងការចោទប្រកាន់ដាច់ពីគ្នា ទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់។ វិធាននេះ ត្រូវបានបញ្ញត្តិឡើងសម្រាប់សម្រាលទោសដល់ពិរុទ្ធជន ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ និងមនុស្សធម៌។

ដើម្បីអាចសិក្សាបានកាន់តែលម្អិត និងស៊ីជម្រៅអំពីវិធានស្រូបទោស យើងនឹងសិក្សាវិធាននេះម្តងមួយៗ ទាំងនៅក្នុងការចោទប្រកាន់តែមួយ (១.១.) និងក្នុងសំណុំរឿងចោទប្រកាន់ដាច់ពីគ្នា (១.២.)។

### ១.១. វិធានស្រូបទោសតាមបញ្ញត្តិមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ

យោងតាមមាត្រា ១៣៧ នៃក្រ.ព្រ. បានបញ្ញត្តិថា “ **បុគ្គលដែលប្រព្រឹត្តបទល្មើសច្រើននឹងត្រូវចោទប្រកាន់នៅក្នុងលិខិតចោទប្រកាន់តែមួយ តុលាការត្រូវសម្រេចប្រកាសទោសដែលមានលក្ខណៈដូចគ្នាជាទោសរួម នៃបទល្មើសទាំងអស់ ដោយមិនឲ្យលើសពីព្រំដែននៃអតិបរមាស្របច្បាប់ដែលបានកំណត់ឡើយ** ” ។ មានន័យថា បុគ្គលណាមួយដែលត្រូវបានរកឃើញថាមានពិរុទ្ធភាពក្នុងសំណុំរឿងការចោទប្រកាន់តែមួយ តុលាការត្រូវអនុវត្តវិធានស្រូបទោសចំពោះបុគ្គលនេះដោយស្វ័យប្រវត្តិតែម្តង ដោយពុំចាំបាច់មានលិខិតស្នើសុំស្រូបទោសឡើយ។[24] តុលាការត្រូវថ្លឹងថ្លែងអំពើប្រព្រឹត្តបទល្មើសនីមួយៗដោយម៉ត់ចត់ដើម្បីវាយតម្លៃព្យសនកម្មសង្គម និងប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចជ្រើសរើសទោសក្នុងចំនួនណាមួយ យកមកប្រកាសជាទោសរួមចំពោះបទល្មើសទាំងអស់ពិរុទ្ធជនបានប្រព្រឹត្ត។[25] តុលាការត្រូវតែកំណត់ចំនួនទោសរួម ដោយមិនឲ្យលើសពីព្រំដែនអតិបរមាស្របច្បាប់នៃបទល្មើសណាមួយដែលពិរុទ្ធជនបានប្រព្រឹត្តឡើយ។

**ឧទាហរណ៍៖** បុគ្គលម្នាក់ប្រព្រឹត្តបទល្មើសដូចជា៖

១. បទរំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រ.ព្រ.ទ. ត្រូវផ្តន្ទាទោសពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។

២. បទលួច តាមមាត្រា ៣៥៧ នៃក្រ.ព្រ.ទ. ត្រូវផ្តន្ទាទោសពន្ធនាគារពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

៣. បទបំផ្លាញទ្រព្យអ្នកដទៃដោយចេតនា តាមមាត្រា៤១០ នៃក្រ.ព្រ.ទ. ត្រូវផ្តន្ទាទោសពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន ទៅ ២លានរៀល។

នៅក្នុងឧទាហរណ៍នេះ ឧបមាថា តុលាការបានសម្រេចផ្តន្ទាទោស៖

១. បទរំលោភសេពសន្ថវៈ ផ្តន្ទាទោសពន្ធនាគារចំនួន ៨ឆ្នាំ។

២. បទលួច ផ្តន្ទាទោសពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យ ៥លានរៀល។

៣. បទបំផ្លាញទ្រព្យអ្នកដទៃដោយចេតនា ផ្តន្ទាទោសពន្ធនាគារចំនួន ១ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ចំនួន ២លានរៀល។

យោងតាមខ្លឹមសារមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ បានបកស្រាយថា “ **តុលាការត្រូវប្រកាសទោសតែមួយ ចំពោះប្រភេទទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ នៅក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់**

[24] សៀវភៅស្តីពីបទល្មើសត្រួតគ្នា រៀបរៀងដោយ លោក **ចក់ សម្បត្តិ** ទំព័រ៥៨ កថាខណ្ឌទី៦៩ វាក្យកណ្ឌទី២។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤០។

**ជាងគេ** ” ។ តាមរយៈនេះ តុលាការអាចប្រកាសទោសចំពោះបទល្មើសទាំង ៣ខាងលើ ដោយផ្តន្ទាទោសពន្ធនាគារជាអតិបរមាចំនួន ១០ឆ្នាំ (ព្រំដែនអតិបរមាទោសពន្ធនាគារនៃបទរំលោភសេពសន្ថវៈ) និងផ្តន្ទាទោសពិន័យជាប្រាក់អតិបរមាចំនួន ៦លានរៀល (ព្រំដែនអតិបរមាទោសពិន័យជាប្រាក់នៃបទលួច) តែប៉ុណ្ណោះ។ ទោះបីជាផលបូកទោសពន្ធនាគារ និងទោសពិន័យជាប្រាក់នៃបទរំលោភសេពសន្ថវៈ, បទលួច និងបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃដោយចេតនា មានទោសពន្ធនាគារចំនួន ១១ឆ្នាំ និងទោសពិន័យជាប្រាក់ចំនួន ៧លានរៀលក៏ដោយ។ ម្យ៉ាងវិញទៀត ទោសដាក់ពន្ធនាគារ ១០ឆ្នាំ និងទោសពិន័យជាប្រាក់ចំនួន ៦លានរៀលដែលតុលាការប្រកាសនោះ ត្រូវចាត់ទុកថាជាទោសរួមចំពោះបទល្មើសត្រួតគ្នានៅក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ដោយអនុវត្តទៅលើបទល្មើសទាំង៣ ខាងលើ។

ការអនុវត្តវិធានបែបនេះ ត្រូវចាត់ទុកថាជាការស្រូបទោសក្នុងការចោទប្រកាន់តែមួយនៃបទល្មើសត្រួតគ្នា។ មួយវិញទៀត យោងតាមការបកស្រាយមាត្រា៩ នៃក្រ.ព្រ.ទ. ប្រសិនបើក្នុងកំឡុងពេលទណ្ឌិតកំពុងអនុវត្តទោស បទល្មើសដែលតុលាការបានសម្រេចកំណត់ជាព្រំដែនអតិបរមានៃទោសនោះ ត្រូវបានបញ្ញត្តិក្រមព្រហ្មទណ្ឌថ្មីលុបចោល ឬលែងចាត់ទុកថាជាបទល្មើស ទណ្ឌិតនឹងអនុវត្តទោសដោយទទួលបានការបន្ធូរបន្ថយចំនួនទោសដែលបានប្រកាសពីមុន មកត្រឹមទោសដែលនៅតែចាត់ទុកថាជាបទល្មើសវិញ ពោលគឺទោសក្នុងបទល្មើសដែលច្បាប់ថ្មីបានប្រកាសលុបចោលហើយ ពុំមានអនុភាពក្នុងការអនុវត្តទេ។

**ឧទាហរណ៍**៖ ប្រសិនបើបទល្មើសរំលោភសេពសន្ថវៈខាងលើ លែងត្រូវបានចាត់ទុកជាបទល្មើសទៀតហើយ។ នោះទោសដាក់ពន្ធនាគារដែលកំណត់ជាទោសរួមក្នុងព្រំដែនអតិបរមាស្របច្បាប់នៃបទរំលោភសេពសន្ថវៈ ត្រូវបន្ថយទោសរួមមកត្រឹមព្រំដែនអតិបរមាស្របច្បាប់នៃបទល្មើសលួចវិញ ដែលត្រូវដាក់ឲ្យជាប់ពន្ធនាគារយ៉ាងយូរបំផុត ៣ឆ្នាំប៉ុណ្ណោះ។ ក្នុងករណីដែលទណ្ឌិតបានអនុវត្តទោសក្នុងពន្ធនាគារស្មើ ឬលើស ៣ឆ្នាំ ទណ្ឌិតនឹងត្រូវបានដោះលែងឲ្យមានសេរីភាពចូលទៅរស់នៅក្នុងសង្គមវិញតែម្តង។[26]

## ១.២. វិធានស្រូបទោសតាមបញ្ញត្តិមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ

វិធានស្រូបទោសនៅក្នុងការចោទប្រកាន់ដាច់ពីគ្នា បានផ្តល់គោលការណ៍ប្រកាសទោសមួយសម្រាប់តុលាការចុងក្រោយធ្វើការថ្លឹងថ្លែងព្យសនកម្មដែលបណ្តាលមកពីបទល្មើសពីរ ឬច្រើនដែលបុគ្គលបានប្រព្រឹត្ត។ តាមរយៈក្រមព្រហ្មទណ្ឌ វិធានស្រូបទោសក្នុងការចោទប្រកាន់តែមួយ និងការចោទប្រកាន់ដាច់ពីគ្នា មាននីតិវិធីសម្រាប់អនុវត្តខុសគ្នា ដោយក្នុងការចោទប្រកាន់តែមួយ តុលាការត្រូវមានកាតព្វកិច្ចស្រូបចំពោះទោសដែលមានប្រភេទដូចគ្នា ប៉ុន្តែនៅក្នុងការចោទប្រកាន់ដាច់ពីគ្នាវិញ តុលាការមិនមានកាតព្វកិច្ចប្រកាសស្រូបទោសនោះទេ។[27] គេអាចប្រកាសស្រូបទោសបានលុះត្រាតែព្រះរាជអាជ្ញា ឬភាគីពាក់ព័ន្ធបានស្នើសុំស្រូបទោសទៅកាន់

[26] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **វុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៧៨។

[27] សៀវភៅស្តីពីបទល្មើសត្រួតគ្នា រៀបរៀងដោយលោក **ចក សម្បត្តិ** ទំព័រទី ៧៣ និង៧៤ កថាខណ្ឌទី៨០។

តុលាការ។[28] ក្នុងករណីនេះ តុលាការធ្វើឆន្ទានុសិទ្ធិតាមសតិសម្បជញ្ញៈរបស់ខ្លួនក្នុងការប្រកាសស្រូបទោសក៏បាន ឬមិនស្រូបទោសក៏បាន ប៉ុន្តែបើតុលាការសម្រេចប្រកាសមិនស្រូបទោសទេ តុលាការត្រូវប្រកាសវិធានត្រួតទោសជំនួសឲ្យការស្រូបទោសវិញ។ ម៉្យាងវិញទៀត ប្រសិនបើតុលាការសម្រេចប្រកាសស្រូបទោស តុលាការក៏ត្រូវពិចារណាផងចំពោះការស្រូបទោសទាំងមូល និងស្រូបតែមួយផ្នែកចូលទៅក្នុងទោសដែលមានចំនួនធំជាង។ ការស្រូបទោសអាចយកទៅអនុវត្តបានចំពោះមូលទោស (ទោសពន្ធនាគារ និងទោសពិន័យជាប្រាក់) ទោសជំនួស (ការងារសហគមន៍ និងទោសស្ដីបន្ទោស) ឬទោសបន្ថែមដែលមានប្រភេទដូចគ្នាតែប៉ុណ្ណោះ មិនអាចយកទៅអនុវត្តចំពោះទោសដែលមានប្រភេទខុសគ្នាបានទេ។[29]

### ១.២.១. ការស្រូបទោសទាំងមូល

តុលាការអាចប្រកាសពីការស្រូបទោសទាំងមូល ឬមួយផ្នែកបានដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់ជនល្មើសនិងគោលការណ៍ឯកត្តកម្មនៃទោសដែលបញ្ញត្តិទុកក្នុងមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ។ នៅក្នុងសំណុំរឿងចោទប្រកាន់ដាច់ពីគ្នា ច្បាស់ណាស់នឹងមានការសម្រេចផ្តន្ទាទោសពិរុទ្ធជននូវសាលក្រមនៃតុលាការផ្សេងៗគ្នា ដែលមានកម្រិតទោសខុសៗគ្នាទៅតាមបទល្មើសដែលបានប្រព្រឹត្ត។ កាលនេះ ប្រសិនបើតុលាការចុងក្រោយសម្រេចប្រកាសស្រូបទោសទាំងមូលតែម្តង នោះជនជាប់ចោទពុំចាំបាច់អនុវត្តទោសដែលមានចំនួនតូចជាងនោះទេ ពោលគឺទោសដែលមានចំនួនធំជាងនឹងស្រូបទោសដែលមានចំនួនតូចជាងបញ្ចូលគ្នា។[30]

**ឧទាហរណ៍**៖ លោក **ក** ត្រូវបានតុលាការសម្រេចក្នុងសំណុំរឿងទី១ ផ្តន្ទាទោសជាប់ពន្ធនាគារ ១ឆ្នាំកន្លះពីបទធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃតាមមាត្រា៤១០ នៃក្រ.ព្រ.ទ. ដែលមានអតិបរមាទោសចំនួន ២ឆ្នាំ។ ក្រោយពីសំណុំរឿងទី១ បានចូលជាស្ថាពរ តុលាការបានប្រកាសផ្តន្ទាទោសក្នុងសំណុំរឿងទី២ ជាប់ពន្ធនាគារចំនួន ៤ឆ្នាំពីបទសញ្ជារកម្ម តាមមាត្រា២៨៤ នៃក្រ.ព្រ.ទ. ដែលមានអតិបរមាទោសចំនួន ៥ឆ្នាំ។

បទល្មើសត្រួតគ្នាក្នុងឧទាហរណ៍ខាងលើ តំណាងអយ្យការ ឬភាគីពាក់ព័ន្ធអាចដាក់ពាក្យប្តឹងស្នើសុំស្រូបទោសទៅតុលាការចុងក្រោយដែលជាអ្នកមានសមត្ថកិច្ចសម្រេចក្នុងសំណុំរឿងទី២ ពីបទសញ្ជារកម្មបាន។ ប្រសិនបើតុលាការសម្រេចឆន្ទានុសិទ្ធិ ដោយប្រកាសស្រូបទោសទាំងមូលតាមការស្នើសុំរបស់ភាគីខាងលើនោះមានន័យថាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ពីបទធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ នឹងត្រូវស្រូបបញ្ចូលទាំងស្រុងទៅក្នុងទោសនៃបទសញ្ជារកម្មដែលមានចំនួន ៤ឆ្នាំ។ ការស្រូបនេះនឹងធ្វើឲ្យលោក **ក** ត្រូវអនុវត្តទោសក្នុងពន្ធនាគារបានតិចជាងការមិនទាន់ស្រូបទោស គឺលោក **ក** ត្រូវអនុវត្តទោសពន្ធនាគារតែចំនួន ៤ឆ្នាំប៉ុណ្ណោះចំពោះការប្រព្រឹត្តបទល្មើសចំនួន ២លើកខាងលើ ដែលចំនួននេះខុសពីការសម្រេចចិត្តមិនស្រូបទោសរបស់តុលាការដោយត្រូវអនុវត្តទោសចំនួន ៥ឆ្នាំ (អតិបរមាបទសញ្ជារកម្ម)។ ដូច្នេះ ការអនុវត្តវិធានស្រូបទោសទាំងមូល បានធ្វើឲ្យលោក **ក**

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥០១។

[29] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៨១។

[30] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៨៤។

ចំណោញរយៈពេលអនុវត្តទោសក្នុងពន្ធនាគារបានចំនួន ១ឆ្នាំ ប្រសិនបើតុលាការសម្រេចមិនប្រកាសយកវិធានត្រួតទោសមកអនុវត្ត។

ពាក្យថា **តុលាការចុងក្រោយ គឺចង់មានន័យសំដៅទៅលើសាលាជំនុំជម្រះក្ដីដែលមានសមត្ថកិច្ចវិនិច្ឆ័យបទល្មើស និងចេញសេចក្ដីសម្រេចចុងក្រោយគេ ដោយរាប់បញ្ចូលទាំងសាលាក្ដីជាន់ទាបគឺ សាលាដំបូងរាជធានីខេត្ត និងសាលាក្ដីជាន់ខ្ពស់ គឺសាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូលផងដែរ។**

**ឧទាហរណ៍**៖ នៅឆ្នាំ ២០១៩ សាលាដំបូងរាជធានីភ្នំពេញសម្រេចផ្ដន្ទាទោសបុគ្គលម្នាក់ដាក់ពន្ធនាគារចំនួន ១ឆ្នាំ ពីបទឆបោក ។ បន្ទាប់មកទៀត នៅក្នុងឆ្នាំ ២០២០ បុគ្គលដដែលនេះ ត្រូវបានសាលាដំបូងខេត្តកណ្ដាលសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ៤ឆ្នាំ ពីបទលួចមានស្ថានទម្ងន់ទោស។ តាមពិត បទល្មើសទាំងពីរនេះគឺជាបទល្មើសត្រួតគ្នា ដូច្នេះសាលាដំបូងខេត្តកណ្ដាល គឺជាតុលាការចុងក្រោយដែលមានសមត្ថកិច្ចសម្រេចលើការស្រូបទោសបញ្ចូលគ្នា ប្រសិនបើមានពាក្យសុំស្រូបទោសបញ្ចូលគ្នាពីអ្នកពាក់ព័ន្ធ។

ឧបមាថា ដូចក្នុងឧទាហរណ៍ខាងលើនេះ សាលក្រមរបស់សាលាដំបូងខេត្តកណ្ដាលត្រូវបានបុគ្គលប្ដឹងទាស់ទៅសាលាឧទ្ធរណ៍ ហើយក្រោយមកសាលាឧទ្ធរណ៍ក៏បានចេញសាលដីកាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្ដាលនៅដដែល។ ក្នុងករណីបែបនេះ តុលាការចុងក្រោយ គឺសាលាឧទ្ធរណ៍ ហេតុនេះប្រសិនបើបុគ្គលនោះ មានបំណងចង់ស្នើសុំស្រូបទោស បុគ្គលដដែលត្រូវដាក់ពាក្យស្នើសុំទៅសាលាឧទ្ធរណ៍ដែលបានចេញសាលដីកាតម្កល់សាលក្រមសាលាដំបូងតាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បន្ទាប់មក សាលាឧទ្ធរណ៍នឹងសម្រេចលើពាក្យស្នើសុំ ដោយចេញជាសាលដីកាដែលអាចប្ដឹងសាទុក្ខទៅតុលាការកំពូលបាន។

ផ្ទុយមកវិញ ប្រសិនបើសំណុំរឿងកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់សាលាដំបូងខេត្តកណ្ដាលនៅឡើយ តុលាការអាចសម្រេចដោយឯកឯងបានអំពីការស្នើសុំស្រូបទោសរបស់ជនជាប់ចោទបាន។ ក្នុងករណីបែបនេះ តុលាការត្រូវសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្ដាប់តំណាងអយ្យការ ស្ដាប់ភាគីពាក់ព័ន្ធ និងជាយថាហេតុស្ដាប់មេធាវីរបស់ភាគីទាំងនេះ។[31]

### ១.២.២. ការស្រូបទោសមួយផ្នែក

ក្រៅពីការប្រកាសស្រូបទោសទាំងមូល តុលាការក៏អាចសម្រេចចិត្តយកការស្រូបទោសតែមួយផ្នែកក្នុងបទល្មើសត្រួតដែលមានប្រភេទដូចគ្នាមកប្រកាសទោសបានផងដែរ។ ការស្រូបទោសមួយផ្នែក គឺជាស្រូបយកទោសចំនួនមួយផ្នែកដែលស្រាលជាង ស្រូបបញ្ចូលទៅក្នុងទោសដែលធ្ងន់ជាង ហើយទោសនៅសល់ពីការស្រូបត្រូវយកទៅអនុវត្តត្រួតគ្នាជាមួយទោសដែលធ្ងន់ជាង។ គេអាចពន្យល់ម៉្យាងទៀតបានថា នៅពេលតុលាការចង់ប្រកាសស្រូបទោសមួយផ្នែក តុលាការត្រូវកាត់យកទោសមានចំនួនស្រាលជាងមួយចំណែកមកធ្វើជាទោសដែលត្រូវស្រូបបញ្ចូលគ្នា ឯទោសដែលនៅសេសសល់មួយចំណែកទៀតពីការស្រូបទោស ត្រូវយក

[31] សៀវភៅស្ដីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៨២ និង៤៨៣។

ទៅអនុវត្តជាបន្តបន្ទាប់ជាមួយទោសដែលធ្ងន់ជាងនោះ ប៉ុន្តែមិនត្រូវលើសពីព្រំដែនអតិបរមាកំណត់ដោយច្បាប់នោះទេ។[32] ដូចទៅនឹងការស្រូបទោសទាំងមូលដែរ ទោសដែលតុលាការប្រកាសស្រូបមួយផ្នែកនោះ មិនអាចយកទៅឲ្យទណ្ឌិតអនុវត្តទេ ពោលគឺទណ្ឌិតត្រូវរួចកាតព្វកិច្ចក្នុងការអនុវត្តទោសដែលបានស្រូបទោស។

**ឧទាហរណ៍**៖ ទណ្ឌិតម្នាក់ត្រូវសាលាដំបូងខេត្តកំពង់ស្ពឺប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៩ឆ្នាំ ពីបទទារុណកម្មនិងអំពើឃោរឃៅ តាមមាត្រា២១០ នៃក្រ.ព្រ.ទ ដែលត្រូវដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ។ ក្រោយមកត្រូវបានសាលាដំបូងខេត្តតាកែវផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ ពីបទហិង្សាមានស្ថានទម្ងន់ទោស តាមមាត្រា ២១៨ នៃក្រ.ព្រ.ទ ដែលត្រូវផ្តន្ទាទោសពី ២ឆ្នាំ ទៅ ៥ឆ្នាំ។ ស្ថានភាពបទល្មើសទាំងពីរខាងលើជាស្ថានភាពបទល្មើសត្រួតគ្នា។

ឧបមាថា តំណាងអយ្យការ ឬភាគីពាក់ព័ន្ធបានស្នើសុំស្រូបទោសមកតុលាការខេត្តតាកែវដែលជាតុលាការចុងក្រោយមានសមត្ថកិច្ចសម្រេចបទល្មើសហិង្សាមានស្ថានទម្ងន់ទោស។ ប្រសិនបើតុលាការសម្រេចជ្រើសរើសវិធានស្រូបទោស ប៉ុន្តែជ្រើសរើសយកការស្រូបទោសមួយផ្នែក តុលាការត្រូវយកទោសចំនួន ៣ឆ្នាំដែលស្រាលជាងមកបំបែកជា ២ចំណែកតាមនិយមន័យខាងលើ។ ក្នុងករណីដែលតុលាការកំណត់យកទោសចំនួន ១ឆ្នាំកន្លះសម្រាប់ជាទោសត្រូវស្រូប នោះទោស ១ឆ្នាំកន្លះទៀតដែលសល់ត្រូវប្រកាសយកទៅអនុវត្តបន្ត។

ទណ្ឌិតនឹងត្រូវបានរួចកាតព្វកិច្ចក្នុងការអនុវត្តទោសចំនួន ១ឆ្នាំកន្លះ រីឯទោស១ឆ្នាំកន្លះទៀត ត្រូវយកទៅអនុវត្តបន្តជាមួយនឹងទោសចំនួន ៩ឆ្នាំពីបទទារុណកម្មនិងអំពើឃោរឃៅ ដូច្នេះទណ្ឌិតត្រូវអនុវត្តទោសពន្ធនាគារសរុបចំនួន ១០ឆ្នាំកន្លះ។[33] ការស្រូបទោសតែមួយផ្នែកនេះ ពុំបានប៉ះពាល់ដល់ការអនុវត្តទោសទាំងមូលនៅថ្ងៃអនាគតនោះទេ ប្រសិនបើមានបទល្មើសណាមួយខាងលើ ត្រូវបានក្រមព្រហ្មទណ្ឌថ្មីលុបចោល។ យោងតាមមាត្រា៩ នៃក្រ.ព្រ.ទ បទល្មើសដែលបានលុបចោលដោយបញ្ញត្តិថ្មីត្រូវបានរួចកាតព្វកិច្ចក្នុងការអនុវត្តទោសទាំងពេលនៅក្នុងនីតិវិធីនិងពេលកំពុងអនុវត្តទោស មានន័យថា បើបទល្មើសទារុណនិងអំពើឃោរឃៅត្រូវបានលុបចោលលែងក្លាយជាបទល្មើស ទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារតែ ១ឆ្នាំកន្លះតែប៉ុណ្ណោះ។ ក្នុងករណីបានអនុវត្តទោសស្មើ ឬលើសចំនួន ១ឆ្នាំកន្លះហើយ ទណ្ឌិតត្រូវបានចាត់ទុកថាបានអនុវត្តទោសរួចរាល់តាមសាលក្រមតុលាការ និងត្រូវដាក់បញ្ចូលឲ្យចូលទៅរស់នៅក្នុងសង្គមដូចពលរដ្ឋធម្មតាវិញ។

## កថាខណ្ឌទី២. វិធានត្រួតទោស

វិធានត្រួតទោសជាវិធានសម្រាប់ផ្តន្ទាទោសមួយ ដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌដែលតុលាការត្រូវយកមកជាជម្រើស ក្នុងការធ្វើឆន្ទានុសិទ្ធិប្រកាសទោសទៅលើបុគ្គលដែលមានពិរុទ្ធភាពបទល្មើសត្រួតគ្នា។ វិធានត្រួតទោស ត្រូវបានយកទៅអនុវត្តទាំងក្នុងការចោទប្រកាន់តែមួយ ឬការចោទប្រកាន់ដាច់ពីគ្នា ប៉ុន្តែការ

[32] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣៨។

[33] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៤៨៥ និង៤៨៦។

អនុវត្តវិធាននេះក្នុងខាងចោទប្រកាន់ទាំង២ មានលក្ខខណ្ឌតាមច្បាប់មិនដូចគ្នាទេ។

### ១.១. ការត្រួតទោសដែលមានប្រភេទខុសគ្នា (បញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ)

នៅក្នុងការចោទប្រកាន់តែមួយ តុលាការអាចប្រកាសអំពីការត្រួតទោសបាន លុះត្រាតែបទល្មើសទាំងនោះត្រូវបានប្រកាសឡើងដោយមានប្រភេទទោសខុសគ្នា ពោលពុំអាចប្រកាសត្រួតទោសដែលមានប្រភេទដូចគ្នាបានទេ។ ទោសដាក់ពន្ធនាគារ ទោសពិន័យជាប្រាក់ ទោសព្យួរលិខិតបើកបរ ទោសប្រកាសទណ្ឌកម្មតាមការបិទផ្សាយ ទោសរឹបអូសវត្ថុ ទោសហាមឃាត់ការស្នាក់នៅ។ល។[34] ទោសដែលបានរៀបរាប់ខាងលើសុទ្ធសឹងតែជាទោសដែលមានប្រភេទខុសប្លែកពីគ្នា ហេតុដូច្នេះប្រសិនបើបទល្មើសក្នុងការចោទប្រកាន់មួយ ត្រូវផ្តន្ទា-ដោយទោសប្រភេទទាំងនេះ តុលាការអាចប្រកាសយកទោសទាំងនេះមកត្រួតគ្នាបាន។

**ឧទាហរណ៍៖** តុលាការបានផ្តន្ទាទោសបុគ្គលម្នាក់ពីបទដណ្តើមកាន់កាន់មធ្យោបាយដឹកជញ្ជូនតាមមាត្រា២៥៦ នៃក្រ.ព្រ.ទ ដោយឲ្យជាប់ពន្ធនាគារចំនួន ៥ឆ្នាំ និងមានទោសបន្ថែមហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈរយៈពេល ៥ឆ្នាំ ព្រមទាំងហាមឃាត់មិនឲ្យកាន់កាប់និងយកតាមខ្លួនអាវុធចំនួន ៤ឆ្នាំ។ បន្ថែមពីលើការប្រកាសទោសនេះ តុលាការបានសម្រេចផ្តន្ទាទោសបទល្មើសជេរប្រមាថជាសាធារណៈដោយពិន័យជាទឹកប្រាក់ចំនួន ៨លានរៀល។

ក្នុងឧទាហរណ៍ខាងលើ ឧបមាថាតុលាការបានសម្រេចជ្រើសយកអនុវត្តវិធានត្រួតទោសប្រភេទខុសៗគ្នាទាំង ៤ខាងលើ នៅក្នុងសំណុំរឿងបទល្មើសទាំង ២ ដែលតំណាងអយ្យការបានសម្រេចការចោទប្រកាន់ក្នុងសំណុំរឿងតែមួយ។ វិធានត្រួតទោស នឹងធ្វើឲ្យបុគ្គលនោះត្រូវអនុវត្តទោសទាំងអស់ព្រមគ្នា ដោយមានន័យថាបុគ្គលដែលជាប់ចោទក្នុងបទល្មើសត្រួត ត្រូវជាប់កាតព្វកិច្ចអនុវត្តទោសក្នុងពន្ធនាគារចំនួន ៥ឆ្នាំ, បង់ពិន័យជាប្រាក់ចំនួន ៨លានរៀល, ហាមមិនឲ្យប្រកបបរវិជ្ជាជីវៈដែលបទល្មើសបានកើតឡើងចំនួន ៥ឆ្នាំ និងចុងក្រោយហាមមិនឲ្យកាន់កាប់អាវុធចំនួន ៤ឆ្នាំដែលជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស។ ការប្រកាសទោសនេះ គឺសម្រាប់ឲ្យបុគ្គលអនុវត្តទោសចំពោះបទល្មើសទាំង២ ទាំងបទដណ្តើមកាន់កាប់មធ្យាបាយដឹកជញ្ជូន និងបទជេរប្រមាថជាសាធារណៈតែម្តង។

បន្ថែមពីនេះ ប្រសិនបើកំឡុងពេលទណ្ឌិតអនុវត្តទោស ទណ្ឌិតទទួលបានលើកលែងទោសដោយឲ្យរួចកាតព្វកិច្ចអនុវត្តទោសដែលនៅសល់រួមមានទោសដាក់ពន្ធនាគារ, ការហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈ និងការហាមឃាត់មិនឲ្យប្រើប្រាស់អាវុធ ទណ្ឌិតនឹងត្រូវដោះលែងឲ្យមានសេរីភាពវិញ។[35] ប៉ុន្តែប្រាក់ពិន័យចំនួនលានរៀលដែលបានបង់ចូលជាថវិការជាតិរួចហើយ ទណ្ឌិតមិនអាចស្នើសុំមកវិញបានទេ ពោលគឺការលើកលែងទោសជាទូទៅពុំមានអានុភាពអនុវត្តឡើយចំពោះទោសពិន័យជាប្រាក់។[36]

---

[34] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រ៤៧៥។

[35] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា២៧។

[36] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៤៩។

### ១.២. ការត្រួតទោសដែលមានប្រភេទដូចគ្នា (បញ្ញត្តិមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ)

#### ១.២.១. ការត្រួតទោសត្រឹមអតិបរិមាស្របច្បាប់ខ្ពស់ជាងគេ

ប្រសិនបើតុលាការមិនប្រកាសវិធានស្រូបទោស បុគ្គលដែលតុលាការរកឃើញថាមានពិរុទ្ធភាពក្នុងការចោទប្រកាន់ដាច់ពីគ្នា នឹងត្រូវរងការផ្តន្ទាទោសពីវិធានត្រួតទោសដោយយកទោសនីមួយៗ ដែលតុលាការប្រកាសមកអនុវត្តទោសត្រួតគ្នា។ យោងតាមកថាខណ្ឌទី១ មាត្រា ១៣៨ នៃក្រ.ព្រ.ទ ការត្រួតទោសអាចធ្វើបានស្ថិតនៅក្នុងព្រំដែននៃអតិបរិមាស្របច្បាប់ដែលខ្ពស់ជាងគេ មានន័យថា នៅពេលដែលតុលាការទី១ បានផ្តន្ទាទោសជនជាប់ចោទក្នុងដែនដីរបស់ខ្លួនរួចហើយ គេត្រូវបញ្ជូនខ្លួនជននោះទៅតុលាការទី២ ឬតុលាការចុងក្រោយគេដើម្បីផ្តន្ទាទោសជនជាប់ចោទនៅបទល្មើសមួយទៀត។ តុលាការចុងក្រោយមិនត្រូវប្រកាសទោសលើជនជាប់ចោទលើសពីព្រំដែនអតិបរមាក្នុងបទល្មើសដែលច្បាប់បានកំណត់នោះទេ។

ម៉្យាងវិញ ក្នុងករណីដែលតុលាការនីមួយៗបានប្រកាសផ្តន្ទាទោសលើបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តក្នុងដែនសមត្ថកិច្ចតុលាការខ្លួនរួចហើយ ប៉ុន្តែទោសទាំងនោះ យកមកធ្វើផលបូកបញ្ចូលគ្នាពុំទាន់ដល់ចំណុចព្រំដែននៃអតិបរមាស្របច្បាប់នោះទេ។ តុលាការចុងក្រោយត្រូវតែកំណត់យកចំនួនទោសដែលធ្វើផលបូកបញ្ចូលគ្នានោះ មកអនុវត្តចំពោះបុគ្គលនោះតែម្តង ដោយមិនត្រូវបន្ថែមទោសរហូតដល់ព្រំដែននៃអតិបរមាដែលច្បាប់បានកំណត់នោះឡើយ។ ការអនុវត្តវិធានត្រួតទោសអាចធ្វើទៅបានចំពោះតែមូលទោស និងទោសបន្ថែមតែប៉ុណ្ណោះ រីឯទោសជំនួសមិនអាចអនុវត្តបានទេ។

**ឧទាហរណ៍ទី១៖** ជនបរទេសម្នាក់បានសម្លាប់មនុស្សនៅខេត្តបាត់ដំបងកាលពីខែមករា ឆ្នាំ២០២៤។ បន្ទាប់នៅខែមីនា ឆ្នាំដដែល គាត់បានប្រើហិង្សាស្ថានទម្ងន់ទោសលើនារីម្នាក់នៅរាជធានីភ្នំពេញ និងត្រូវបានមន្ត្រីនគរបាល យុត្តិធម៌ឃាត់ខ្លួនបញ្ជូនទៅតុលាការដើម្បីបន្តនីតិវិធី។

យោងតាមឧទាហរណ៍ខាងលើ បទល្មើសត្រួតគ្នានេះត្រូវអនុវត្តដូចខាងក្រោម៖

- (ជាយុទ្ធសាស្ត្រ)ជនល្មើសត្រូវបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ជម្រះក្តីនៅបទហិង្សាមានស្ថានទម្ងន់ទោសតាមមាត្រា២១៨ ក្រ.ព្រ.ទ. ប្រឈមនឹងការទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លាន ទៅ ១០លានរៀល និងទោសបន្ថែមមួយចំនួនទៀត។ ក្នុងសវនាការតុលាការបានប្រកាសទោសដាក់ពន្ធនាគារចំនួន ៤ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦លានរៀល និងហាមឃាត់មិនឲ្យស្នាក់នៅកម្ពុជារយៈពេល ៣ឆ្នាំ ៦ខែ។ សាលក្រមនេះ ត្រូវចាត់ទុកថាជាសាលក្រមតុលាការទី១។
- បន្ទាប់មក ទណ្ឌិតត្រូវបញ្ជូនទៅសាលាដំបូងខេត្តបាត់ដំបងជម្រះលើបទឃាតកម្ម តាមមាត្រា ១៩៩ នៃក្រ.ព្រ.ទ. ដែលប្រឈមនឹងការជាប់ពន្ធនាគារពី ១០ឆ្នាំ ទៅ១៥ឆ្នាំ និងទោសបន្ថែមផ្សេងទៀត។ ក្នុងការសម្រេច តុលាការបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួន១៣ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០

លានរៀល ព្រមទាំងហាមឃាត់ជនជាប់ចោទមិនឲ្យស្នាក់នៅក្នុងប្រទេសកម្ពុជាចំនួន ៥ឆ្នាំ។

ប៉ុន្តែដោយយោងតាមមាត្រា១៣៨ នៃក្រ.ព្រ.ទ. សាលាដំបូងខេត្តបាត់ដំបូងចុងក្រោយដោយត្រូវប្រកាសទោសទាំងពីរខាងលើត្រួតគ្នាក្នុងព្រំដែនអតិបរមានៃច្បាប់បានកំណត់។

ហេតុនេះដោយៈ

- មាត្រា២១៨ ក្រ.ព្រ.ទ. បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយមានអតិបរមាទោសដាក់ពន្ធនាគារ ៥ឆ្នាំ និងពិន័យជាប្រាក់១០លានរៀល និងទោសបន្ថែមហាមមិនឲ្យស្នាក់នៅកម្ពុជារយៈ-ពេល ៥ឆ្នាំ។
- មាត្រា១៩៩ ក្រ.ព្រ.ទ. បទឃាតកម្ម មានអតិបរមាទោសដាក់ពន្ធនាគារ១៥ឆ្នាំ និងទោសបន្ថែមហាមមិនឲ្យស្នាក់នៅកម្ពុជារយៈពេល ៥ឆ្នាំ។

ដូច្នេះ តុលាការខេត្តបាត់ដំបងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១៥ឆ្នាំ និងពិន័យជាប្រាក់យ៉ាងច្រើន ១០លានរៀល និងទោសបន្ថែមហាមមិនឲ្យស្នាក់នៅកម្ពុជាច្រើនបំផុតត្រឹម ៥ឆ្នាំប៉ុណ្ណោះ។

**ឧទាហរណ៍ទី២៖** លោកសុខ បានប៉ុនប៉ងចាប់រំលោភនារីម្នាក់នៅបន្ទប់ខារ៉ាអូខេខេត្តកំពុងស្ពឺ កន្លះឆ្នាំក្រោយមក គាត់បានឆបោកបុរសម្នាក់នៅខេត្តកណ្តាលនៅទឹកប្រាក់ចំនួន ៥០០០ដុល្លារសហរដ្ឋអាមេរិក។

យោងតាមឧទាហរណ៍ខាងលើ អង្គហេតុបានបង្កើតជាស្ថានភាពបទល្មើសត្រួតគ្នា និងស្ថិតក្នុងវិធានចោទប្រកាន់ដាច់ពីគ្នាៈ

- សាលាដំបូងខេត្តកណ្តាលមានអ្នកមានសមត្ថកិច្ចមុនគេ ជម្រះលើរឿងឆបោកទឹកប្រាក់ ៥០០០ដុល្លារ យោងតាមមាត្រា ៣៧៨ ក្រ.ព្រ.ទ. ជនជាប់ចោទត្រូវប្រឈមជាប់ពន្ធនាគារពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាប់ពី ១លាន ទៅ ៦លានរៀល។ ក្នុងការជំនុំជម្រះនោះ តុលាការបានប្រកាសដាក់ពន្ធនាគារ ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លានរៀល។
- បន្ទាប់ពីសាលក្រមទី១ បានចូលជាស្ថាពររួចហើយ ទណ្ឌិតត្រូវបញ្ជូនទៅសាលាដំបូងខេត្តកំពុងស្ពឺជាតុលាការចុងក្រោយ។ យោងតាមមាត្រា២៣៩ ក្រ.ព្រ.ទ. បទរំលោភសេពសន្ថវៈ អាចត្រូវប្រកាសឲ្យដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ ប៉ុន្តែ ក្នុងសវនាការ តុលាការបានប្រកាសដាក់ពន្ធនាគារចារីចំនួន ៦ឆ្នាំ ដោយមិនមានទោសបន្ថែមអ្វីផ្សេងឡើយ។

ដោយហេតុថា បទរំលោភសេពសន្ថវៈមានអតិបរមាដាក់ពន្ធនាគារចំនួន ១០ឆ្នាំ និងទោសពិន័យបទឆបោក ចំនួន ១០លានរៀល។ ប៉ុន្តែទោសដែលតុលាការទាំង ២ខាងលើបានប្រកាស ធ្វើផលបូកទៅដោយមានទោសដាក់ពន្ធនាគារចំនួន ៧ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លានរៀល ដែលពុំទាន់ដល់ព្រំដែនអតិបរមាស្របច្បាប់ខ្ពស់ជាងគេ។ ដូច្នេះ យោងតាមអន្តន័យនៃមាត្រា១៣៨ ក្រ.ព្រ.ទ. សាលាដំបូងខេត្តកំពុងស្ពឺត្រូវប្រកាសផ្តន្ទាទោសបទល្មើសទាំង ២ ត្រួតគ្នា ដោយត្រូវប្រកាសដាក់ពន្ធនាគារត្រឹមចំនួន ៧ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លានរៀលតែប៉ុណ្ណោះ។

### ១.២.២. ការត្រួតទោសក្នុងករណីទោសពន្ធនាគារមួយជីវិត

យោងតាមមាត្រា១៣៨ កថាខណ្ឌទី២ នៃក្រ.ព្រ.ទ. បានចែងថា “ **នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនោះទេ** ”។ មានន័យថា ប្រសិនបើពិរុទ្ធជន ពុំទាន់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតក្នុងបទល្មើសត្រួតគ្នាដែលមានចែងអំពីអតិបរមានៅក្នុងច្បាប់ដោយដាក់ពន្ធនាគារអស់មួយជីវិតនោះ តុលាការត្រូវតែផ្តន្ទាទោសបុគ្គលនោះដោយដាក់ពន្ធនាគារត្រឹមកម្រិតអតិបរមានៃទោសចំនួន ៣០ឆ្នាំតែប៉ុណ្ណោះ។

**ឧទាហរណ៍**៖ លោក **ក** បានទទួលប្រាក់ចំនួន ១០,០០០ ដុល្លារពីនារីម្នាក់ជាថ្នូរនឹងការទៅសម្លាប់ប្តីរបស់នាងដែលកំពុងរស់នៅភ្នំពេញ។ ប៉ុន្តែដោយការសម្លាប់បុរសនោះត្រូវបានបរាជ័យ លោក **ក** ត្រូវបានប៉ូលីសឃាត់ខ្លួន។ ក្នុងនីតិវិធីបើកការស៊ើបសួរ ចៅក្រមស៊ើបសួរបានរកឃើញថាលោក **ក** ធ្លាប់បានស៊ីឈ្នួលសម្លាប់នារីម្នាក់នៅខេត្តព្រះសីហនុក្នុងឆ្នាំ២០១០ និងឆ្នាំ២០១៥ គាត់បានសម្លាប់បុរសចំណាស់ម្នាក់ទៀតដោយសារជម្លោះនឹងគ្នាក្នុងភោជនីយដ្ឋានមួយក្នុងខេត្តកំពត។

យោងតាមអង្គហេតុ តុលាការត្រូវអនុវត្តបទល្មើសត្រួតគ្នាទាំង ៣ដូចខាងក្រោម៖

- សាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចមុនគេ ជំនុំជម្រះលើរឿងឃាតកម្មគិតទុកជាមុនដែលលោក **ក** ទទួលប្រាក់១០,០០០ ដុល្លារក្នុងការសម្លាប់ប្តីរបស់នាងនោះ។ ដោយយោងតាមមាត្រា ២០០ ត្រូវប្រឈមនឹងការជាប់ពន្ធនាគារអស់មួយជីវិត។ ដោយមូលហេតុបញ្ហាសតិអារម្មណ៍របស់គាត់តុលាការបានប្រកាសដាក់ពន្ធនាគារត្រឹមតែ ២៥ឆ្នាំប៉ុណ្ណោះ។
- បន្ទាប់មកត្រូវបញ្ជូនលោក **ក** ទៅសាលាដំបូងខេត្តព្រះសីហនុដោយជម្រះលើបទឃាតកម្មគិតទុកជាមុនដូចនឹងករណីខាងលើផងដែរ ចំពោះការស៊ីឈ្នួលទៅសម្លាប់នារីម្នាក់នៅឆ្នាំ២០១០។ សាលាដំបូងខេត្តព្រះសីហនុបានចេញសាលក្រមឲ្យលោក **ក** ជាពន្ធនាគារចំនួន ២២ ឆ្នាំ ដោយពុំមានទោសបន្ថែមអ្វីឡើយ។
- ចុងក្រោយសាលាដំបូងខេត្តកំពតជាតុលាការចុងក្រោយ ដោយជំនុំជម្រះលើសំណុំរឿងលោក **ក** បានសម្លាប់បុរសចំណាស់ម្នាក់ក្នុងភោជនីយដ្ឋាន ដោយយោងតាមមាត្រា ១៩៩ ក្រ.ព្រ.ទ. ត្រូវប្រឈមជាប់ពន្ធនាគារពី១០ ទៅ១៥ឆ្នាំ។ នៅក្នុងសវនាការ តុលាការខេត្តកំពតបានប្រកាសដាក់ពន្ធនាគារជនជាប់ចោទចំនួន ១៣ឆ្នាំ ដោយពុំមានទោសបន្ថែមដូចនឹងសាលក្រមមុនៗដែរ។

ដោយហេតុថា សាលាដំបូងខេត្តកំពតជាតុលាការចុងក្រោយមានសមត្ថកិច្ចត្រូវកំណត់លើទោសចុងក្រោយនៃទោសទាំង៣ ដែលតុលាការនានាបានប្រកាសទៅលោក **ក** ក្នុងការរកយុត្តិធម៌ទៅលើជនរងគ្រោះ។ ទោសដែលតុលាការនៃសាលាដំបូងទាំង៣ បានប្រកាសទៅលើលោក **ក** ពុំមានទោសមួយណាត្រូវបានផ្តន្ទា-

ទោសដោយដាក់ពន្ធនាគារអស់មួយជីវិតនោះឡើយ, ដូច្នេះដោយអនុលោមតាមកថាខណ្ឌទី២ នៃមាត្រា១៣៨ ក្រ.ព្រ.ទ. តុលាការខេត្តកំពតត្រូវប្រកាសផ្តន្ទាទោសលើបទល្មើសទាំង៣ ដាក់ពន្ធនាគារត្រឹមចំនួន ៣០ឆ្នាំតែប៉ុណ្ណោះ។ ប៉ុន្តែប្រាស់មកវិញ ឧបមាថាប្រសិនមានតុលាការមួយក្នុងចំណោមតុលាការទាំង៣ បានប្រកាសដោយផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះបទល្មើសណាមួយខាងលើ នោះអតិបរមាដែលត្រូវប្រកាសផ្តន្ទាទោសគឺត្រូវជាប់ពន្ធនាគារអស់មួយជីវិតតែម្តង។

## ផ្នែកទី៣. វិធានបូកទោស

វិធានបូកទោសត្រូវបានកំណត់បែកចែកជាពីរដាច់ពីគ្នា គឺវិធានបូកទោសពិន័យចំពោះបទលហុ (កថា-ខណ្ឌទី១) និងវិធានបូកទោសចំពោះការរត់គេចពីពន្ធនាគារ ឬមន្ទីរឃុំឃាំង (កថាខណ្ឌទី២)។

## កថាខណ្ឌទី១. វិធានបូកទោសពិន័យចំពោះបទលហុ

យោងមាត្រា១៤០ នៃក្រ.ព្រ.ទ បានកំណត់ថា៖ “ **ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើងចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬមជ្ឈិម** ”។ តាមបទប្បញ្ញត្តិនេះ គេអាចពន្យល់បានថា វិធានបូកទោសពិន័យជាប្រាក់ចំពោះបទលហុ គឺជាការបូកបញ្ចូលគ្នានូវទោសពិន័យជាប្រាក់រវាងបទលហុជាមួយនឹងបទលហុ ឬបទមជ្ឈិម ឬបទឧក្រិដ្ឋនិងអាចយកទៅអនុវត្តបានមិនថាក្នុងសំណុំរឿងចោទប្រកាន់តែមួយ ឬចោទប្រកាន់ដាច់ពីគ្នានោះទេ។[37] ទោសពិន័យបទលហុអាចយកទៅស្រូបបញ្ចូលគ្នាជាមួយនឹងទោសពិន័យដែលបានប្រកាសចំពោះបទលហុដូចគ្នា ឬបទមជ្ឈិម ឬបទឧក្រិដ្ឋផ្សេងទៀតបាន។ ដោយហេតុថាចំពោះបទលហុប្រាក់ពិន័យបទល្មើសមានចំនួនតិច និងខ្លះទៀតពុំមានទោសដាក់ពន្ធនាគារនោះទេ ដូច្នេះការជ្រើសយកវិធីបូកប្រាក់ពិន័យបញ្ចូលគ្នាច្រើនដងជាបន្តបន្ទាប់អាចជាវិធីសាស្ត្រល្អមួយធ្វើឲ្យជនល្មើសមានការរៀងចាលនូវការប្រព្រឹត្តខុសខាងសីលធម៌រស់នៅក្នុងសង្គម និងច្បាប់ជាតិ។ រីឯថវិកាបានមកពីការបង់ពិន័យចំពោះបទល្មើសដែលប្រកាសឲ្យអនុវត្តដោយវិធាននេះ នឹងត្រូវបានប្រមូលចូលជាថវិកាប្រចាំឆ្នាំរបស់ជាតិ។[38]

**ឧទាហរណ៍**៖ ជនម្នាក់បានប្រព្រឹត្តបទជេរប្រមាថជាសាធារណៈតាមមាត្រា៣០៧ ក្រ.ព្រ.ទ ដែលត្រូវផ្តន្ទា-ទោសពិន័យជាប្រាក់ពី ១០ម៉ឺនរៀល ទៅ ១០លានរៀល និងបទហិង្សាស្រាលតាមមាត្រា២២៨ នៃក្រ.ព្រ.ទ ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចាប់ពី ៥ពាន់រៀល ទៅដល់ ១០ម៉ឺនរៀលចំនួន ៣ករណី។

ឧបមាថា តុលាការសម្រេចផ្តន្ទាទោសដោយ ៖

- បទជេរប្រមាថជាសាធារណៈ ពិន័យជាប្រាក់ចំនួន ១លានរៀល

[37] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រ៤៨៩។

[38] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៤៣ និងមាត្រា៥២។

- និងបទហិង្សាស្រាល ពិន័យជាប្រាក់ចំនួន ៥ម៉ឺនរៀលចំពោះករណីទី១, ៨ម៉ឺនរៀលចំពោះករណីទី២ និង១០ម៉ឺនរៀល ចំពោះករណីទី៣។

តាមរយៈគោលការណ៍នៃវិធានបូកទោសពិន័យចំពោះបទលហុ ដែលបានកំណត់ថា ត្រូវធ្វើផលបូកទោសពិន័យជាប្រាក់បញ្ចូលគ្នាចំពោះបទលហុ និងបទលហុដូចគ្នាដោយបូកមិនកំណត់។ តាមគោលការណ៍នេះ តុលាការត្រូវប្រកាសទោសដោយបូកប្រាក់ពិន័យដែលបានប្រកាសចំពោះបទល្មើសទាំង៤ ករណីខាងលើ ពោលគឺបូកប្រាក់ពិន័យចំនួន ១លានរៀលពីបទដេរប្រមាថជាសាធារណៈ និងចំនួន ៥ម៉ឺន, ៨ម៉ឺន, និង១០ម៉ឺនរៀលពីបទហិង្សាស្រាល។ ដូច្នេះតុលាការត្រូវប្រកាសទោសពិន័យជាប្រាក់សរុបចំនួន ១លាន ២៣ម៉ឺនរៀលគត់។

ក្រឡេកមកមើលទោសដាក់ពន្ធនាគារ ទោសបន្ថែម ឬទោសជំនួសដែលមានក្នុងបទលហុវិញ យោងតាមមាត្រា៤៨ នៃក្រ.ព្រ.ទ បានកំណត់និយមន័យបទលហុដោយសម្តែងថា៖ **បទល្មើសជាបទលហុនៅក្នុងករណីដែល៖ (១). អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង៦ថ្ងៃ។ ទោសដាក់ពន្ធនាគារអាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ (២). បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែទោសពិន័យជាប្រាក់ប៉ុណ្ណោះ**។ យោងតាមការបកស្រាយមាត្រា១៤០ នៃក្រ.ព្រ.ទ ដោយផ្អែកលើគោលការណ៍ការបកស្រាយយ៉ាងតឹងរ៉ឹងរបស់ក្រមព្រហ្មទណ្ឌ ការបូកទោសបញ្ចូលគ្នាមានវិសាលភាពអាចអនុវត្តបានតែចំពោះទោសពិន័យជាប្រាក់តែប៉ុណ្ណោះ រីឯទោសដាក់ពន្ធនាគារ ទោសបន្ថែម ឬទោសជំនួសមិនអាចយកមកបូកបញ្ចូលគ្នាបានទេ។[39] ពោលគឺត្រូវទៅស្រូបទោស ឬត្រួតទោសទៅតាមការបម្រែបម្រួលនៃនីតិវិធីនៃការចោទប្រកាន់តែមួយ ឬដាច់ពីគ្នា។

**ឧទាហរណ៍**៖ ស្ត្រីម្នាក់ត្រូវបានតុលាការផ្តន្ទាទោសពីបទទ្វេពន្ធភាពតាមមាត្រា៣៥០ នៃក្រ.ព្រ.ទ ដាក់ពន្ធនាគារ ៦ខែ និងពិន័យជាប្រាក់ចំនួន ១លាន ៥០ម៉ឺនរៀល និងបទញុះញង់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈតាមមាត្រា៥០៥ នៃក្រ.ព្រ.ទ ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៥ថ្ងៃ និងពិន័យជាប្រាក់ចំនួន ១០ម៉ឺនរៀល។

តាមគោលការណ៍នៃមាត្រា១៤០ នៃក្រ.ព្រ.ទ ការប្រកាសទោសពិន័យចំពោះបទលហុត្រូវយកទៅបូកជាមួយការប្រកាសទោសពិន័យនូវបទមជ្ឈិម និងបទឧក្រិដ្ឋ ដោយមិនអាចយកទៅស្រូប ឬត្រួតទោសបានឡើយ។ ហេតុនេះ តុលាការត្រូវប្រកាសវិធានបូកទោសចំពោះបទល្មើសទាំង២ខាងលើមកបូកបញ្ចូលនូវទោសពិន័យជាប្រាក់គ្នាសរុបចំនួន ១លាន ៦០ម៉ឺនរៀល។ រីឯទោសដាក់ពន្ធនាគារពីបទញុះញង់ឲ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈដែលជាបទលហុវិញ មិនអាចយកជាកម្មវត្ថុក្នុងការបូកបញ្ចូលគ្នាជាមួយបទទ្វេភាពដូចការបូកប្រាក់ពិន័យបទលហុបានឡើយ។[40]

---

[39] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៥។

[40] សៀវភៅស្តីពីបទល្មើសត្រួតគ្នា រៀបរៀងដោយលោក **ចក សម្បត្តិ** ទំព័រទី ៩៥ កថាខណ្ឌទី១១៣។

សរុបជារួម ទោសពន្ធនាគារត្រូវយកទៅអនុវត្តតាមវិធានស្រូប ឬត្រួតទោសអាស្រ័យទៅតាមការចោទប្រកាន់តែមួយ ឬចោទប្រកាន់ដាច់ពីគ្នារបស់តំណាងអយ្យការ។

## កថាខណ្ឌទី២. វិធានបូកទោសចំពោះករណីរត់ចេញពីពន្ធនាគារ

ការរត់គេចចេញពីមន្ទីរឃុំឃាំងរបស់មន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាក់ថាជនល្មើស ឬទណ្ឌិតមិនព្រមទទួលស្គាល់កំហុសរបស់ខ្លួន និងគ្មានបំណង់ចង់ជម្រុះចោលនូវគំនិតក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌម្តងទៀតឡើយ។ យោងតាមមាត្រា១៤១ នៃក្រមព្រហ្មទណ្ឌបានចែងកំណត់ថា “ **ក្នុងករណីផ្តន្ទាទោសពីបទលួចរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះ ត្រូវបូកជាមួយនឹងទោសប្រកាសឡើងចំពោះបទល្មើសដែលនាំឲ្យមានការឃុំខ្លួនជននោះដោយមិនអាចមានកាស្រូបចូលគ្នា** ”។ ពាក្យ “ **ពន្ធនាគារ** ” យោងតាមមាត្រា៤ នៃច្បាប់ស្តីពីពន្ធនាគារ មានន័យចង់ “ **សំដៅដល់កន្លែងប្រើសម្រាប់ឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយ អាជ្ញាធរតុលាការរួមមានមណ្ឌលឃុំ និងមណ្ឌលអប់រំកែប្រែ** ”។ បន្ថែមពីនេះ យោងតាមមាត្រា៥៦០ ដល់មាត្រា៥៧០ នៃក្រមព្រហ្មទណ្ឌ ការរត់ចេញពីពន្ធនាគារ គឺសំដៅដល់ការរត់ចេញពីការកន្លែងឃុំខ្លួនតាមរយៈការប្រើប្រាស់មធ្យោបាយទុច្ចរិតនានា នៅក្នុងដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌដើម្បីបញ្ជូនទៅជំនុំជម្រះនៅចំពោះមុខតុលាការ។ ម្យ៉ាងវិញទៀត ចំពោះទណ្ឌិតដែលបានទទួលរបបពាក់កណ្តាលសេរីភាព របបព្យួរទោស របបបែងចែកទោសជាប្រភាគ ឬការអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារ ដោយមិនបានវិលត្រឡប់មកពន្ធនាគារវិញតាមរយៈពេលផុតការមានសេរីភាព ក៏ត្រូវចាត់ទុកថាបានរត់គេចចេញពីពន្ធនាគារផងដែរ។ [41]

**ឧទាហរណ៍ទី១៖** សមត្ថកិច្ចបានឲ្យដឹងថាទណ្ឌិតម្នាក់ក្នុងចំណោម បក្ខពួកទាំង ៥នាក់ដែលបានហែកគុករត់គេចខ្លួនចេញពីពន្ធនាគារខេត្តបាត់ដំបង កាលពីអំឡុងខែមេសា ឆ្នាំ២០១២ កន្លងទៅ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបានមកវិញនៅវេលាម៉ោង ១០ព្រឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០១៤ ខណៈរូបគេ កំពុងជិះម៉ូតូនៅក្នុងភូមិមួយនៃស្រុកសង្កែ ខេត្តបាត់ដំបង។

**ឧទាហរណ៍ទី២៖** ជនសង្ស័យ ៣ នាក់ មានជំនាញខាងលួចកាត់សោ ក ម៉ូតូប្រជាពលរដ្ឋ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៨ និងថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៤ វេលាទៀបភ្លឺនៅក្នុងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ និងត្រូវបាននាំខ្លួនទៅឃុំនៅអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ។ ជនសង្ស័យទាំង ៣នាក់នេះ បាននាំគ្នាហែកគុករត់គេចខ្លួនចេញពីកន្លែងឃុំឃាំងរបស់នគរបាលខណ្ឌដោយសុវត្ថិភាព កាលពីវេលាម៉ោងជាង ៩យប់ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ ដែលហេតុការណ៍នេះបង្កឲ្យមានការភ្ញាក់ផ្អើលដល់សមត្ថកិច្ច និងប្រជាពលរដ្ឋពេញមួយខណ្ឌឫស្សីកែវ។

**ឧទាហរណ៍ទី៣៖** ជនជាប់ចោទម្នាក់បានប៉ុនប៉ងរត់គេចចេញពីមន្ទីពេទ្យកាលម៉ែត្រ ក្រោយពីរូបគេបានធូរស្បើយពីជំងឺបន្ទាប់ពីបានបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីពេទ្យ។ ជនជាប់ចោទមានបំណង់ចង់សម្លាប់ខ្លួន

[41] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា៥៦២។

ដើម្បីឲ្យមន្ត្រីពន្ធនាគារបញ្ជូនរូបគេមកព្យាបាលនៅខាងក្រៅ ដោយមានគម្រោងគិតទុកថានឹងរត់ចេញពីមន្ទីរពេទ្យនៅពេលខ្លួនបានធូរស្បើយពីជំងឺ ដោយមិនចង់ទៅជំនុំជម្រះក្នុងសវនាការដែលបានកំណត់ទុកនៅថ្ងៃខាងមុខ។

យោងតាមគោលការណ៍បូកទោសដែលមានចែងក្នុងមាត្រា១៤១ នៃក្រ.ព្រ.ទ ជនដែលបានប្រព្រឹត្តអំពើតាមមធ្យោបាយដែលបានរៀបរាប់ខាងលើ ឬមធ្យោបាយផ្សេងទៀត ក្នុងគោលបំណងគេចចេញពីការឃុំខ្លួនរបស់មន្ត្រីមានសមត្ថកិច្ច តុលាការត្រូវតែប្រកាសអនុវត្តវិធានបូកទោសបញ្ចូលគ្នាករណីរត់គេចចេញពន្ធនាគារ មិនអាចប្រកាសវិធានត្រួតទោស ឬវិធានស្រូបទោសមកអនុវត្តបានឡើង ទោះបីជាមានការស្នើសុំស្រូបទោសក៏ដោយ។ តុលាការត្រូវប្រកាសសាលក្រមឬសាលដីកា ដោយយកទោសដែលប្រកាសពីបទល្មើសដំបូងមកបូកបញ្ចូលគ្នាជាមួយនឹងទោសក្នុងបទរត់គេចចេញពីពន្ធនាគារដោយមិនខ្វល់អំពីប្រភេទបទល្មើស ប្រភេទទោស ឬពីព្រំដែនអតិបរមាខ្ពស់ជាងគេស្របច្បាប់ឡើយ។ តុលាការអាចអនុវត្តវិធាននេះបាន ទោះបីជាសំណុំរឿងស្ថិតក្នុងការចោទប្រកាន់តែមួយ ឬការចោទប្រកាន់ដាច់ពីគ្នាក៏ដោយ ឬទោះបីជាក្នុងករណីជាទោសពិន័យ និងទោសដាក់ពន្ធ-នាគារក៏ដោយ។

**ឧទាហរណ៍**៖ តុលាការបានផ្តន្ទាទោសពីឃាតកម្មតាមមាត្រា១៩៩ នៃក្រ.ព្រ.ទ ដោយដាក់ពន្ធនាគារ ១០ឆ្នាំ។ បន្ទាប់ពីបានអនុវត្តទោសបានចំនួន ២ឆ្នាំ តុលាការបានប្រកាសផ្តន្ទាទោសពីបទរត់គេចពន្ធនាគារតាមមាត្រា ៥៦១ នៃក្រ.ព្រ.ទ ដោយផ្តន្ទាទោសបន្ថែមដាក់ពន្ធនាគារចំនួន ៣ឆ្នាំ។

តាមអង្គហេតុនេះ បុគ្គលខាងលើនឹងត្រូវរងការចោទប្រកាន់ពីបទល្មើសត្រួតគ្នា ដោយកំណត់យកវិធានបូកទោសរត់ចេញពីពន្ធនាគារមកប្រកាសជារូបមន្តក្នុងការអនុវត្ត។ ផ្អែកតាមគោលការណ៍នៃវិធានបូកទោស ទោសពន្ធនាគារនៃបទល្មើសដំបូងត្រូវធ្វើផលបូកជាមួយទោសរត់គេចចេញពីពន្ធនាគារ ដែលជាបទល្មើសក្រោយ។ ដោយហេតុថាបុគ្គលបានអនុវត្តទោសចំនួន ២ឆ្នាំចំពោះបទឃាតកម្មក្នុងពន្ធនាគាររួចហើយ ដូច្នេះ ទោសពន្ធនាគារថ្មីដែលត្រូវប្រកាសឲ្យអនុវត្តតាមវិធានបូកទោសនេះ បុគ្គលត្រូវជាប់ពន្ធនាគារសរុបចំនួន ១១ឆ្នាំ ដោយអនុវត្តសម្រាប់បទល្មើសទាំង ២ខាងលើ។

# ជំពូកទី៣

# ជំពូកទី៣

# ការអនុវត្តទោស

យោងតាមមាត្រា៣ នៃក្រមព្រហ្មទណ្ឌ ស្តីពីគោលការណ៍នីត្យានុកូលភាព រាល់បុគ្គលទាំងឡាយដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ តុលាការត្រូវតែចាំបាច់ផ្តន្ទាទោសបុគ្គលទៅតាមបញ្ញត្តិដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ តុលាការប្រកាសទោសដោយផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ ដែលជាគោល-ការណ៍ពិសេសមួយបានបញ្ញត្តិនៅក្នុងមាត្រា៩៦ ក្រមព្រហ្មទណ្ឌ ក្នុងគោលបំណងកំណត់ជាមូលដ្ឋានគ្រឹះសម្រាប់តុលាការធ្វើការថ្លឹងថ្លែង ពិចារណា និងប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយគោរពតាមគោលការណ៍នេះ ក្នុងការប្រកាសទោសព្រហ្មទណ្ឌ ទៅតាមកម្រិតនៃអំពើដែលជនជាប់ចោទបានប្រព្រឹត្ត និងទំហំព្យសនកម្មដែលបានបង្កដល់ជនរងគ្រោះ និងសង្គមជាតិ ដើម្បីផ្តល់ភាពត្រឹមត្រូវ និងយុត្តិធម៌។

## ផ្នែកទី១. ការព្យួរទោស

ការព្យួរទោស គឺជាការដោះលែងដោយលក្ខខណ្ឌនូវការអនុវត្តទោសដែលកំណត់ប្រកាសដោយតុលាការ។ ប៉ុន្តែគេអាចឲ្យនិយមន័យមួយទៀតបានថា ការព្យួរទោស គឺជាការអនុញ្ញាតឲ្យទណ្ឌិតចេញទៅរស់នៅក្នុងសង្គមដោយត្រូវគោរពលក្ខខណ្ឌកំណត់តាមច្បាប់អនុវត្ត។[42] ទណ្ឌិតអាចទទួលបានការប្រកាសព្យួរទោសប្រភេទណាមួយបាន លុះត្រាតែទណ្ឌិតបានបំពេញលក្ខខណ្ឌសម្រាប់ស្នើសុំការព្យួរទោសនោះដែលមានកំណត់ក្នុងច្បាប់ព្រហ្ម-ទណ្ឌ។ តាមក្រមព្រហ្មទណ្ឌ ការព្យួរទោសត្រូវបានចែកចេញជា ២ប្រភេទដាច់ពីគ្នាគឺ ការព្យួរទោសការព្យួរទោសធម្មតា (កថាខណ្ឌទី១) និងការព្យួរទោសសាកល្បង (កថាខណ្ឌទី២)។

### កថាខណ្ឌទី១. ការព្យួរទោសធម្មតា

ការព្យួរទោស គឺជាវិធានការមួយដែលតុលាការអាចយកទៅប្រកាសអនុវត្តចំពោះទណ្ឌិតណាម្នាក់បាន ប្រសិន បើទណ្ឌិតបានបំពេញតាមលក្ខខណ្ឌតម្រូវជាចាំបាច់តាមផ្លូវច្បាប់។ តុលាការត្រូវសម្រេចដោយប្រុងប្រយ័ត្នថាគួរតែអនុញ្ញាតឱ្យព្យួរទោស ឬមិនគួរយល់ព្រមឱ្យព្យួរទោស ក៏ប៉ុន្តែទន្ទឹមនឹងគ្នាការធ្វើឆន្ទានុសិទ្ធិនេះ តុលាការក៏ត្រូវតែពិនិត្យវិនិច្ឆ័យទៅលើលក្ខខណ្ឌនានាដែលច្បាប់បានកំណត់ឱ្យប្រាកដប្រជា និងឱ្យបានច្បាស់លាស់ផងដែរ។ ក៏ប៉ុន្តែទោះបីជាមានគ្រប់លក្ខខណ្ឌដែលច្បាប់ចែងក៏ដោយ ក៏មិនមែនបានន័យថា តុលាការមានកាតព្វកិច្ចត្រូវតែប្រកាសការព្យួរទោសដើម្បីជាប្រយោជន៍ឱ្យដល់ជនជាប់ចោទនោះដែរ។ ក្រមព្រហ្មទណ្ឌបានចែងកំណត់អំពីលក្ខខណ្ឌដែលត្រូវគោរពតាម ក្នុងការអនុញ្ញាតឱ្យមានការប្រកាសការព្យួរទោសធម្មតា (១.១.) ដែលនឹងត្រូវមានអានុភាពលើកចោលនូវការអនុវត្តទោស (១.២.)។

[42] សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រ៤៩៧។

### ១.១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា

ដើម្បីសម្រេចយល់ព្រមអនុញ្ញាតឱ្យមានការព្យួរទោសធម្មតា តុលាការត្រូវតែធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីលក្ខខណ្ឌផ្សេងៗ ដែលក្រមព្រហ្មទណ្ឌកំណត់ឱ្យបានគ្រប់ជ្រុងជ្រោយ ។ ជាដំបូង ត្រូវពិនិត្យទៅលើលក្ខខណ្ឌទាក់ទងនឹងទោសដែលត្រូវព្យួរ ( ១.១.១. ) និងបន្ទាប់មកទៀត លក្ខខណ្ឌអំពីប្រវត្តិនៃការផ្តន្ទាទោសជនជាប់ចោទនាពេលកន្លងមក ( ១.១.២. )។

#### ១.១.១. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ

លក្ខខណ្ឌដែលអាចនាំឲ្យមានការព្យួរទោស យោងតាមមាត្រា១០៧ នៃក្រ.ព្រ.ទ សំដៅដល់ទោសដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹង ៥ឆ្នាំ។ ទោសត្រឹម ៥ឆ្នាំគឺតុលាការប្រកាសថាជនជាប់ចោទត្រូវមានទោសដាក់ពន្ធនាគារត្រឹមចំនួន ៥ឆ្នាំចុះមកក្រោម ក្នុងករណីនេះតុលាការអាចពិចារណាជ្រើសរើសយកការព្យួរទោសធម្មតាមកប្រកាសទោសបាន។ ចំពោះទោសពិន័យជាប្រាក់វិញ តុលាការអាចធ្វើឆន្ទានុសិទ្ធិក្នុងការប្រកាសព្យួរទោស ឬមិនព្យួរទោសបានផងដែរ។ តាមខ្លឹមសារមាត្រា១០៧ នៃក្រ.ព្រ.ទ. ដដែល បានកំណត់អំពីការព្យួរទោសធម្មតាសម្រាប់តែទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់តែប៉ុណ្ណោះ ដោយមិនបានបញ្ញត្តិអំពីទោសប្រភេទផ្សេងទៀតឡើយ។ ហេតុនេះ គេអាចសន្និដ្ឋានបានយ៉ាងច្បាស់ថាទោសបន្ថែម និងទោសជំនួសមិនត្រូវបានអនុញ្ញាតឲ្យមានការព្យួរទោសឡើយ។

#### ១.១.២. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន

ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមវិញ តុលាការអាចប្រកាសការព្យួរទោសធម្មតាបាន លុះត្រាតែជនជាប់ចោទមិនធ្លាប់មានការផ្តន្ទាទោសជាស្ថាពរពីមុនក្នុងរយៈពេល ៥ឆ្នាំ រហូតដល់ថ្ងៃជនជាប់ចោទបានប្រព្រឹត្តបទល្មើសថ្មី។[43] ចំពោះបទលហុ តុលាការអាចប្រកាសអំពីការព្យួរទោសធម្មតាបាន លុះត្រាណាតែជនជាប់ចោទពុំធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេល១ឆ្នាំ គិតរហូតដល់បទល្មើសថ្មីបានកើតឡើង។[44] ប៉ុន្តែប្រសិនបើជនជាប់ចោទគ្រាន់តែធ្លាប់ត្រូវបានតុលាការប្រកាសទោសពិន័យជាប្រាក់ ឬទោសផ្សេងៗទៀតដែលមិនមែនជាទោសពន្ធនាគារក្នុងរយៈពេលបានកំណត់ខាងលើ ទោសទាំងនេះពុំមានអានុភាពប៉ះពាល់ដល់ឆន្ទានុសិទ្ធិតុលាការក្នុងការសម្រេចព្យួរទោសធម្មតាឡើយ។ ត្បិតថាយោងតាមក្រមព្រហ្មទណ្ឌ បានកំណត់រយៈពេលខាងលើ តែទោសពន្ធនាគារតែប៉ុណ្ណោះ រីឯទោសពិន័យជាប្រាក់ឬទោសផ្សេងៗទៀតមិនបានកំណត់ឡើយ។

**ឧទាហរណ៍៖** លោក **ក** ត្រូវបានតុលាការសម្រេចប្រកាសផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៤លានរៀលពីបទលួចតាមមាត្រា៣៥៦ នៃក្រ.ព្រ.ទ នៅក្នុងឆ្នាំ២០២០។ ក្រោយមកនៅ ឆ្នាំ២០២៣ តុលាការបានរកឃើញថា

[43] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០៦។
[44] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១២។

បុគ្គលនោះបានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនា និងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លានរៀល។

ក្នុងករណីឧទាហរណ៍ខាងលើ ទណ្ឌិតបានប្រព្រឹត្តលួចក្នុងឆ្នាំ២០២០ ប៉ុន្តែត្រូវបានតុលាការប្រកាសទោសពិន័យជាប្រាក់តែមួយចំនួន ៤ លានរៀល ដោយពុំមានទោសដាក់ពន្ធនាគារឡើយ។ ៣ឆ្នាំក្រោយមក នៅឆ្នាំ២០២៣ ទណ្ឌិត **ក** បានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនា ដែលលើកនឹងតុលាការប្រកាសទាំងទោសពិន័យជាប្រាក់ចំនួន ៣លានរៀល និងទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ។ ដោយហេតុតែក្នុងបទល្មើសលួចខាងលើ តុលាការសម្រេចប្រកាសតែទោសពិន័យជាប្រាក់ នោះទោះបីជាបទហិង្សាដោយចេតនាដែលជាបទមជ្ឈិមថ្មីដែលទណ្ឌិតបានប្រព្រឹត្តក្រោយនិងមានគម្លាតរយៈពេលត្រឹមតែ ៣ឆ្នាំប៉ុណ្ណោះពីបទល្មើសក៏ដោយមុន ក៏តុលាការអាចប្រកាសព្យួរទោសធម្មតា (ទោសដាក់ពន្ធនាគារចំនួន២ឆ្នាំ និងទោសពិន័យចំនួន ៣លានរៀល) ដែលជាប្រយោជន៍របស់ទណ្ឌិត **ក** បានដែរ។ ទោសពិន័យជាប្រាក់ក្នុងបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋទោះបីជាស្ថិតក្នុងរយៈពេលប៉ុណ្ណាក៏ដោយ ក៏ពុំអាចក្លាយឧបសគ្គក្នុងការប្រកាសព្យួរទោសធម្មតាបានដែរ។

### ១.២. អានុភាពនៃការព្យួរទោសធម្មតា

រូបវន្តបុគ្គលជាទណ្ឌិតដែលទទួលបានការប្រកាសព្យួរទោសទាំងមូល ឬមួយផ្នែកពីតុលាការ អានុភាពនៃសេចក្តីសម្រេចនឹងធ្វើឲ្យទណ្ឌិតរួចផុតពីការអនុវត្តទោសក្នុងពន្ធនាគារ ដោយត្រូវអនុវត្តទោសនៅខាងក្រៅពន្ធនាគារវិញ។ ទណ្ឌិតនឹងត្រូវបានដោះលែងឲ្យចូលទៅក្នុងសង្គមវិញ នៅពេលសេចក្តីសម្រេចរបស់តុលាការបានចូលជាស្ថាពរ ប៉ុន្តែការដោះលែងនេះ ទណ្ឌិតត្រូវតែគោរពតាមលក្ខខណ្ឌការព្យួរទោសធម្មតា ពោលពុំមែនជាការដោះលែងឲ្យសេរីភាពដូចជនដែលបានអនុវត្តទោសរួចរាល់នោះទេ។ បន្ទាប់ពីទទួលបានការប្រកាសព្យួរទោសធម្មតា ទណ្ឌិតមិនត្រូវប្រព្រឹត្តបទល្មើសមជ្ឈិម ឬបទឧក្រិដ្ឋថ្មីណាមួយក្នុងរយៈពេលសាកល្បងចំនួន ៥ឆ្នាំ និងបទលហុក្នុងរយៈពេលសាកល្បងចំនួន ១ឆ្នាំ ដែលអាចនាំឲ្យទោសនៃបទល្មើសនោះចូលជាស្ថាពរបានឡើយ គិតចាប់ពីការព្យួរទោសធម្មតាត្រូវបានប្រកាសឲ្យអនុវត្តដោយតុលាការ។[45] ប្រសិនបើមិនមានការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកានៃបទល្មើសថ្មី រហូតដល់រយៈពេលសាកល្បងការព្យួរធម្មតាបានអស់សុពលភាពនោះទេ ទោសដែលតុលាការប្រកាសព្យួរទោសត្រូវចាត់ទុកជាអសាបង់ទាំងអស់ គឺទណ្ឌិតមិនត្រូវបានជាប់កាតព្វកិច្ចក្នុងការអនុវត្តទោសទៀតទេ។[46] ម្យ៉ាងវិញទៀត ក្នុងករណីដែលតុលាការសម្រេចព្យួរតែទោសដាក់ពន្ធនាគារនោះទេ ទោសដែលចាត់ថាអសាបង់មានតែទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ ចំណែកទោសពិន័យជាប្រាក់ ឬទោសផ្សេងៗទៀតទណ្ឌិតត្រូវអនុវត្តទៅតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ។

[45] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០៩ និងមាត្រា១១៤។

[46] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១១ និងមាត្រា១១៦។

ផ្ទុយទៅវិញ ទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដោយបទល្មើសថ្មីក្នុងកំឡុងពេលសាកល្បងព្យួរទោសធម្មតា តុលាការត្រូវតែធ្វើឆន្ទានុសិទ្ធិឡើងវិញអំពីការព្យួរទោសថាត្រូវបន្តឬដកហូតការព្យួរទោសធម្មតានោះមកវិញ។ ប្រសិន បើតុលាការសម្រេចប្រកាសបន្តការព្យួរទោស តុលាការត្រូវមានសំអាងហេតុពិសេសរបស់ខ្លួននៅក្នុងសេចក្តីសម្រេច។[47] ច្រាសមកវិញ តុលាការក៏អាចសម្រេចដកហូតការព្យួរទាំងមូលឬមួយផ្នែកមកវិញបានដោយស្របតាមច្បាប់ ក្នុងករណីនេះ ទណ្ឌិតត្រូវអនុវត្តទោសទី១ ដែលតុលាការប្រកាសព្យួរកន្លងមកផង និងត្រូវអនុវត្តទោសទី២ ដែលតុលាការប្រកាសចំពោះបទល្មើសថ្មី។

**ឧទាហរណ៍៖** បុរសម្នាក់ត្រូវបានតុលាការសម្រេចប្រកាសទោសរួមក្នុងបទល្មើសត្រួតគ្នា ដោយផ្តន្ទាទោសដាប់ពន្ធនាគារចំនួន ៤ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥លានរៀល។ តុលាការសម្រេចប្រកាសការព្យួរទោសធម្មតាចំពោះទោសពន្ធនាគារចំនួន ៤ឆ្នាំ និងបានដោះលែងបុរសចូលទៅក្នុងសង្គមវិញ។ ៣ឆ្នាំក្រោយមក បុរសនោះបានប្រព្រឹត្តបទល្មើសគំរាមគំហែងថានឹងសម្លាប់តាមមាត្រា២៣៣ នៃក្រ.ព្រ.ទ. និងត្រូវបានតុលាការសម្រេចប្រកាសទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លាន ៥០ម៉ឺនរៀល។

នៅក្នុងឧទាហរណ៍ខាងលើនេះ គេត្រូវបែកចែងសម្មតិកម្មក្នុងការអនុវត្តទោសជា ២ចំណុចខុសគ្នាគឺ៖

**ចំណុចទី១៖** ការប្រកាសទោសចំពោះបទល្មើសត្រួតគ្នា តុលាការបានប្រកាសព្យួរទោសធម្មតាដាក់ពន្ធនាគារដែលរយៈពេលចំនួន ៤ឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែទោសពិន័យជាប្រាក់តុលាការពុំបានប្រកាសអំពីការព្យួរនោះទេ។ ហេតុនេះ បុរសនោះត្រូវអនុវត្តកាតព្វកិច្ចដោយបង់ប្រាក់ពិន័យចំនួន ៥លានរៀល ទៅតាមអំណាចនៃសាលក្រមរបស់តុលាការដំបូង។

**ចំណុចទី២៖** បន្ទាប់ពីបានទទួលការព្យួរទោសធម្មតាប្រមាណ ៣ឆ្នាំក្រោយមក បុគ្គលខាងលើត្រូវបានតុលាការផ្តន្ទាទោសម្តងទៀតក្នុងកំឡុងរយៈពេលសាកល្បងចំនួន ៥ឆ្នាំដែលកំណត់ក្នុងច្បាប់អំពីលក្ខខណ្ឌនៃការព្យួរទោស។ ក្នុងកាលទេសៈនេះ តុលាការអាចប្រកាសដកហូតការព្យួរទោសធម្មតាពីទណ្ឌិតមកវិញបាន។ មានន័យថាបុរសនោះត្រូវមានកាតព្វកិច្ចអនុវត្តទោសដែលបានប្រកាសព្យួរពីមុន រួចហើយត្រូវអនុវត្តទោសដែលតុលាការប្រកាសចំពោះបទគំរាមគំហែងថានឹងសម្លាប់ដែលជាបទល្មើសថ្មីបន្ថែមពីលើទៀត។ ដូច្នេះ បុរសខាងលើត្រូវអនុវត្តទោសក្នុងពន្ធនាគារសរុបចំនួន ៦ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លាន ៥០ម៉ឺនរៀល។

តុលាការក៏អាចប្រកាសព្យួរទោសតែមួយផ្នែកបានផងដែរ ទៅតាមការវិនិច្ឆ័យនិងការយល់ឃើញរបស់ខ្លួន។ ការព្យួរទោសមួយផ្នែក គឺស្ថានភាពមួយដែលតុលាការបានកំណត់យកទោសមួយផ្នែកក្នុងចំនួនណាមួយនៃទោសដែលបានប្រកាស (ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់) មកព្យួរទោស រីឯទោសដែលនៅសល់

[47] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១០។

ពីការប្រកាសព្យួរទោស តុលាការត្រូវកំណត់ថេរវេលានិងប្រកាសឲ្យទណ្ឌិតអនុវត្តទោសរបស់ខ្លួនជាធម្មតា។[48] ទណ្ឌិតត្រូវអនុវត្តទោសដែលតុលាការកំណត់ឲ្យអនុវត្តសិន ទើបអាចទទួលបានការព្យួរទោសមួយផ្នែកនោះតាមក្រោយ។

## កថាខណ្ឌទី២. ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង គឺជាការដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវលក្ខ-ខណ្ឌដោយឡែកមួយ ឬច្រើនក្នុងរយៈពេលព្យួរទោសសាកល្បងមុនអនុវត្តទោសព្យួរ។[49] ការព្យួរទោសសាកល្បងមានលក្ខខណ្ឌក្នុងការស្នើសុំខុសគ្នាជាមួយការព្យួរទោសធម្មតា។ តុលាការអាចប្រកាសការព្យួរទោសសាកល្បងចំពោះតែទោសដាក់ពន្ធនាគារតែមួយប៉ុណ្ណោះ ចំពោះទោសពិន័យជាប្រាក់វិញ ឬទោសបន្ថែម និងទោសជំនួស តុលាការមិនអាចការព្យួរទោសសាកល្បងបានឡើយ។[50]

### ២.១. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

ដើម្បីអាចព្យួរទោសសាកល្បងបាន លុះត្រាណាទណ្ឌិតត្រូវបានតុលាការប្រកាសទោសដាក់ពន្ធនាគារនៅចន្លោះពី ៦ខែ ទៅ ៥ឆ្នាំ មានន័យថាការព្យួរទោសនេះអាចអនុវត្តបានតែបទលមជ្ឈឹមនិងបទឧក្រិដ្ឋតែប៉ុណ្ណោះ រីឯបទលហុតុលាការមិនអាចប្រកាសការព្យួរទោសសាកល្បងបានទេ ដោយហេតុថាបទលហុមានអតិបរមាជាប់ពន្ធនាគារត្រឹម ៦ថ្ងៃប៉ុណ្ណោះ។ តុលាការកំណត់ចិរវេលាអំពីការព្យួរទោសសាកល្បង ដោយត្រូវកំណត់មិនឲ្យមានរយៈពេលតិចជាង ១ឆ្នាំ ហើយក៏មិនឲ្យលើសពី ៣ឆ្នាំផងដែរ។[51] នៅក្នុងរយៈពេលអនុវត្តការព្យួរទោសសាកល្បង តុលាការត្រូវដាក់ទណ្ឌិតឲ្យស្ថិតក្រោមវិធានតាមដានត្រួតពិនិត្យរបស់តំណាងអយ្យការ និងជ្រើសរើសវិធានកាតព្វកិច្ចដោយឡែកមួយឬច្រើន ដើម្បីឲ្យទណ្ឌិតអនុវត្តប្រសិនជាការចាំបាច់។

#### ២.១.១. វិធានការតាមដានត្រួតពិនិត្យរបស់តំណាងអយ្យការ

តុលាការត្រូវប្រកាសការព្យួរទោសសាកល្បង ដោយភ្ជាប់នឹងការដាក់ឲ្យទណ្ឌិតស្ថិតក្រោមវិធានតាមដានត្រួតពិនិត្យដោយតំណាងអយ្យការដូចខាងក្រោម៖[52]

- ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ
- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ

[48] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០៨។
[49] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១៧ កថាខណ្ឌទី២។
[50] សៀវភៅស្ដីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រ៥០៧ និង៥០៨។
[51] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១៧ កថាខណ្ឌទី១ និងមាត្រា១១៨។
[52] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១១៩។

- ទណ្ឌិតត្រូវមកប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឲ្យទៅរស់នៅក្នុងសង្គមវិញ
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។

### ២.១.២. វិធានកាតព្វកិច្ចដោយឡែក

ក្រៅពីតុលាការប្រកាសវិធានការតាមដានត្រួតពិនិត្យក្នុងនៅសាលក្រម ឬសាលដីកា តុលាការត្រូវជ្រើសរើសវិធានកាតព្វកិច្ចដោយឡែកមួយ ឬច្រើនផ្សេងទៀត ប្រសិនបើតុលាការយល់ថាទណ្ឌិតត្រូវតែអនុវត្តដែលមានដូចជា៖[53]

- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់
- បញ្ជាក់ថាខ្លួនចូលរួមចំណែកក្នុងការចិញ្ចឹមបីបាច់ថែរក្សាគ្រួសារ
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន
- បញ្ជាក់ថាខ្លួនបានបង់ប្រាក់ពិន័យជូនរដ្ឋ បន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពនៃធនធានរបស់ខ្លួន
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់
- មិនត្រូវសេពគប់បនល្បែង
- មិនត្រូវសេពគប់គ្រឿងស្រវឹង
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេសចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គល ដែលមិនត្រូវសេពគប់ជាមួយ
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ដោយយោងតាមមាត្រា១២០ នៃក្រ.ព្រ.ទ កាតព្វកិច្ចដោយឡែកដែលតុលាការជ្រើសរើសដាក់ឲ្យទណ្ឌិតបំពេញនោះ តុលាការត្រូវប្រមើមើលថា តើមានអ្វីពាក់ព័ន្ធដែលអាចឲ្យទណ្ឌិតប្រព្រឹត្តបទល្មើសបាន។ ជារួមតុលាការមិនមែនចេះតែដាក់កាតព្វកិច្ចទាំងអស់តាមតែចិត្តចង់ ឬនឹកឃើញដាក់ទៅលើទណ្ឌិតនោះទេ ប៉ុន្តែតុលាការមានសិទ្ធិស្វ័យសម្រេចក្នុងការជ្រើសរើសមួយ ឬច្រើនលើសពីមួយបាន ទៅតាមការវិនិច្ឆ័យចរិកលក្ខណៈរបស់ទណ្ឌិត។ តុលាការដាក់កាតព្វកិច្ចដោយឡែកខាងលើ ទៅលើតែនីតិជនដែលគាត់ប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ។

[53] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២០។

ឯចំពោះអនីតិជនវិញ កាតព្វកិច្ចដោយឡែកត្រូវបានកំណត់មកត្រឹម ៩ចំណុចតែប៉ុណ្ណោះមានដូចជា៖[54]

- ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថិតនៅទីកន្លែងមួយជាកំណត់
- ដាក់ខ្លួនឲ្យពេទ្យពិនិត្យ ឬព្យាបាល
- ជួសជុលព្យសនកម្មដែលអាចបណ្តាលមកអំពីបទល្មើសទៅតាមធនធានរបស់ខ្លួន
- បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួនបន្ទាប់ពីផ្តន្ទាទោស
- មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ដែលតុលាការហាមប្រាម
- មិនត្រូវសេពគប់ទីកន្លែងដែលលក់គ្រឿងស្រវឹង
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះ នៃបទល្មើស
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

**សូមបញ្ជាក់ថា៖** នៅគ្រប់ពេលវេលានៃការព្យួរទោសសាកល្បង តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិត ប្រសិនបើកាតព្វកិច្ចណាមួយដែលប្រកាសពីមុនលែងសមស្របទៀតហើយ តុលាការអាចប្រកាសកែប្រែកាតព្វកិច្ចនោះឲ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងវិញ។[55]

ក្នុងកំឡុងពេលអនុវត្ត ប្រសិនតុលាការបានទទួលបណ្តឹង នៅក្នុងលក្ខខណ្ឌដែលបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាការលំបាកទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តទោសត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ដែលបានសម្រេចផ្តន្ទាទោសនោះដោះស្រាយ។ តាមពាក្យបណ្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ និងតុលាការត្រូវធ្វើការសម្រេចនៅក្នុងសវនាការសាធារណៈក្រោយពីបានស្តាប់តំណាងអយ្យការភាគីពាក់ព័ន្ធ និងមេធាវីរបស់ភាគីនោះ។[56]

## ២.២. អានុភាពការព្យួរទោសសាកល្បង

មានលក្ខណៈស្រដៀងទៅនឹងការព្យួរទោសធម្មតាដែរ ទណ្ឌិតដែលទទួលបានការព្យួរទោសសាកល្បងនឹងត្រូវដាក់ឲ្យរស់នៅក្នុងសង្គមប៉ុន្តែត្រូវអនុវត្តតាមវិធាននានាដែលដាក់ចេញដោយតុលាការ។ ទណ្ឌិតត្រូវអនុវត្តវិធានទាំងនោះឲ្យអស់ពីដួងចិត្តរបស់ខ្លួន និងត្រូវធ្វើជាពលរដ្ឋល្អពេលចូលទៅក្នុងសង្គមវិញ បើពុំដូច្នេះទេអំពើផ្ទុយទាំងនោះអាចនឹងជាកម្មវត្ថុនៃការដកហូតការព្យួរទោសសាកល្បងទាំងមូល ឬមួយផ្នែករបស់តុលាការ។

[54] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៦៥។
[55] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២១។
[56] ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥០០។

យោងតាមមាត្រា១២២ នៃក្រ.ព្រ.ទ. ការព្យួរទោសសាកល្បងអាចត្រូវបានដកហូតដោយតុលាការ នៅក្នុងករណីដែលទណ្ឌិតប្រព្រឹត្តផ្ទុយលក្ខខណ្ឌដូចខាងក្រោម៖

**ករណីទី១៖** ក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ។ តុលាការដកហូតការព្យួរទោសសាកល្បងបាន បើមានបណ្តឹងពីព្រះរាជអាជ្ញាទាក់ទងជាមួយការមិនគោរពកាតព្វកិច្ចរបស់ទណ្ឌិតក្នុងរយៈពេលសាកល្បង ព្រោះថាពេលទណ្ឌិតស្ថិតក្រោមវិធានតាមដានត្រួតពិនិត្យនិងវិធានកាតព្វកិច្ចដោយឡែក ទណ្ឌិតត្រូវដាក់ឲ្យស្ថិតក្រោមការឃ្លាំមើលយ៉ាងម៉ត់ចត់ពីព្រះរាជអាជ្ញា ឬបុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចអោយ។

**ករណីទី២៖** ក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមសារជាថ្មីទៀត។ មានន័យថាមិនទាន់ហួសរយៈពេលកំណត់សាលល្បងផង ទណ្ឌិតបានទៅប្រព្រឹត្តបទល្មើសថ្មីផ្សេងទៀត ដែលជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ វានឹងក្លាយជាកម្មវត្ថុរបស់ព្រះរាជអាជ្ញាក្នុងការប្តឹងស្នើសុំឲ្យដកហូតការព្យួរទោសសាកល្បង។ សម្រាប់បណ្តឹងស្នើសុំឲ្យដកហូតការព្យួរទោសសាកល្បងវិញ គឺព្រះរាជអាជ្ញាត្រូវរៀបចំឡើងដោយប្រតិបត្តិទៅតាមលក្ខខណ្ឌដូចដែលមានចែងនៅមាត្រា៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ចំពោះទណ្ឌិតដែលត្រូវបានដកហូតការព្យួរទោសទាំងមូល ឬផ្នែក ទណ្ឌិតត្រូវតែអនុវត្តទោសនោះឡើងវិញទៅតាមការប្រកាសទោសដែលមានកំណត់ក្នុង សេចក្តីសម្រេចរបស់តុលាការ។

ម្យ៉ាងវិញទៀត ប្រសិនបើផុតរយៈពេលនៃការសាកល្បងកំណត់ដោយតុលាការ ដោយមិនឲ្យតិចជាង១ឆ្នាំ ឬស្មើ ៣ឆ្នាំនឹង ទណ្ឌិតពុំមានបណ្តឹងរបស់ព្រះអាជ្ញាស្នើសុំដកហូតការព្យួរទោសសាកល្បងនោះទេ នោះការផ្តន្ទា-ទោសពន្ធនាគាររបស់តុលាការនឹងត្រូវបានចាត់ទុកជាអសារបង់មិនអាចអនុវត្តបានទៀតទេ។ ទណ្ឌិតនឹងត្រូវបានរាប់ថា បានអនុវត្តទោសរួចរាល់ និងដោះលែងឲ្យមានសេរីភាពពេញលេញក្នុងសង្គមឡើងវិញ ពោលពុំត្រូវបានដាក់ឲ្យបំពេញវិធានតាមដានត្រួតពិនិត្យនិងកាតព្វកិច្ចឲ្យព្រះរាជអាជ្ញា ឬបុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចឲ្យទៀតឡើយ។[57]

**ឧទាហរណ៍៖** តុលាការសាលាដំបូងបានប្រកាសទោសក្នុងការចោទប្រកាន់តែមួយចំពោះជនម្នាក់ដែលបានប្រព្រឹត្តបទល្មើសលួចតាមមាត្រា៣៥៦ នៃក្រ.ព្រ.ទ ចំនួន ១ដង និងបទលួចមានស្ថានទម្ងន់ទោសតាមមាត្រា៣៥៧ នៃក្រ.ព្រ.ទ. ចំនួន១ដង។ តុលាការបានសម្រេចប្រកាសស្រូបទោសដោយឲ្យជាប់ពន្ធនាគារចំនួន ៥ឆ្នាំ ចំពោះការប្រព្រឹត្តបទល្មើសលួចទាំង ២ដងកន្លងមក។ បន្ថែមពីនេះទៀត តុលាការបានប្រកាសការព្យួរទោសសាកល្បងមួយផ្នែកចំនួន២ឆ្នាំ ដែលមានរយៈពេលសាកល្បងចំនួន១ឆ្នាំកន្លះ និងបានដាក់ឲ្យទណ្ឌិតស្ថិតក្រោមវិធានកាតព្វកិច្ចត្រូវបំពេញឲ្យព្រះរាជអាជ្ញា។

[57] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២៣។

តាមសម្មតិកម្មខាងលើ ទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារតាមអំណាចសាលក្រមរបស់តុលាការចំនួន ៣ឆ្នាំសិន ទើបទទួលបានការព្យួរទោសសាកល្បងដោយមានរយៈពេលសាកល្បងចំនួន ១ឆ្នាំកន្លះ ដែលជាការដោះលែងទណ្ឌិតចូលទៅក្នុងសង្គមវិញ។ ទណ្ឌិតត្រូវគោរព និងប្រតិបត្តិឲ្យបាន នូវវិធានតាមដានត្រួតពិនិត្យ និងកាតព្វកិច្ចបានកំណត់ក្នុងសាលក្រមយ៉ាងម៉ត់ចត់បំផុតក្នុងរយៈពេលសាកល្បងចំនួន ១ឆ្នាំកន្លះនេះ។ ឧបមាថារយៈពេលសាកល្បង ១ឆ្នាំកន្លះបានកន្លងផុតទៅ ពុំមានពាក្យបណ្តឹងពីព្រះរាជអាជ្ញាស្នើសុំដកហូតការព្យួរទោសពីទណ្ឌិតទៅតុលាការនោះទេ ទោសដែលតុលាការប្រកាសនោះនឹងត្រូវបានចាត់ទុកថាអសារបង់ដោយមិនអាចយកមកអនុវត្តបានទៀតទេ។ ច្រាសមកវិញ ប្រសិនបើមានពាក្យបណ្តឹងទៅតុលាការស្នើសុំដកហូតការព្យួរទោសដោយហេតុថាទណ្ឌិតបានប្រព្រឹត្តអំពើផ្ទុយពីលក្ខខណ្ឌការព្យួរទោសក្នុងរយៈពេលសាកល្បងចំនួន ១ឆ្នាំកន្លះ ទណ្ឌិតត្រូវតែអនុវត្តទោសក្នុងពន្ធនាគារចំនួន ២ឆ្នាំដែលតុលាការប្រកាសឲ្យព្យួរទោសសាកល្បងពីមុននោះឡើងវិញ។

## ផ្នែកទី២. ការកម្រិតសិទ្ធិសេរីភាព

ការកម្រិតសិទ្ធិសេរីភាពក៏ជាជម្រើសមួយនៃការផ្តន្ទាទោសរបស់តុលាការ ទៅលើរូបវន្តបុគ្គលដែលត្រូវបានរកឃើញថាមានពិរុទ្ធភាពផងដែរ។ ការកម្រិតសិទ្ធិសេរីភាព សំដៅដល់ការអនុញ្ញាតឲ្យទណ្ឌិតចេញទៅខាងក្រៅពន្ធនាគារត្រឹមរយៈពេលកំណត់ណាមួយរបស់តុលាការ បន្ទាប់ពីអស់រយៈពេលមានសេរីភាពទណ្ឌិតត្រូវតែចូលមកពន្ធនាគារវិញដោយមិនអាចខកខានបានឡើយ។ ព្រះរាជអាជ្ញាមានតួនាទីក្នុងការចាំឃ្លាំសង្កេតមើលការចេញទៅខាងក្រៅ និងចូលក្នុងពន្ធនាគារវិញរបស់ទណ្ឌិត និងត្រូវដាក់ពាក្យបណ្តឹងស្នើសុំលុបចោលរបបទោសបែបនេះទៅកាន់តុលាការ ប្រសិនបើរកឃើញថាទណ្ឌិតមិនបានបំពេញតាមការកំណត់ ឬមិនបានចូលពន្ធនាគារវិញតាមពេលវេលាកំណត់នោះទេ។ ប៉ុន្តែការប្រកាសទោសក្រោមទម្រង់បែបនេះ តុលាការត្រូវតែពិនិត្យមើលលក្ខខណ្ឌច្បាប់ឲ្យបានច្បាស់លាស់ និងវិនិច្ឆ័យទៅលើស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ។ តាមក្រមព្រហ្មទណ្ឌយើង ការប្រកាសរបបទោសដែលមានលក្ខណៈបែបនេះត្រូវបាននីតិនិពន្ធកម្ពុជាបែងចែកមាន ២ប្រភេទទី១ គេហៅថា របបពាក់កណ្តាលសេរីភាព (កថាខណ្ឌទី១) និងទី២ របបនៃការបែងចែកទោសជាប្រភាគ (កថាខណ្ឌទី២) ។

### កថាខណ្ឌទី១. របបពាក់កណ្តាលសេរីភាព

ជាទ្រឹស្តីរបបពាក់កណ្តាលសេរីភាព គឺជាការអនុញ្ញាតរបស់តុលាការ ឲ្យទណ្ឌិតចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់និងទៀងទាត់ ដើម្បីជួយសម្រួលឲ្យទណ្ឌិតមានពេលវេលាអាចបំពេញសកម្មភាពភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់ក្រុមគ្រួសារខ្លួន។ ដើម្បីអាចយល់ដឹងកាន់តែច្បាស់អំពីរបបពាក់កណ្តាលសេរី យើងនឹងសិក្សាលម្អិតទៅលើលក្ខខណ្ឌតាមផ្លូវច្បាប់ចំពោះការអាចប្រកាសរបបនេះបាន (១.១.) និងអនុភាពរបស់វានៅក្នុងពេលអនុវត្តទោស (១.២.) ជាដើម។

### ១.១. លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព

ដើម្បីអាចឲ្យតុលាការប្រកាសអំពីការអនុវត្តរបបពាក់កណ្តាលសេរីភាពបាន លុះត្រាណាតែទណ្ឌិតត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹង ៦ខែតែប៉ុណ្ណោះ។ ប្រសិនបើការប្រកាសទោសនោះមានរយៈពេលលើសពី ៦ខែ តុលាការមិនអាចជ្រើសយកការរបបពាក់កណ្តាលសេរីភាពឲ្យទណ្ឌិតអនុវត្តបាននោះទេ ទោះបីជាមានការស្នើសុំរបបនេះក៏ដោយ។ ដូចនឹងទ្រឹស្តីបានរៀបរាប់ខាងលើ របបពាក់កណ្តាលសេរីភាពពុំបានដោះលែងឲ្យទណ្ឌិតចូលទៅក្នុងសង្គមដោយគ្មានលក្ខខណ្ឌនោះទេ ពោលទណ្ឌិតត្រូវបានដោះលែងដើម្បីឲ្យទៅបំពេញកាតព្វកិច្ចជាប្រចាំថ្ងៃរបស់ខ្លួននៅខាងក្រៅពន្ធនាគារតែប៉ុណ្ណោះ កាតព្វកិច្ចទាំងនេះរួមមានការបំពេញសកម្មភាពវិជ្ជាជីវៈ ការសិក្សា និងបណ្តុះបណ្តាល ការពិនិត្យព្យាបាលជំងឺ ឬការទៅបំពេញការងារដើម្បីជួយឧបត្ថម្ភដល់ជីវភាពក្រុមគ្រួសារជាដើម។[58]

យោងតាមមាត្រា១២៨ នៃក្រ.ព្រ.ទ តុលាការត្រូវតែកំណត់ឲ្យបានច្បាស់លាស់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីចំនួនថ្ងៃ ចំនួនម៉ោងចេញ-ចូលពន្ធនាគារ និងប្រភេទកាតព្វកិច្ចដែលត្រូវបំពេញ។[59] ទណ្ឌិតត្រូវតែគោរពនិងប្រតិបត្តិតាមការកំណត់ទាំងនោះ បើពុំដូច្នេះទេអំពើផ្ទុយនោះ អាចនឹងក្លាយជាកម្មវត្ថុនៃការស្នើសុំលុបចោលរបបពាក់កណ្តាលសេរីភាពរបស់ព្រះរាជអាជ្ញាទៅតុលាការ។

### ១.២. អានុភាពនៃការប្រកាសរបបពាក់កណ្តាលសេរីភាព

បន្ទាប់ពីទណ្ឌិតទទួលបានការប្រកាសឲ្យអនុវត្តរបបនេះ ទណ្ឌិតមានសិទ្ធិក្នុងការចេញទៅខាងក្រៅពន្ធនាគារជារៀងរាល់ថ្ងៃបានតាមការកំណត់ក្នុងសាលក្រម ប៉ុន្តែនេះមិនមែនករណីឲ្យទណ្ឌិតត្រូវបានបន្ធូរបន្ថយទោស ឬលើកលែងចំពោះការអនុវត្តទោសនោះទេ។ ព្រះរាជអាជ្ញាជាសេនាធិការរបស់តុលាការ មានតួនាទីចាំមើលនិងតាមដានទណ្ឌិតក្នុងការអនុវត្តកាតព្វកិច្ចនៅខាងក្រៅ និងពិនិត្យទៅលើចំនួនថ្ងៃនិងចំនួនម៉ោងចេញចូលពន្ធនាគារ។ ប្រសិនបើរកឃើញថាទណ្ឌិតពុំបានគោរពម៉ោងចូលពន្ធនាគារ ឬមិនបានបំពេញកាតព្វកិច្ចដែលតុលាការបានកំណត់ ឬបានប្រព្រឹត្តបទល្មើសដទៃបន្ថែម ឬអំពើផ្សេងទៀតដែលពុំគប្បី ព្រះរាជអាជ្ញាត្រូវប្តឹងទៅតុលាការដើម្បីស្នើសុំលុបចោលរបបពាក់កណ្តាលសេរីភាព។ បន្ថែមពីនេះយោងតាមមាត្រា១៣១ នៃក្រ.ព្រ.ទ បើករណីទណ្ឌិតមិនបានចូលពន្ធនាគាររហូតដល់ម៉ោងដែលផ្តល់សេរីភាពត្រូវបានផុត ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យអាជ្ញាធរមានសមត្ថកិច្ចតាមចាប់ទណ្ឌិតមកដាក់ក្នុងពន្ធនាគារវិញ។[60] ម្យ៉ាងទៀតទណ្ឌិតអាចនឹងត្រូវបានចោទប្រកាន់និងផ្តន្ទាទោសអំពីបទល្មើសថ្មី គឺអំពើដែលប្រដូចទៅនឹងការរត់គេចចេញពីពន្ធនាគារតាមមាត្រា៥៦២ នៃក្រ.ព្រ.ទ បន្ថែមពីទោសដែលកំពុងអនុវត្តទៀតផង។

[58] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២៧។

[59] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២៨។

[60] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣១។

ផ្ទុយទៅវិញ ប្រសិនបើទណ្ឌិតបានគោរពយ៉ាងល្អនូវកាតព្វកិច្ចទាំងឡាយតែតុលាការបានដាក់ឲ្យអនុវត្ត ប៉ុន្តែក្រោយមកកាតព្វកិច្ចនោះ ត្រូវបានប្រែប្រួលនៅចន្លោះម៉ោង ឬចំនួនម៉ោង ឬចំនួនថ្ងៃផ្សេងៗទៀតដែលខុសអំពីការកំណត់ដើម ព្រះរាជអាជ្ញាត្រូវប្ដឹងទៅតុលាការអំពីបញ្ហានេះដើម្បីរៀបចំរូបមន្តអនុវត្តរបបពាក់កណ្ដាលសេរីភាពឡើងវិញស្របតាមសភាពប្រែប្រួលជាក់ស្ដែងរបស់ទណ្ឌិត។[61] បន្ថែមពីនេះ យោងតាមបញ្ញត្តិមាត្រា១២៩ នៃក្រ.ព្រ.ទ រយៈពេលដែលទណ្ឌិតបាននៅក្រៅពន្ធនាគារត្រូវរាប់បញ្ចូលជាមួយនឹងរយៈពេលដែលទណ្ឌិតជាប់ឃុំឃាំងក្នុងពន្ធនាគារ ពោលគឺមានន័យថាក្នុងកំឡុងពេលទណ្ឌិតបានអនុវត្តរបបពាក់កណ្ដាលសេរីភាពបានចំនួន ៦ខែដោយគ្មានការស្នើសុំលុបចោលរបបនេះទេ ទណ្ឌិតត្រូវបានចាត់ទុកថាបានអនុវត្តទោសក្នុងពន្ធនាគារចំនួន ៦ខែ និងត្រូវដោះលែងឲ្យមានសេរីភាពពេញលេញដូចពលរដ្ឋធម្មតាវិញ។[62] ប្រាសមកវិញ បើការអនុវត្តរបបពាក់កណ្ដាលសេរីភាពទើបបានចំនួន ៣ខែ តុលាការបានសម្រេចលុបចោលរបបនេះវិញ ទណ្ឌិតត្រូវតែអនុវត្តទោសក្នុងពន្ធនាគារដោយពេញលេញចំនួន ៣ខែដែលនៅសល់ ទើបត្រូវបានដោះលែងឲ្យចូលទៅរស់នៅក្នុងសង្គមវិញ។

**ឧទាហរណ៍**៖ តុលាការបានប្រកាសការផ្ដន្ទាទោសទៅលើនិស្សិតម្នាក់ និងដាក់អនុវត្តរបបពាក់កណ្ដាលសេរីភាពចំនួន ៦ខែដោយឲ្យនិស្សិតនោះចេញទៅសិក្សានៅម៉ោង ៧ព្រឹក និងចូលពន្ធនាគារវិញនៅម៉ោង ៦ល្ងាច បន្ទាប់ពីរូបគេបានប្រព្រឹត្តបទគំរាមកំហែងថានឹងធ្វើឲ្យខូចខាតតាមមាត្រា៤២៣ នៃក្រ.ព្រ.ទ ចំនួន ២ដងនៅទីតាំងក្នុងខេត្ត២ផ្សេងគ្នា។ ក្រោយមកព្រះរាជអាជ្ញាបានដឹងថានិស្សិតនោះ ពុំបានចូលសាលាអស់រយៈពេល ២ខែមកហើយបន្ទាប់ពីទទួលបានការប្រកាសឲ្យអនុវត្តរបបនេះមក។

តាមឧទាហរណ៍ខាងលើ ព្រះរាជអាជ្ញាត្រូវដាក់ពាក្យប្ដឹងទៅតុលាការស្នើសុំលុបចោលរបបពាក់កណ្ដាលសេរីភាពដែលអនុវត្តកន្លងមក ដោយហេតុថាទណ្ឌិតមិនបានបំពេញកាតព្វកិច្ចរៀនសូត្រដែលតុលាការបានកំណត់ក្នុងសាលក្រមចំនួន ២ខែមកហើយ។ ប្រសិនបើតុលាការយល់ព្រមតាមពាក្យប្ដឹងរបស់ព្រះរាជអាជ្ញា ទណ្ឌិតជានិស្សិតត្រូវតែផ្លាស់ប្ដូរពីការអនុវត្តទោសបែបរបបពាក់កណ្ដាលសេរីភាព មកជាការអនុវត្តទោសក្នុងពន្ធនាគារដោយពេញលេញវិញ ពោលគឺទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារចំនួន ៤ខែទៀតដែលនៅសល់ និងពុំមានសិទ្ធិអាចចេញក្រៅពន្ធនាគារដូចមុនទៀតបានឡើយ។

## កថាខណ្ឌទី២. របបនៃការបែកចែកទោសជាប្រភាគ

ការប្រកាសរបបនៃការបែកចែកទោសជាប្រភាគ គឺមានលក្ខណៈទ្រឹស្ដី និងលក្ខខណ្ឌអនុវត្តស្រដៀងទៅនឹងការប្រកាសទោសរបបពាក់កណ្ដាលសេរីភាព។ ការបែងចែកទោសជាប្រភាគ គឺជាការបែងចែកទោសជាផ្នែកៗ ដែលអាចអនុញ្ញាតឱ្យទណ្ឌិតបានចេញទៅខាងក្រៅពន្ធនាគារ និងត្រូវត្រឡប់ចូលក្នុងវិញក្នុងរយៈពេលកំណត់ណាមួយ ដែលតុលាការបានដែលប្រកាសក្នុងសេចក្ដីសម្រេច។[63]

[61] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣០។

[62] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១២៩។

[63] សៀវភៅស្ដីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៥១៣។

### ២.១. លក្ខខណ្ឌរបបបែងចែកទោសជាប្រភាគ

ទណ្ឌិតអាចស្នើសុំឲ្យតុលាការប្រកាសរបបបាន លុះត្រាតែទណ្ឌិតបានបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលក្រមព្រហ្មទណ្ឌបានបញ្ញត្តិថាត្រូវតែបំពេញជាដាច់ខាត ទើបតុលាការអាចយកការស្នើសុំនោះមកវិនិច្ឆ័យ និងប្រកាសឲ្យទណ្ឌិតអនុវត្តបាន។ លក្ខខណ្ឌច្បាប់ដែលក្រមព្រហ្មទណ្ឌបានកំណត់មានដូចជា៖

**ចំណុចទី១៖** យោងតាមមាត្រា១៣២ នៃក្រ.ព្រ.ទ.បានកំណត់ថា “ **ទណ្ឌិតត្រូវតែមានទទឹ្លករណ៍ ឬមូលហេតុធ្ងន់ធ្ងរណាមួយជាក់លាក់ និងជាករណីចំបាច់បំផុតក្នុងការស្នើសុំអនុវត្តរបបបែងទោសជាប្រភាគ** ”។ មូលហេតុដែលត្រូវបានចាត់ទុកថាធ្ងន់ធ្ងរតាមផ្លូវច្បាប់រួមមាន មូលហេតុក្នុងគ្រួសារ វេជ្ជសាស្ត្រ វិជ្ជាជីវៈ ឬសង្គមជាដើម។ ទោះបីជាទណ្ឌិតមានមូលហេតុដែលពាក់ព័ន្ធនឹងការរៀបរាប់ខាងលើក៏ដោយ ក៏ទណ្ឌិតមិនប្រាកដថាទទួលបានការប្រកាសឲ្យអនុវត្តរបបនេះនោះដែរ ត្បិតការប្រកាសឲ្យអនុវត្តទោសតាមបែបណាមួយ ជាឆន្ទានុសិទ្ធិរបស់តុលាការ ពុំមែនទទួលបានជាការស្វ័យប្រវត្តិរបស់ទណ្ឌិតទេ។

**ចំណុចទី២៖** តុលាការអាចប្រកាសរបបនោះបានចំពោះតែទណ្ឌិតរូបណា ដែលត្រូវបានប្រកាសឲ្យជាប់ពន្ធនាគារតិចជាង ឬស្មើ១ឆ្នាំតែប៉ុណ្ណោះ។ ទំហំទោសពន្ធនាគារដែលមានចំនួនលើស ១ឆ្នាំ តុលាការមិនអាចយករបបបែកចែកទោសជាប្រភាគមកប្រកាសបានទេ ព្រោះថាលក្ខខណ្ឌនេះត្រូវបានបញ្ញត្តិយ៉ាងជាក់ច្បាស់ ក្នុងមាត្រា១៣២ នៃក្រ.ព្រ.ទ. ដែលតុលាការត្រូវតែយកជាមូលដ្ឋានគ្រឹះចំពោះការសម្រេចចិត្ត។

### ២.២. ការអនុវត្តរបបនៃការបែងចែកទោសជាប្រភាគ

ប្រសិនបើលក្ខខណ្ឌតម្រូវទាំង ២ ត្រូវបានបំពេញរួចហើយ តុលាការត្រូវពិនិត្យ និងវាយតម្លៃការប្តឹងស្នើសុំអនុវត្តទោសដោយរបបបែងចែកទោសជាប្រភាគរបស់ទណ្ឌិត។ ករណីដែលយល់ព្រម តុលាការត្រូវតែរៀបចំបែបបទ និងកំណត់រូបមន្តក្នុងអនុវត្តទោស ដោយកំណត់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនឲ្យបានជាក់លាក់។ របបនៃការបែងចែកទោសជាប្រភាគនីមួយៗ តុលាការមិនត្រូវកំណត់រយៈពេលតិចជាង ១ខែឡើយ ពោលគឺមានន័យសាមញ្ញថា តុលាការត្រូវតែប្រកាសទោសជាប្រភាគក្នុងពន្ធនាគារច្រើនជាង១ខែ និងការចេញទៅខាងក្រៅពន្ធនាគារច្រើនជាង១ខែ។ ប៉ុន្តែចំពោះរយៈពេលអនុវត្តទោសក្នុងពន្ធនាគារ និងរយៈពេលចេញទៅខាងក្រៅ តុលាការត្រូវតែកំណត់រូបមន្តដោយមិនឲ្យមានរយៈពេលសរុបលើសពី ២ឆ្នាំឡើយ ដោយរាប់បញ្ចូលទាំងរយៈពេលក្នុងការផ្អាកការប្រកាសទោសផងដែរ។[64]

ក្នុងការអនុវត្តរបបបែងចែកទោសជាប្រភាគ រយៈពេលដែលទណ្ឌិតទៅបំពេញកាតព្វកិច្ចខាងក្រៅពន្ធនាគារតាមការបង្គាប់បញ្ជារបស់តុលាការ មិនត្រូវបានរាប់បញ្ចូលគ្នាជាមួយនឹងរយៈពេលអនុវត្តទោសក្នុងពន្ធ-

[64] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣៣។

នាគារដូចរបបពាក់កណ្ដាលសេរីភាពនោះទេ។[65] មានន័យថាចំនួនទោសដែលតុលាការសម្រេចផ្ដន្ទាទោសពន្ធ-នាគារក្នុងសវនាការ ទាល់តែទណ្ឌិតបានស្ថិតក្នុងពន្ធនាគារទើបគេអាចរាប់ចំនួនអនុវត្តទោសបាន ក្នុងករណីទណ្ឌិតទៅបំពេញកាតព្វកិច្ចនៅក្រៅពន្ធនាគារទោះបីជាតាមអំណាចសាលក្រម ឬសាលដីកាក៏ដោយ ក៏គេមិនអាចរាប់ចូលក្នុងចំនួនទោសពន្ធនាគារដែលបានអនុវត្តរួចនោះដែរ។

**ឧទាហរណ៍**៖ តុលាការបានផ្ដន្ទាទោសទណ្ឌិត **ខ** ដាក់ពន្ធនាគារចំនួន ១ឆ្នាំ ពីបទដេញថ្លៃមិនត្រឹមត្រូវតាមមាត្រា៣៨៧ នៃក្រ.ព្រ.ទ ។ ដោយហេតុទណ្ឌិតត្រូវបំពេញកាតព្វកិច្ចចិញ្ចឹមកូនជាចាំបាច់ តុលាការក៏បានសម្រេចប្រកាសឲ្យទណ្ឌិតអនុវត្តរបបនៃការបែងចែកទោសជាប្រភាគ ដោយចំនួនប្រភាគនីមួយមានចំនួន ២ខែ។

តាមករណីសិក្សានេះ ទណ្ឌិតអាចចេញទៅខាងក្រៅពន្ធនាគារម្ដងមានរយៈពេលចំនួន ២ខែ ដើម្បីបំពេញកាតព្វកិច្ចចិញ្ចឹមកូន និងត្រូវអនុវត្តទោសក្នុងពន្ធនាគារម្ដងចំនួន ២ខែដូចគ្នាផងដែរ។ ពោលគឺទណ្ឌិតត្រូវជាប់កាតព្វ-កិច្ចទោសក្នុងពន្ធនាគារចំនួន ៦ដង ទើបស្មើនឹងចំនួនទោសសរុប ១ឆ្នាំដែលតុលាការបានប្រកាសចំពោះបទដេញថ្លៃមិនត្រឹមត្រូវដែលទណ្ឌិត **ខ** បានប្រព្រឹត្ត។ ហេតុនេះមានន័យថា ទណ្ឌិតត្រូវអនុវត្តរបបបែងចែកទោសជាប្រភាគសរុបចំនួន ២ឆ្នាំ ទើបការប្រកាសទោសពន្ធនាគាររបស់តុលាការត្រូវបានចាត់ទុកថាអសារបង់ទាំងស្រុង។

នៅគ្រប់ពេលវេលាទាំងអស់តុលាការអាចសម្រេចកែប្រែរៀបចំរូបមន្ត សម្រាប់អនុវត្តរបបបែកចែកទោសជាប្រភាគឲ្យស្របតាមសភាពជាក់ស្ដែងរបស់ទណ្ឌិត បន្ទាប់ពីទទួលបានពាក្យបណ្ដឹងស្នើសុំរបស់ព្រះរាជាអាជ្ញាដែលជាអ្នកមានតួនាទីត្រួតពិនិត្យការអនុវត្ត។[66] ប៉ុន្តែបើក្នុងករណីព្រះរាជអាជ្ញារកឃើញថាទណ្ឌិតបានអនុវត្តផ្ទុយឬខុសនូវនឹងកាតព្វកិច្ចដែលត្រូវបំពេញ ឬការមិនមកត្រឡប់ចូលពន្ធនាគារវិញពេលដល់រយៈពេលជាកំណត់ជាដើម ទណ្ឌិតអាចនឹងត្រូវស្នើសុំឲ្យលុបចោលអនុវត្តរបបនេះវិញ។ បន្ថែមពីនេះ ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យនគរបាលយុត្តិធម៌តាមស្វែងរកនិងតាមចាប់ខ្លួនទណ្ឌិតមកឃុំខ្លួនក្នុងពន្ធនាគារ ដើម្បីរង់ចាំការសម្រេចរបស់តុលាការចំពោះកំហុសនេះ។[67] បើតុលាការបានសម្រេចលុបចោលរបបបែកចែកទោសជាប្រភាគ ទណ្ឌិតនឹងត្រូវដាក់ឲ្យអនុវត្តទោសដោយពេញលេញក្នុងពន្ធនាគារដោយមិនអនុញ្ញាតឲ្យចេញក្រៅពន្ធនាគារបានទៀតឡើយ។

---

[65] សៀវភៅស្ដីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ទំព័រទី៥១៣ ដល់ ៥១៤។

[66] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣៤។

[67] ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៣៥។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ “ **បទល្មើសត្រួតគ្នា** ” នេះរួចមក ធ្វើឲ្យខ្ញុំបាទកាន់តែយល់ច្បាស់អំពីចរិកលក្ខណៈបទល្មើស នីតិវិធី របបប្រកាសទោស និងវិធានអនុវត្តក្នុងបទល្មើសត្រួតគ្នា។

បទល្មើសត្រួតគ្នានឹងត្រូវបានឡើង ប្រសិនបើចារីបានប្រព្រឹត្តបទល្មើសនិងមិនទាន់ទទួលបានការផ្តន្ទាទោសចាប់ពីពីរករណីឡើងទៅ ដែលបទល្មើសនីមួយៗមិនត្រូវស្ថិតក្នុងស្ថានភាពអស់អាជ្ញាយុកាលនោះទេ។ ព្រះរាជអាជ្ញាដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកពិរុទ្ធភាពច្រើនករណីរបស់ចារីដើម្បីធ្វើការចោទប្រកាន់។ ការចោទប្រកាន់បទល្មើសត្រួតគ្នាមានចំនួន ២បែប គឺការចោទប្រកាន់តែមួយ និងការចោទប្រកាន់ដាច់ពីគ្នា។ ការចោទប្រកាន់តែមួយ គឺព្រះរាជាអាជ្ញាសម្រេចធ្វើការចោទប្រកាន់ចារីក្នុងសំណុំលិខិតចោទប្រកាន់តែមួយ ដែលទម្រង់នេះមានការពាក់ពន្ធតែសាលាដំបូងតែមួយប៉ុណ្ណោះ។ រីឯការចោទប្រកាន់ដាច់ពីគ្នាវិញ គឺជាស្ថានភាពដែលព្រះរាជអាជ្ញាធ្វើការបំបែកសំណុំរឿងចោទប្រកាន់របស់ចារីចាប់ពី ២សំណុំរឿងឡើងទៅដោយមូលហេតុមួយចំនួនដូចជាអង្គហេតុគ្មានការពាក់ព័ន្ធខ្វះភស្តុតាង ការឆ្លងដែនសមត្ថកិច្ចតុលាការ និងការកំណត់ដោយច្បាប់ជាដើម។ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បទល្មើសដោយប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗរបស់ក្រមព្រហ្មទណ្ឌ និងគប្បីអនុវត្តម៉ត់ចត់តាមក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាដល់ការគោរពច្បាប់ សិទ្ធិមនុស្ស តាមគោលការណ៍នីតិអន្តរជាតិ។

ចារីដែលមានពិរុទ្ធភាពប្រព្រឹត្តបទល្មើសត្រួតគ្នានឹងត្រូវផ្តន្ទាទោសតាមវិធានបទល្មើសត្រួតគ្នា រួមមានវិធានស្រូបទោស វិធានត្រួតទោស និងវិធានបូកទោសដែលបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ទណ្ឌកម្មព្រហ្មទណ្ឌតាមវិធានស្រូបទោស និងវិធានត្រួតទោស មានកម្រិតទោសដូចគ្នាទៅនឹងការផ្តន្ទាទោសធម្មតា ត្បិតថាក្នុងវិធានទាំងនេះនីតិនិពន្ធបានកម្រិតឲ្យនៅត្រឹមអតិបរិមាស្របច្បាប់ខ្ពស់ជាងគេតែប៉ុណ្ណោះ។ ការកម្រិតបែបនេះ បានខណ្ឌឆន្ទានុសិទ្ធិរបស់តុលាការមិនអាចផ្តន្ទាទោសចារីលើសពីច្បាប់បាន ទោះបីជាអំពីដែលចារីប្រព្រឹត្តមានលក្ខណៈសាហាវឃោរឃៅ ប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈធំធេងយ៉ាងណាក៏ដោយ។ ច្បាប់នឹងលែងមានភាពស៊ីចង្វាក់ជាមួយសង្គមតទៅទៀត នៅពេលគេមើលឃើញថាការប្រព្រឹត្តធ្ងន់ធ្ងរច្រើនដង ប៉ុន្តែទំហំទោសដែលប្រកាសចំពោះពិរុទ្ធភាពនោះ ស្មើឬប្រហាក់ប្រហែលការប្រកាសទោសទូទៅតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយមុនពេលក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ត្រូវធ្វើវិសោធនកម្មថ្មីតុលាការមិនអាចបង្កើនអតិបរមាទោសដោយខ្លួនឯងបានទេ ជំនួសមកវិញតុលាការត្រូវតែតាមដាន និងអនុវត្តនីតិវិធីចំពោះចារីដែលមានចរិកលក្ខណៈកាចសាហាវឲ្យតឹងរ៉ឹងបំផុត ដើម្បីឲ្យជនរងគ្រោះ និងក្រុមគ្រួសារមានភាពកក់ក្តៅពីសង្គម និងមានសុវត្ថិភាពពីចារី និងក្រុមបក្សពួក។

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវរបបប្រកាសទោសច្រើនបែបទម្រង់ដើម្បីផ្តល់ឲ្យតុលាការនូវជម្រើសសម្រាប់ថ្លឹងថ្លែង និងជ្រើសរើសរបបប្រកាសទោសណាមួយប្រកាសទៅលើចារី

ឲ្យសមស្របជាមួយសភាពជាក់ស្តែងរបស់ចារី ក្រុមគ្រួសារ សង្គម និងប្រទេសជាតិ។ របបប្រកាសទោសនីមួយៗមានលក្ខណៈជួយសម្រាលដល់ទណ្ឌិតក្នុងការអនុវត្តទោស បើករណីទណ្ឌិតបានដឹងកំហុសខិតខំសិក្សារៀនសូត្រ និងព្យាយាមកែខ្លួនឲ្យជាពលរដ្ឋល្អវិញ។ តុលាការអាចប្រកាសឲ្យទណ្ឌិតទទួលបានរបបប្រកាសទោសណាមួយដែលទណ្ឌិតអាចបំពេញលក្ខខណ្ឌច្បាប់បាន បន្ទាប់ពីមានការពិនិត្យវាយតម្លៃ និងស្នើសុំរបស់ព្រះរាជអាជ្ញា។ ត្បិតថាការចែងនូវរបបប្រកាសទោសធ្វើឡើង ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីកែប្រែជនដែលបានប្រព្រឹត្តបទល្មើសនោះឱ្យក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងធ្វើសមាហរណកម្មឱ្យចូលមករួមរស់ជាមួយសង្គមជាតិវិញ ដោយគេជឿថាការប្រើនូវរបបនេះ ក៏ជាគំរូមួយសម្រាប់ប្រជាពលរដ្ឋដទៃ មិនឱ្យប្រព្រឹត្តបទល្មើសដូចជននេះ ព្រោះអាចធ្វើឱ្យខ្លួនប្រឈមនឹងទោសព្រហ្មទណ្ឌបាន។ ការប្រើនូវរបបដោយឡែកដូចជា របបនៃការព្យួរទោស របបពាក់កណ្តាលសេរីភាពក៏ដូចជា ការបែងចែកទោសជាប្រភាគពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះទណ្ឌិត និងសង្គម ព្រោះថាការប្រកាសរបបទាំងនេះចំពោះទណ្ឌិតដែលបានផ្តន្ទាទោសហើយ គឺទណ្ឌិតមានលទ្ធ-ភាពក្នុងការកែប្រែ និងធ្វើសមាហរណកម្មមករួមរស់ជាមួយសង្គមវិញ ហើយថែមទាំងមិនបានកាត់ទំនាក់ទំនងរវាងទណ្ឌិត និងសង្គមទៀតផង។ ម៉្យាងវិញទៀត រដ្ឋមិនសូវចំណាយច្រើនទៅលើទណ្ឌិតទាំងនេះ ព្រោះការប្រកាសនូវរបបទាំងនេះគឺមិនត្រូវអនុវត្តទោសក្នុងពន្ធនាគារនោះទេ ដូច្នេះការចំណាយរបស់រដ្ឋទៅលើទណ្ឌិតនៅមន្ទីរឃុំឃាំងក៏បានកាត់បន្ថយច្រើនដែរ។

សរុបសេចក្តីមក ការចោទប្រកាន់បទល្មើស និងដំណើរការនីតិវិធីវិធាន និងការប្រកាសរបបអនុវត្តទោស ទាមទារឲ្យស្ថាប័នតុលាការទាំងមូលត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះអង្គហេតុបទល្មើសត្រួតនីមួយ ត្បិតថាវាមានលក្ខណៈរញ៉េរញ៉ៃច្រើន និងទាមទារឲ្យមានអំណះអំណាងច្បាប់គ្រប់គ្រាន់ក្នុងការជំនុំជម្រះក្តី។ តុលាការមិនត្រូវប្រើឆន្ទានុសិទ្ធិសម្រេចណាមួយ ដែលខុសពីសភាពជាក់ស្តែងរបស់ចារីបំពានច្បាប់ក្នុងគោលបំណងជួយសម្រួលដល់ចារី ដើម្បីទទួលទោសស្រាល ឬឆាប់រួចកាតព្វកិច្ចពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលវាអាចនាំទៅនិទណ្ឌភាពក្នុងសង្គមកម្ពុជា។ ដូច្នេះនៅក្នុងសវនាការប្រកាសទោស តុលាការត្រូវប្រកាន់ឲ្យបានភ្ជាប់ខ្លួននូវសតិសម្បជញ្ញៈរបស់ខ្លួនដោយប្រកាន់យ៉ាងម៉ឺងម៉ាត់ចំពោះច្បាប់ ឯករាជ្យភាព និងគោលការណ៍ឯកត្តកម្មនៃទោស ដែលជាគោលការណ៍សំខាន់បញ្ញត្តិយ៉ាងជាក់លាក់ក្នុងក្រមព្រហ្មទណ្ឌ ដើម្បីធានានូវយុត្តិធម៌ជូនជនរងគ្រោះ យុត្តិធម៌សម្រាប់សង្គម សុខសុវត្ថិភាព សណ្តាប់ធ្នាប់របៀបរៀបរយ ប្រទេសជាតិមានការអភិវឌ្ឍន៍ និងដើម្បីទទួលបានការផ្តល់ទំនុកចិត្តពីប្រជាជនចំពោះវិស័យយុត្តិធម៌នៅប្រទេសកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីការបកស្រាយនូវប្រធានបទខាងលើនេះរួចមក ខ្ញុំបាទយល់ឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងអំពីបទល្មើសត្រួតគ្នាជាលក្ខណគោលៗតែប៉ុណ្ណោះ ដែលខ្លឹមសារបកស្រាយលម្អិតសម្រាប់ធ្វើការសិក្សានិងអនុវត្តវិធាន គឺពឹងផ្អែកលើការបកស្រាយរបស់អ្នកជំនាញ នីតិបារាំង និងយុត្តិសាស្ត្រអង្គជំនុំជម្រះតុលាការកំពូល **អ.វ.ត.ក.** ជាដើម។ ការខ្វះខាតភាពពេញលេញនូវខ្លឹមសារច្បាប់សម្រាប់អនុវត្តវិធាន វាបានប៉ះពាល់យ៉ាងខ្លាំងដល់កិច្ចដំណើរការនីតិវិធី និងការធ្វើឆន្ទានុសិទ្ធិរបស់អង្គតុលាការក្នុងការសម្រេចសេចក្តី។ តាមក្រមព្រហ្មទណ្ឌបានកំណត់ថាការចោទប្រកាន់ក្នុងបទល្មើសត្រួតគ្នាធ្វើឡើងតាមទម្រង់ ២ប្រភេទ គឺការចោទប្រកាន់តែមួយ និងការចោទប្រកាន់ដាច់ពីគ្នា ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបញ្ចូលនីតិវិធីក្នុងដំណើរការសំណុំរឿងបទល្មើសត្រួតគ្នាលម្អិតឡើង ដោយភាគច្រើនការបន្តជំនុំជម្រះសំណុំរឿងពីតុលាការមួយឆ្លងទៅតុលាការមួយប្រើប្រាស់វិធានយុត្តិសាស្ត្រ និងការសម្រេចរបស់តុលាការឧទ្ធរណ៍។ ពិតណាស់ក្នុងសំណុំរឿងព្រហ្មទណ្ឌ យើងត្រូវការអង្គហេតុ និងអង្គច្បាប់គ្រប់គ្រាន់ដើម្បីនឹងធ្វើការចោទប្រកាន់ និងផ្តន្ទាទោសបុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឲ្យសមស្រមនឹងពិរុទ្ធភាព ក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈ និងសង្គមជាតិទាំងមូល។ ដូច្នេះ ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបញ្ញត្តិត្រូវបានច្បាស់លាស់នូវនីតិវិធីមួយនៃបទល្មើសត្រួត ចៀសវាងនិទណ្ឌភាពចំពោះបទល្មើសណាមួយ។

ចំពោះវិធានអនុវត្តទោសករណីមានបទល្មើសត្រួតគ្នា ក៏មិនត្រូវបានចែងលម្អិតឲ្យបានច្បាស់លាស់អំពីនីតិវិធីក្នុងការអនុវត្តផងដែរ កាលនេះធ្វើឲ្យមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវច្បាប់នានាខិតខំសិក្សាស្រាវជ្រាវពីនីតិបរទេសដទៃដែលមានប្រព័ន្ធច្បាប់ស៊ីវិល រួចទាញអំណះអំណាងភ្ជាប់ជាមួយនីតិកម្ពុជា ដែលនាំឲ្យការបកស្រាយមានលទ្ធផលខុសៗគ្នាទៅតាមប្រទេសដែលគេយកជាម៉ូដែល។ អត្ថបទទាំងនោះបានជះឥទ្ធិពលអវិជ្ជមានដល់អ្នកសិក្សានីតិកម្ពុជាប្រសិនបើការបកស្រាយទាំងនោះមានអត្ថន័យខុសពីគោលបំណងដើមរបស់នីតិកម្ពុជា។ ដំណោះស្រាយក្នុងបញ្ហានោះ ទាមទារឲ្យក្រសួងយុត្តិធម៌ មន្ត្រីក្នុងវិជ្ជាជីវៈ និងស្ថាប័នជំនាញពាក់ព័ន្ធ ចូលរួមផ្សព្វផ្សាយតាមគ្រប់មធ្យោបាយដើម្បីលើកកម្ពស់ចំណេះដូវច្បាប់តាមស្មារតីដើម លុបបំបាត់ចម្ងល់ និងការយល់ខុសរបស់អ្នកសិក្សាដែលមិនទាន់យល់ច្បាស់អំពីបទល្មើសត្រួតគ្នានេះ។ ម្យ៉ាងវិញ គេសង្កេតឃើញថាវិធានស្រូបទោសនិងវិធានត្រួតទោស មានលក្ខណៈសម្រាលទោសខ្លាំងពេកដល់ទណ្ឌិត ដែលពិបាកក្នុងការឲ្យសង្គមទទួលយកបាន ត្បិតថាអំពើខ្លះទណ្ឌិតបានប្រព្រឹត្តអំពើកាចសាហាវ គ្មានចិត្តមេត្តា និងគ្មានគំនិតភ្ញាក់រលឹកមុននឹងត្រូវបានអាជ្ញាធរឃាត់ខ្លួន។ ប៉ុន្តែដោយវិធានទាំង២ខាងលើ បានកំណត់ទោសត្រឹមព្រំដែនអតិបរមាទោសស្របច្បាប់ ហេតុនេះតុលាការមិនអាចប្រកាសផ្តន្ទាទោសទណ្ឌិតឲ្យលើសពីអ្វីដែលច្បាប់បានចែងនោះទេ ទោះបីជាពេលខ្លះតុលាការយល់ថាអំពីទាំងនោះមិនសមទទួលទណ្ឌកម្មព្រហ្មទណ្ឌត្រឹមព្រំដែនអតិបរមាស្របច្បាប់ក៏ដោយ។ ហេតុនេះក្នុងនាមខ្ញុំបាទជានិស្សិតសិក្សាផ្នែកច្បាប់មួយរូបសូមស្នើសុំឲ្យមានវិសោធនកម្មក្រមព្រហ្មទណ្ឌ

លើកក្រោយ ដោយពិនិត្យត្រង់ចំណុចបទល្មើសត្រួតគ្នានិងធ្វើការលុបចោលនូវព្រំដែនអតិបរមាសម្រាប់ប្រកាសទោសក្នុងវិធានស្រូបនិងវិធានត្រួតទោស ដើម្បីផ្តល់ឲ្យតុលាការអាចធ្វើឆន្ទានុសិទ្ធិផ្តន្ទាទោសទណ្ឌិតសមនឹងពិរុទ្ធ-ភាពអាចឲ្យសង្គមរំងាប់ចិត្ត និងទទួលយកបាន។ ចំពោះការស្រូបទោសក្នុងការចោទប្រកាន់ដាច់ពីគ្នាវិញ ចំណុចនេះត្រូវកំណត់នូវលក្ខខណ្ឌទទួល ឲ្យបានច្បាស់លាស់ មុនពេលតុលាការសម្រេចប្រកាសផ្តល់ទៅឲ្យទណ្ឌិតដូចជាកំណត់អំពីចំនួនទោសពន្ធនាគារក្រោមឬស្មើ ៥ឆ្នាំ ឬអាចទទួលបានតែបទមជ្ឈិម និងបទលហុជាដើម។

បន្ថែមពីនេះ ដើម្បីអាចឲ្យប្រព័ន្ធយុត្តិធម៌កម្ពុជាទទួលបានការគាំទ្រ និងជំនឿទុកចិត្តពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិ តុលាការត្រូវតែធានារក្សាភាពមិនលំអៀង ប្រកាន់នៅជំហរ និងសមត្ថកិច្ចរបស់ខ្លួនក្នុងការវិនិច្ឆ័យមុននឹងប្រកាសសេចក្តីសម្រេចដោយផ្អែកតាមច្បាប់យ៉ាងម៉ឺងម៉ាត់បំផុត។ អ្វីដែលរឹតតែសំខាន់ទៀតនេះ ត្រូវបង្កើតឲ្យមានអង្គភាពដែលមានសិទ្ធិអំណាចពេញលេញ មានភារកិច្ចត្រួតពិនិត្យ និងតាមដានការងារជាប្រចាំក្នុងវិស័យយុត្តិធម៌ លុបបំបាត់ចោលនូវភាពមិនប្រក្រតីក្នុងសវនាការ និងអំពើពុករលួយដែលនៅតែចោទជាបញ្ហា។ លើកទឹកចិត្ត និងចូលរួមការផ្សព្វផ្សាយច្បាប់ជូនដល់ប្រជាជនកម្ពុជាទាំងមូល ឲ្យយល់ដឹងអំពីច្បាប់ចៀសវាងការប្រព្រឹត្តបទល្មើសដោយចេតនាក្តី ឬអចេតនាក្តីដែលនាំទៅរកការទទួលខុសត្រូវព្រហ្មទណ្ឌ ខាតបង់ពេលវេលា កិត្តិយសថវិកា និងមុខមាត់ប្រទេសជាតិជាដើម។

ជាចុងបញ្ចប់ ខ្ញុំបាទសង្ឃឹមថាប្រព័ន្ធយុត្តាធិការនៃប្រទេសកម្ពុជាយើងនឹងអាចអនុវត្តការជំនុំជម្រះបទល្មើសត្រួតគ្នាដោយមានស្តង់ដាច្បាប់គោលតែមួយនៅសាលាជំនុំជម្រះទូទាំងប្រទេស និងធ្វើការជំនុំជម្រះក្តីដោយយុត្តិធម៌ និងចំណាយពេលវេលាតិច។ ការសម្រេចក្តីត្រូវធ្វើឡើងដោយគិតអំពីអនាគតរបស់ទណ្ឌិត និងផលប្រយោជន៍របស់សង្គម ព្រោះថាទណ្ឌិតនឹងត្រូវបានដោះលែងឲ្យចូលទៅកសាងអនាគតក្នុងសង្គម នៅពេលបានអនុវត្តទោសរួចរាល់។

# បញ្ជីឯកសារយោង

# បញ្ជីឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ , នស/រកត/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ , នស/រកត/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ២. សៀវភៅមេរៀនច្បាប់

- សៀវភៅជំនួយព្រហ្មទណ្ឌដែលចងក្រងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ស្តីពីនីតិព្រហ្មទណ្ឌទូទៅ បានបោះពុម្ភក្នុងឆ្នាំ២០២២
- សៀវភៅជំនួយព្រហ្មទណ្ឌដែលចងក្រងដោយលោក **ចក សម្បត្តិ** ស្តីពីបទល្មើសត្រួតគ្នា បានបោះពុម្ភក្នុងខែឧសភា ឆ្នាំ២០១៥
- ឯកសារសម្រាប់ស្មារតីសម្រាប់ការស្វែងយល់ព្រហ្មទណ្ឌ រៀបរៀងដោយឯកឧត្តម **ហ៊ី សោភា** និង ឯកឧត្តម **កើត រិទ្ធ**។

## ៣. វចនានុក្រម

- សន្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ របស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ភលើកទី១ ឆ្នាំ២០១១
- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ **ជួន ណាត**។